**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន

ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **នាង ខេមរា**

លោក **អ៊ឹម ធីរៈ**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ជុំ អ៊ឹម**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២៤**

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **នាង ខេមរា** និង **អ៊ឹម ធីរៈ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ សិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ មាតាបិតា អាណាព្យាបាលដែលជាអ្នកមានគុណចំពោះរូបកូនៗយ៉ាងធំធេង លោកបានខិតខំប្រឹងប្រែងតស៊ូដោយព្រហ្មវិហារធម៌ចិញ្ចឹមបីបាច់ថែរក្សា លះបង់អស់កម្លាំងកាយចិត្ត លះបង់ធនធាន ផ្តល់នូវសេចក្តីស្រឡាញ់ ដំបូន្មាន ការអប់រំ និងប្រៀនប្រដៅ ព្រមទាំងផ្តល់នូវភាពកក់ក្តៅឱ្យដល់រូបកូនតាំងពីតូចរហូតដល់ពេលបច្ចុប្បន្ននេះ។ កូនសូមក្រាបបង្គំប្រណិបត្តិ និងសម្តែងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះអ្នកមានគុណទាំងពីរ និងអ្នកអាណាព្យាបាលដែលមានចំពោះកូនៗទាំងអស់គ្នា។

**ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ បណ្ណារក្ស និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីសមត្ថភាពក្នុងការដឹកនាំ និងពង្រឹងគុណភាពកម្មវិធីសិក្សាដល់និស្សិតគ្រប់មុខជំនាញ ប្រកបដោយប្រសិទ្ធិភាពការងារខ្ពស់ ព្រមទាំងចែករំលែកចំណេះដឹង បទពិសោធន៍ល្អៗជាច្រើនដល់រូបយើងខ្ញុំ។

សាស្ត្រាចារ្យជំនួយ **ជុំ អ៊ឹម** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ព្រោះថាប្រសិនបើគ្មានការចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្ត ក្នុងការជួយជ្រោមជ្រែងផ្តល់ការណែនាំ គំនិតយោបល់ និងផ្តល់ជាវិធីសាស្ត្រល្អៗដល់យើងខ្ញុំទេនោះ សមិទ្ធផលនេះមិនអាចកើតមានឡើយ ព្រោះគ្មានសមិទ្ធផលណាមួយអាចកើតឡើងបានដោយឯកឯងនោះទេ។

និស្សិតរៀមច្បង និង មិត្តនិស្សិតដទៃទៀតដែលបានលើកទឹកចិត្ត គាំទ្រផ្តល់ជាបទពិសោធន៍ គំនិតយោបល់ល្អៗ ដែលជម្រុញឱ្យពួកខ្ញុំកាន់តែមានទឹកចិត្តក្នុងការសម្រេចបាននូវសារណានេះដោយមិនរាថយ ដើម្បីទុកជាវិភាគទានក្នុងការសិក្សាស្រាវជ្រាវផ្សេងៗសម្រាប់មិត្តនិស្សិត និងប្អូនៗជំនាន់ក្រោយៗ។

ជាចុងបញ្ចប់ចុងបញ្ចប់នេះ យើងខ្ញុំសូមបួងសួងដល់វត្ថុសក្តិសិទ្ធទាំងឡាយ ក្នុងព្រះរាជាណាចក្រកម្ពុជា ជួយប្រសិទ្ធិពរជ័យជូនដល់អ្នកមានគុណទាំងទ្វេ អ្នកអាណាព្យាបាល លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់គ្នា ជួបតែសេចក្តីសុខ សេចក្តីចម្រើន ព្រមទាំងជួបប្រទះទៅនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំទាំងពីរនាក់ជានិស្សិតឆ្នាំទី ៤ បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានខិតខំសិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមពីច្បាប់ជាតិ ច្បាប់អន្តរជាតិ ព្រមទាំងបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួនទៀត ដើម្បីរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមួយនេះឡើងសម្រាប់ធ្វើជាឯកសារជំនួយស្មារតីដល់និស្សិត អ្នកសិក្សាគ្រប់រូបដែលកំពុងសិក្សានៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានបំណងចង់ស្វែងយល់ពាក់ព័ន្ធនឹងប្រធានបទ “**បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន**” ។

នៅក្នុងឯកសារនេះ គ្រប់ផ្នែកទាំងអស់សុទ្ធសឹងតែបានលើកយកចំណុចនីមួយៗមកធ្វើការអធិប្បាយពង្រីកសេចក្តី ប្រៀបធៀបគ្នាយ៉ាងលម្អិត ព្រមទាំងមានលើកយកនូវមាត្រាច្បាប់ និងគោលការណ៍របស់ច្បាប់ផ្សេងៗដែលពាក់ព័ន្ធធ្វើជាមូលដ្ឋានក្នុងការបកស្រាយ ដើម្បីជាជំនួយស្មារតីដល់ការសិក្សាស្វែងយល់របស់និស្សិត ផ្នែកនីតិសាស្ត្រទាំងអស់ដែលកំពុងសិក្សា និងស្រាវជ្រាវនូវមេរៀនទាក់ទងនឹងបត្យាប័ន ដើម្បីអាចទទួលបាននូវចំណេះដឹងបន្ថែមលើការសិក្សានូវមុខជំនាញផ្នែកនីតិសាស្ត្រ ឬយកទៅប្រើប្រាស់ក្នុងវិជ្ជាជីវៈរបស់ខ្លួនផងដែរ។

យើងខ្ញុំទាំងពីរសង្ឃឹមថា ការរៀបរៀងនេះនឹងក្លាយជាប្រទីបមួយសម្រាប់ជាឯកសារជំនួយស្មារតីដល់និស្សិតផ្នែកច្បាប់ ព្រមទាំងមិត្តអ្នកអានទាំងអស់ សម្រាប់ប្រើប្រាស់ជាឯកសារក្នុងការសិក្សា ការស្រាវជ្រាវ ព្រមទាំងស្វែងយល់ចំណុចសំខាន់ៗ ដើម្បីទទួលចំណេះដឹងអំពីមុខវិជ្ជានេះ សម្រាប់ធ្វើជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការសិក្សាផ្នែកនីតិសាស្ត្រ ឬនីតិអន្តរជាតិជាដើម។

សូមមេត្តាអធ្យាស្រ័យចំពោះរាល់កំហុសឆ្គងទាំងឡាយ ដែលកើតមានឡើងដោយអចេតនាមានទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធផ្សេងៗក្នុងការតាក់តែងឯកសារនេះឡើង។ ម្យ៉ាងទៀត យើងខ្ញុំសូមទទួលយកទស្សនៈ និងគំនិតតិចតៀមទាំងឡាយរបស់និស្សិត មិត្តអ្នកអានទាំងអស់ចំពោះការរិះគន់ ក្នុងន័យស្ថាបនាដើម្បីឱ្យឯកសារនេះ រឹតតែមានខ្លឹមសារ និងអត្ថន័យកាន់តែសុក្រិតថែមមួយកម្រិតទៀត។

ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត អ្នកអានគ្រប់រូប សូមប្រកបដោយពុទ្ធពរជ័យទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងទទួលបានជោគជ័យរាល់ភារកិច្ច។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ..................................................... ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃបត្យាប័ន**

**ផ្នែកទី១. ការកកើតបត្យាប័ន** ..................................................... ៤

១. ប្រវត្តិបត្យាប័ន ..................................................... ៤

២. គោលបំណងនៃបត្យាប័ន ..................................................... ៥

**ផ្នែកទី២. ច្បាប់ពាក់ព័ន្ធ** ..................................................... ៦

១. ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ..................................................... ៦

២. សន្ធិសញ្ញាស្តីពីការធ្វើបត្យាប័នរបស់អង្គការសហប្រជាជាតិ ..................................................... ៦

៣. សន្ធិសញ្ញាអន្តរជាតិ ..................................................... ៦

៤. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧ ..................................................... ៧

៥. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩ ..................................................... ៧

**ជំពូកទី២**

**លក្ខខណ្ឌនៃបត្យាប័ន**

**ផ្នែកទី១. មូលដ្ឋាននៃការធ្វើបត្យាប័ន** ..................................................... ៩

១. លក្ខខណ្ឌទាក់ទងនឹងបទល្មើស ឬទ្វិកភាពនៃបទល្មើស ..................................................... ៩

២. លក្ខខណ្ឌទាក់ទងនឹងទោសពន្ធនាគារ ..................................................... ៩

៣. លក្ខខណ្ឌទាក់ទងនឹងបុគ្គល ..................................................... ១០

៤. លក្ខខណ្ឌទាក់ទងនឹងពាក្យសុំ ..................................................... ១១

៤.១. ភាពធ្ងន់ធ្ងរនៃបទល្មើស ..................................................... ១១

៤.២. ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តិបទល្មើស ..................................................... ១៣

៤.៣. កាលបរិច្ឆេទ និងលំដាប់មកដល់នៃសំណើស្នើសុំ ..................................................... ១៣

៤.៤. សញ្ជាតិ លំនៅឋាន ទីសំណាក់នៃបុគ្គលដែលគេទាមទារ និងជនរងគ្រោះ ..................................................... ១៣

៤.៥. លទ្ធភាពប្រគល់មកវិញនូវបុគ្គលដែលគេទាមទាររបស់រដ្ឋធ្វើសំណើ ........ ១៣

**ផ្នែកទី២. មូលដ្ឋានបដិសេធនៃការធ្វើបត្យាប័ន ........ ១៣**

១. មូលដ្ឋានដាច់ខាត ........ ១៤

១.១. បទល្មើសនយោបាយ ........ ១៤

១.២. ការប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង ........ ១៥

១.៣. បទល្មើសយោធា ........ ១៦

១.៤. អាជ្ញាយុកាល ........ ១៩

១.៤.១. អាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ........ ១៩

១.៤.២.អាជ្ញាយុកាលនៃទោស ........ ២០

១.៤.៣. មរណភាពនៃជនល្មើស ........ ២១

១.៤.៤. ការផុតអាជ្ញាយុកាល ........ ២១

១.៤.៥. ការលើកលែងទោសទូទៅ ........ ២១

១.៤.៦. និរាករណ៍ច្បាប់ព្រហ្មទណ្ឌ ........ ២២

១.៤.៧. អាជ្ញាអស់ជំនុំ ........ ២២

១.៥. អានុភាពសាលក្រមចេញដោយរដ្ឋទទួលសំណើ ........ ២២

១.៦. សាលក្រមកំបាំងមុខរបស់ភាគីដាក់សំណើ ........ ២៣

២. មូលដ្ឋានបដិសេធដោយឆន្ទានុសិទ្ធិ ........ ២៣

២.១. មូលដ្ឋានច្បាប់របស់ភាគីទទួលសំណើ ........ ២៤

២.២. គោលការណ៍គាំពារមនុស្សធម៌ ........ ២៤

## ជំពូកទី៣

## នីតិវិធីបត្យាប័ន

**ផ្នែកទី១. ព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើ ........ ២៦**

១. ការត្រួតពិនិត្យនីតិវិធីរដ្ឋបាល ........ ២៦

២. ការដំណើរនីតិវិធីដំណាក់កាលស្ថាប័នមហាអយ្យការអមសាលាឧទ្ធរណ៍ ........ ២៧

២.១. នីតិវិធីចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ........ ២៨

២.២. ការឃុំខ្លួនបណ្តោះអាសន្ន ........ ៣០

២.២.១. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ........ ៣១

២.២.២. ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន (ច្បាប់កម្ពុជា) ........................ ៣១
៣. នីតិវិធីចំពោះមុខសភាស៊ើបសួរ ........................ ៣៣
៤. ការពន្យារពេលនៃការប្រគល់ខ្លួន និងការប្រគល់ខ្លួនជាបណ្តោះអាសន្ន ........................ ៣៥
**ផ្នែកទី២. ព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើ ........................ ៣៥**
១. សំណើបត្យាប័ន ........................ ៣៥
២. នីតិវិធីចំពោះមុខសភាស៊ើបសួរ ........................ ៣៧
៣. អានុភាពនៃមោឃភាពបត្យាប័ន ........................ ៣៨
៣.១. អានុភាពមិនផ្អាកនៃបណ្តឹងសុំមោឃភាព ........................ ៣៨
៣.២. អានុភាពនៃមោឃកម្មចំពោះបត្យាប័ន ........................ ៣៨
៤. នីតិវិធីក្រោយផ្តល់បត្យាប័ន ........................ ៣៨
៤.១. ការប្រគល់ខ្លួនដែលត្រូវស្នើសុំ ........................ ៣៩
៤.២. ការប្រគល់នូវទ្រព្យសម្បត្តិ ........................ ៣៩
៤.៣. ការឧបត្ថម្ភ និងការចំណាយ ........................ ៤០
**សេចក្តីសន្និដ្ឋាន ........................ ៤១**
**អនុសាសន៍ ........................ ៤៣**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅលើពិភពលោកយើងនេះរដ្ឋនីមួយៗតែងតែមានទំនាក់ទំនងល្អជាមួយនឹងរដ្ឋដទៃជុំវិញខ្លួន ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការជាមួយបណ្តារដ្ឋដទៃដូចជាផ្នែកនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ មនុស្សជាតិ ច្បាប់ និងកិច្ចសហប្រតិបត្តិការផ្សេងៗ។ ទោះបីជាទំនាក់ទំនងរដ្ឋនីមួយៗមានភាពជិតស្និទ្ធជាមួយគ្នាយ៉ាងណាក៏ដោយ ក៏រដ្ឋមួយមិនអាចរំលោភអធិបតេយ្យភាពដែនដីរបស់រដ្ឋមួយផ្សេងទៀតបានដែរ ព្រោះដែនសមត្ថកិច្ចនៃការអនុវត្តច្បាប់របស់រដ្ឋនីមួយៗ គឺមានអានុភាពអនុវត្តត្រឹមតែនៅក្នុងដែនដីរបស់ខ្លួនតែប៉ុណ្ណោះ មិនអាចពង្រីកដែនសមត្ថកិច្ចរបស់ខ្លួនចូលទៅក្នុងដែនដីរបស់បណ្តារដ្ឋណាមួយបានឡើយ។ ជាក់ស្តែងប្រទេសកម្ពុជា និងប្រទេសចិន ជាប្រទេសជិតខាងល្អ ដែលមានប្រវត្តិទំនាក់ទំនងជាប្រពៃណី និងជាមេត្រីភាពតាំងពីយូរយារណាស់មកហើយ ដោយបានរក្សាបន្តនូវប្រវត្តិរឿងរ៉ាវជាគំរូល្អៗជាច្រើននៅក្នុងប្រវត្តិសាស្ត្រ ដែលត្រូវបានកូនចៅជំនាន់ក្រោយអនុវត្តបន្តពីមួយជំនាន់ទៅមួយជំនាន់។ ទោះបីជាប្រទេសទាំងពីរនេះមានប្រវត្តិទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធិតាំងពីយូរយារក្តី ក៏ប្រទេសទាំងពីរមិនអាចរំលោភអធិបតេយ្យភាពដែនដីគ្នាបានដែរ។ ចំណុចនេះហើយទើបនៅក្នុងយុគ្គសម័យកាល ការធ្វើដំណើរគឺមានភាពងាយស្រួលចំពោះឧក្រិដ្ឋជនដែលពួកគេអាចគេចពីសំណាញ់ច្បាប់ ដោយការរត់គេចខ្លួនទៅជ្រកកោនពីប្រទេសមួយទៅប្រទេសផ្សេងមួយទៀត ដើម្បីគេចខ្លួនពីបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ វាជាបញ្ហាផ្លូវច្បាប់មួយដែលជនល្មើសអាចគេចខ្លួនបានយ៉ាងស្រួល ដោយគ្រាន់តែចាកចេញពីប្រទេសដែលខ្លួនបានប្រព្រឹត្តបទល្មើស ដោយសារតែក្នុងសម័យកាលនោះគេក៏ពុំទាន់មានការសហប្រតិបត្តិការរវាងរដ្ឋ និងរដ្ឋ ដើម្បីបញ្ជូន ឬ ចាប់ខ្លួនអ្នកដែលបានប្រព្រឹត្តបទល្មើសនោះផងដែរ។

កាលពីខែមេសា ឆ្នាំ១៩៥៥ លោកចូវ អ៊ីនឡាយ នាយករដ្ឋមន្ត្រីសាធារណរដ្ឋប្រជាមានិតចិន និងព្រះករុណាព្រះបាទសម្តេចនរោត្តមសីហនុ បានជួបគ្នានៅក្នុងសន្និសីទអាស៊ីអាហ្វ្រិកនៅទីក្រុងបានឌុង ដែលប្រការនេះបានក្លាយទៅជាទីចាប់ផ្តើមថ្មីមួយបន្ថែមទៀតនៃទំនាក់ទំនងមេត្រីភាពរវាងប្រទេសកម្ពុជា និងចិន។ ដើម្បីបង្ការរាល់បទល្មើសឆ្លងដែន ប្រទេសកម្ពុជាបានធ្វើបត្យាប័នជាមួយប្រទេសជិតខាងដែលក្នុងនោះមានដូចជា កម្ពុជា ថៃ ឡាវ វៀតណាម និងសាធារណរដ្ឋប្រជាមានិតចិនផងដែរ។ ចាប់តាំងពីពេលនោះមកការធ្វើបត្យាប័នរវាងកម្ពុជា និងចិនបានដើរតួនាទីយ៉ាងសំខាន់សម្រាប់រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលប្រទេសចិនក្នុងការបង្កើតកិច្ចសហប្រតិបត្តិការជាមួយគ្នាយ៉ាងជិតស្និទ្ធថែមទៀតផង។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីងាយស្រួលក្នុងការប្រមូលផ្តុំគោលគំនិតសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងឆ្លើយតបឱ្យមានភាពកាន់តែច្បាស់លាស់ទៅលើប្រធានបទខាងលើនេះ ខ្ញុំបាទបានសូមលើកឡើងនូវចំណោទបញ្ហាគតិយុត្តមួយចំនួនមកធ្វើការដោះស្រាយៈ

១. តើបត្យាប័នមានសារៈសំខាន់ និងផ្តល់អត្ថប្រយោជន៍អ្វីខ្លះ?

២. តើបត្យាប័នមានលក្ខខណ្ឌ និងនីតិវិធីដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការតាក់តែងសារណានេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីចង់បង្ហាញតម្លៃនៃការធ្វើបត្យាប័នរវាងរដ្ឋ និងរដ្ឋ ក្នុងដំណើរការនៃការបង្ក្រាបបទល្មើសឆ្លងដែន និងបង្ការភាពអសន្តិសុខនៅក្នុងបណ្តារដ្ឋនីមួយៗ។ ប្រសិនបើបណ្តារដ្ឋទូទាំងសកលលោកមានបត្យាប័នជាមួយគ្នា តើវាមានផលប្រយោជន៍អ្វីខ្លះដល់សង្គមជាតិ? ផ្ទុយទៅវិញប្រសិនបើបណ្តារដ្ឋនីមួយៗ គ្មានបត្យាប័នជាមួយគ្នា តើវានឹងមានផលប៉ះពាល់អ្វីខ្លះដល់សង្គម?

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឱ្យការស្រាវជ្រាវប្រព្រឹត្តទៅបានល្អ និងអាចធ្វើការវិភាគឱ្យបានគ្រប់ជ្រុងជ្រោយ វិសាលភាពនៃការស្រាវជ្រាវទៅលើប្រធានបទស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន គឺត្រូវផ្តោតការយកចិត្តទុកដាក់លើសិទ្ធិ លក្ខខណ្ឌ និងនីតិវិធីក្នុងការធ្វើបត្យាប័នរវាងកម្ពុជា និងចិនតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះសារៈសំខាន់ ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះនឹងចូលរួមជាវិភាគទានមួយដ៏សំខាន់នៅក្នុងការសិក្សាស្រាវជ្រាវទៅលើការដំណើរការក្នុងការបញ្ជូនខ្លួនជនសង្ស័យ ឬ អ្នកទោសពីរដ្ឋមួយទៅរដ្ឋមួយទៀត។ បន្ថែមពីនេះ វាក៏ជាឯកសារមួយដែលអាចបំពេញសេចក្តីត្រូវការជាចាំបាច់ដល់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវ ងាយស្រួលក្នុងការវិភាគ និងអាចស្វែងរកចំណុចខ្វះខាតនៃច្បាប់ដើម្បីធ្វើការកែប្រែបន្ថែមនាពេលអនាគតផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ៦.១. វិធីសាស្ត្រប្រមូលទិន្នន័យ

- **ទិន្នន័យចម្បង** ជាប្រភេទទិន្នន័យផ្ទាល់ (Primary Data) បានសាកសួរសំណួរមួយចំពោះសាស្ត្រាចារ្យច្បាប់ ជាពិសេសសាស្ត្រាចារ្យណែនាំផ្ទាល់។

- **ទិន្នន័យបន្ទាប់បន្សំ** (Secondary Date) បានមកពីការដកស្រង់ចំពោះខ្លឹមសារសំខាន់ៗដែលប្រមូលបានពីលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិដែលមានជាធរមាន សៀវភៅ របាយការណ៍ ឯកសារនៅតាមបណ្ណាល័យនានាក្នុងរាជធានីភ្នំពេញ គេហទំព័រនានា ដែលយើងខ្ញុំបានចងក្រងដាក់នៅក្នុង និងឯកសារយោង និងឧបសម្ព័ន្ធមួយចំនួនទៀត។

### ៦.២. វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលមកបាន គឺយកមកវិភាគតាមរយៈការពិពណ៌នាបែបគុណភាពដោយប្រើទិន្នន័យទីពីរ ច្រើនលើសលប់ជាងទិន្នន័យទីមួយ ព្រោះថាទិន្នន័យទីពីរយើងខ្ញុំប្រមូលបានច្រើន ដែលជាហេតុធ្វើឱ្យយើងខ្ញុំត្រូវធ្វើការវិភាគឱ្យបានល្អិតល្អន់គ្រប់ជ្រុងជ្រោយជាងទិន្នន័យទីមួយ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានបង្ហាញជា **៣ ជំពូក**ដូចខាងក្រោមនេះ៖

**សេចក្តីផ្តើម**

**ជំពូកទី១៖ សញ្ញាណទូទៅ**

**ជំពូកទី២៖ លក្ខខណ្ឌនៃបត្យាប័ន**

**ជំពូគទី៣៖ នីតិវិធីបត្យាប័ន**

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

# ជំពូកទី១

# សញ្ញាណទូទៅ

# ជំពូកទី១

# សញ្ញាណទូទៅនៃបត្យាប័ន

## ផ្នែកទី១. ការកកើតបត្យាប័ន

### ១. ប្រវត្តិបត្យាប័ន

ប្រទេសកម្ពុជា និងចិន ជាប្រទេសជិតខាងល្អ ដែលមានប្រវត្តិទំនាក់ទំនងជាប្រពៃណី និងជាមេត្រីភាពតាំងពីយូរយារណាស់មកហើយ ដោយបានរក្សាបន្តនូវប្រវត្តិរឿងរ៉ាវជាគំរូល្អៗជាច្រើននៅក្នុងប្រវត្តិសាស្ត្រដែលត្រូវបានកូនចៅជំនាន់ក្រោយអនុវត្តបន្តពីមួយជំនាន់ទៅមួយជំនាន់។ នៅខែមេសា ឆ្នាំ១៩៥៥ លោកចូវ អ៊ីនឡាយ នាយករដ្ឋមន្ត្រីចិន និងព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ បានជួបគ្នានៅក្នុងសន្និសីទអាស៊ីអាហ្វ្រិកនៅទីក្រុងបានឌុង ដែលប្រការនេះបានក្លាយទៅជាទីចាប់ផ្តើមថ្មីមួយបន្ថែមទៀតនៃទំនាក់ទំនងមេត្រីភាពរវាងប្រទេសកម្ពុជា និងចិន។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៨ ប្រទេសកម្ពុជា និងចិន បានចាប់ផ្តើមមានទំនាក់ទំនងការទូតជាផ្លូវការ។ ចាប់តាំងពីមានចំណងទាក់ទងការទូតរយៈពេលជាងពាក់កណ្តាលសតវត្សកន្លងមកនេះ ភាគីទាំងពីរមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយគ្នាលើគ្រប់វិស័យដូចជា ផ្នែកនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ មនុស្សជាតិ ព្រមទាំងកិច្ចការក្នុងតំបន់ និងអន្តរជាតិ។ បន្ថែមពីនោះព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនបានអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលធ្វើនៅទីក្រុងប៉េកាំង នាថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩។

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនត្រូវបានធ្វើឡើងជាពីរច្បាប់ នៅទីក្រុងប៉េកាំង ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ជាភាសាខ្មែរ ភាសាចិន និងភាសាអង់គ្លេស ដោយមានការចុះហត្ថលេខារបស់តំណាងព្រះរាជាណាចក្រកម្ពុជា និងតំណាងសាធារណរដ្ឋប្រជាមានិតចិន។[1] ក្រោយពីការចុះសន្ធិសញ្ញានៅទីក្រុងប៉េកាំងរួចមក ព្រះរាជាណាចក្រកម្ពុជាបានប្រកាសឱ្យប្រើជាផ្លូវការដោយផ្អែកលើច្បាប់ស្តីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ដោយមានឡាយព្រះហស្តលេខា **ព្រះបាទសម្តេចនរោត្តមសីហនុ** ជាប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអមដោយហត្ថលេខា

[1] សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន, នស/រកម/០៧០០/០៤, ០៩ កុម្ភៈ ១៩៩៩, ប្រការទី២២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី និងហត្ថលេខា **ឯកឧត្តម ហោ ណាំហុង** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។[2]

បត្យាប័ន សំដៅទៅលើទម្រង់នៃការអនុវត្តនីតិវិធីខ្នាតអន្តរជាតិដោយផ្អែកទៅលើលក្ខខណ្ឌដែលបានអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័ន ក្នុងការបង្ក្រាបបទល្មើសជាលក្ខណៈអន្តរជាតិតាមរយៈកិច្ចសហប្រតិបត្តិការរវាងរដ្ឋ។

**២. គោលបំណងនៃបត្យាប័ន**

ច្បាប់ស្តីពីការធ្វើបត្យាប័ន គឺត្រូវបានកំណត់គោលការណ៍ និងវិធានការសម្រាប់ការគ្រប់គ្រង និងការត្រួតពិនិត្យការធ្វើបត្យាប័ន ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមច្បាប់ និងបទប្បញ្ញត្តិ បទដ្ឋានអន្តរជាតិ កិច្ចព្រមព្រៀង និងសន្ធិសញ្ញាអន្តរជាតិដែលមានគោលបំណងក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ឧក្រិដ្ឋកម្ម ដោយមានបំណងជំរុញដល់កិច្ចសហប្រតិបត្តិការអន្តរជាតិប្រកបដោយប្រសិទ្ធភាព ក្នុងវិស័យនេះដោយផ្អែកលើមូលដ្ឋានស្តីពីការគោរពឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី សមភាព និងផលប្រយោជន៍ទៅវិញទៅមក ហើយបត្យាប័ន ជាយន្តការមួយត្រូវធ្វើឡើងដោយរដ្ឋជាភាគីធ្វើសំណើសុំទៅរដ្ឋជាភាគីម្ខាងទៀតដើម្បីបញ្ជូនឧក្រិដ្ឋជនដែលបានប្រព្រឹត្តបទល្មើសយកមកកាត់ទោស ឬទទួលអនុវត្តទោសក្នុងគោលបំណងបង្ការកុំឱ្យឧក្រិដ្ឋជនគេចខ្លួនពីការផ្តន្ទាទោសដោយច្បាប់នៃប្រទេសណាមួយ។ បត្យាប័នត្រូវបានក្លាយទៅជានយោបាយទូទៅដំបូងបំផុតមួយនៅសតវត្សទី១៩។ ច្បាប់អន្តរជាតិមិនទទួលស្គាល់ថា បត្យាប័នជាកាតព្វកិច្ចមួយទេក្នុងពេលដែលគ្មានកិច្ចព្រមព្រៀងណាមួយរវាងរដ្ឋដែលត្រូវធ្វើបត្យាប័នជាមួយគ្នា។ តាមធម្មតាទោះបីជារដ្ឋមួយអាចបដិសេធការសុំជ្រកកោនរបស់អ្នករត់គេចខ្លួនម្នាក់ ឬ គោរពតាមការស្នើសុំធ្វើបត្យាប័នណាមួយក៏ដោយចុះ ក៏ក្នុងការពិតជាក់ស្តែង ការធ្វើបត្យាប័នទាំងអស់ប្រព្រឹត្តទៅតែក្រោមអំណាចនៃកិច្ចព្រមព្រៀងទ្វេភាគីតែប៉ុណ្ណោះ។ បន្ថែមពីនេះបត្យាប័នអាចកើតមានឡើងតែចំពោះបទល្មើសដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងប៉ុណ្ណោះ។

ការធ្វើបត្យាប័ន ត្រូវបានទាមទារនូវការគោរពគោលការណ៍ចម្បងមួយចំនួនដូចជា ការតម្រូវថាបទល្មើសដែលប្រព្រឹត្តនោះ ត្រូវតែជាបទល្មើសដែលមានចែងក្នុងប្រទេសទាំងពីរដែលមានទោសយ៉ាងតិច ១ ឆ្នាំ ឬទោសដែលត្រូវបានអនុវត្តក្នុងពន្ធនាគារនៅសល់ ៦ ខែ។ ទោះបីជាយ៉ាងណាក្តី បទល្មើសមួយចំនួន មិនត្រូវ

[2] សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន, នស/រកម/០៧០០/០៤, ០៩ កុម្ភៈ ១៩៩៩

បានចាត់ទុកជា បទល្មើសដែលអាចធ្វើបត្យាប័នបាននោះទេ ដែលបទល្មើសទាំងនោះមានដូចជា បទល្មើសយោធា ឬ បទល្មើសនយោបាយជាដើម។

## ផ្នែកទី២. ច្បាប់ពាក់ព័ន្ធ

### ១. ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ច្បាប់រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ និងបទដ្ឋានគតិយុត្តដែលស្ថិតនៅតាមឋានានុក្រម ត្រូវតែគោរពតាមច្បាប់រដ្ឋធម្មនុញ្ញជាដាច់ខាតដូច្នេះរាល់ច្បាប់ សន្ធិសញ្ញា អនុសញ្ញា និងសេចក្ដីសម្រេចទាំងឡាយត្រូវតែស្របនឹងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។[3]

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក។[4] បទប្បញ្ញត្តិនេះមានគោលការណ៍ការពារចំពោះជនជាតិខ្មែរគ្រប់រូបក្នុងការមិនត្រូវបានដកសញ្ជាតិ ឬត្រូវចាប់បញ្ជូនខ្លួនទៅឱ្យរដ្ឋបរទេសណាមួយឡើយ ព្រោះជនជាតិខ្មែរគ្រប់រូបត្រូវស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទោះបីជារស់នៅរដ្ឋបរទេសក្តី។

### ២. សន្ធិសញ្ញាស្តីពីការធ្វើបត្យាប័នរបស់អង្គការសហប្រជាជាតិ

សន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ស្ដីពីការធ្វើបត្យាប័ន សម្រាប់ច្បាប់ជាតិ និងកិច្ចព្រមព្រៀងទ្វេភាគីដែលពាក់ព័ន្ធនឹងការធ្វើបត្យាប័ន ព្រមទាំងមានបំណងចែងអំពីប្រទេសដែលមានមូលដ្ឋានបែបនេះ ដើម្បីធានាថាដំណើរការនៃការធ្វើបត្យាប័ន ឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។[5]

### ៣. សន្ធិសញ្ញាអន្តរជាតិ

សន្ធិសញ្ញា គឺជាកិច្ចព្រមព្រៀងអន្តរជាតិរវាងរដ្ឋ និងរដ្ឋ ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរគ្រប់គ្រងដោយច្បាប់អន្តរជាតិ និងធ្វើឡើងដោយលិខិតូបករណ៍តែមួយ ឬ ច្រើនរួមបញ្ចូលគ្នា។ សន្ធិសញ្ញាអន្តរជាតិ អាចកើតឡើងរវាងរដ្ឋ និងរដ្ឋ ឬ រដ្ឋ និងអង្គការអន្តរជាតិ ឬ រវាងអង្គការអន្តរជាតិ និងអង្គការអន្តរជាតិផងដែរ។ សន្ធិសញ្ញាមានពីរប្រភេទ គឺសន្ធិសញ្ញាទូទៅ និងសន្ធិសញ្ញាពិសេស។ សន្ធិសញ្ញាទូទៅ សំដៅដល់សន្ធិសញ្ញាដែលបង្កើតវិធានច្បាប់ ដែលត្រូវអនុវត្តជាសាកល និងបង្កើតជាប្រភពចម្បងនៃនីតិអន្តរជាតិ[6]។ ចំណែកសន្ធិសញ្ញា

[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣, ២៤ កញ្ញា ១៩៩៣, មាត្រា ៥៥

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣, ២៤ កញ្ញា ១៩៩៣, មាត្រា ៣៣

[5] Treaty on Extradition* (Adopted by General Assembly resolution 45/116, subsequently amended by General Assembly resolution 52/88)

[6] នីតិអន្តរជាតិ ជាវិធានទាំងឡាយដែលរដ្ឋទាំងអស់ និងអង្គនីតិបុគ្គលដទៃទៀត ទទួលយកជាចំណងកាតព្វកិច្ចនៅក្នុងសហគមន៍អន្តរជាតិ

ពិសេស សំដៅដល់សន្ធិសញ្ញាដែលប្រៀបបានដូចជាកិច្ចសន្យារវាងរដ្ឋភាគីជាក់លាក់ ដែលការអនុវត្តវិធាននៃសន្ធិសញ្ញានោះត្រូវកម្រិតចំពោះតែរដ្ឋនៃកិច្ចព្រមព្រៀងតែប៉ុណ្ណោះ។[7] ជាក់ស្តែងបត្យាប័នរវាងកម្ពុជា និងចិន ត្រូវបានគេចាត់ទុកថាវាជាប្រភេទសន្ធិសញ្ញាពិសេស។

## ៤. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧

ក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាបែបបទ ឬបច្ចេកទេសនៅក្នុងការប្តឹងផ្តល់ទៅតាមផ្លូវច្បាប់ក្នុងរឿងក្តីព្រហ្មទណ្ឌណាមួយដែលបានកើតឡើងដោយគេបានកំណត់ពីរបៀបស៊ើបសួរ ស៊ើបអង្កេត ការចោទប្រកាន់ជនល្មើស ការស្រាវជ្រាវប្រមូលភស្តុតាង ការចាប់យកវត្ថុតាង ការកំណត់អំពីអត្តសញ្ញាណជនល្មើស ការតាមចាប់ជនល្មើស ព្រមទាំងការផ្តន្ទាទោសជនល្មើសតាមច្បាប់ដែលបានកំណត់។ ម៉្យាងទៀតវាជាវិធាន មួយដែលអ្នកអនុវត្តច្បាប់ទាំងអស់មានកាតព្វកិច្ច ត្រូវតែគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ជៀសវាងឱ្យបាននូវការធ្វេសប្រហែសទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ដើម្បីកំណត់ឱ្យបានច្បាស់លាស់ពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ដែលបានកើតឡើងទៅតាមករណីជាក់ស្តែងនីមួយៗ។ នីតិវិធីនៃការធ្វើបត្យាប័ននៅក្នុងប្រទេសកម្ពុជា គឺត្រូវយកមូលដ្ឋានចម្បងដែលបានបញ្ញត្តិនៅក្នុងក្រមនេះ ក៏ប៉ុន្តែទោះបីជាមានបញ្ញត្តិជាមូលដ្ឋានក៏ដោយ ក៏មិនអាចយកបទប្បញ្ញត្តិនោះមកអនុវត្តបានឡើយ ប្រសិនបើមានបទប្បញ្ញត្តិផ្សេងនៅក្នុងច្បាប់ពិសេស ឬសន្ធិសញ្ញាណាមួយដែលចែងផ្សេងពីបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

## ៥. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩

ក្រមព្រហ្មទណ្ឌ គឺជាបទប្បញ្ញត្តិច្បាប់ដែលចែងអំពីបទល្មើស និងទោសដែលត្រូវអនុវត្តទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ព្រហ្មទណ្ឌ។ បទល្មើសព្រហ្មទណ្ឌ ជាអំពើដែលមានកំណត់នៅក្នុងច្បាប់ព្រហ្មទណ្ឌ ដោយហេតុថាអំពើនេះបង្កចលាចលដល់សង្គម សណ្តាប់ធ្នាប់សាធារណៈ សន្តិភាពសាធារណៈរបស់សង្គម។ ការប្រព្រឹត្តអំពើផ្ទុយនឹងការហាមឃាត់នេះ បង្កើតបានជាបទល្មើសព្រហ្មទណ្ឌដែលត្រូវបានគេធ្វើចំណាត់ថ្នាក់ជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុទៅតាមស្ថានទម្ងន់នៃបទល្មើស។

ក្រមព្រហ្មទណ្ឌមានមុខងារចម្បង ៣ (បី) ធំៗគឺ បង្ក្រាប បង្ការ និងការអប់រំ។ ចំពោះមុខងារបង្ក្រាបសំដៅលើការបង្ក្រាបរាល់អំពើផ្ទុយច្បាប់ព្រហ្មទណ្ឌទាំងអស់ដោយពុំមានការលើកលែងឡើយ។ ចំណែកមុខងារបង្ការ ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ការលើទណ្ឌិត និងសម្រាប់ជនដទៃទៀតដែលមានបំណងប្រព្រឹត្តបទល្មើស ដើម្បីធ្វើឱ្យជនទាំងឡាយ មានការភ័យខ្លាចនឹងទណ្ឌកម្ម ហើយលែងហ៊ានប្រព្រឹត្តអំពើល្មើសតទៅ

[7] Article 38 STATUTE OF THE INTERNATIONAL COURT OF JUSTICE

ទៀត។ ចុងក្រោយបំផុត ក្រមព្រហ្មទណ្ឌបានដើរតួនាទីជាអ្នកធ្វើឱ្យទណ្ឌិតចូលចុះក្នុងសង្គមវិញ តាមរយៈការប្រើប្រាស់វិធានការផ្សេងៗដូចជា យកចិត្តទុកដាក់ដល់ការអប់រំ និងបង្ហាត់បង្រៀនជំនាញវិជ្ជាជីវៈជាដើម។

ក្រមព្រហ្មទណ្ឌត្រូវអនុវត្តទៅលើគ្រប់បទល្មើស និងបុគ្គលជាជនល្មើសទាំងអស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[8] ដែនដីនេះ សំដៅដល់ដែនដីដែលស្ថិតនៅក្រោមអធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា ដោយរួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ។ ក្រៅពីនេះចំពោះបទល្មើសដែលប្រព្រឹត្តនៅក្រៅដែនដីកម្ពុជា ក៏ក្រមព្រហ្មទណ្ឌកម្ពុជាមានសមត្ថកិច្ចអនុវត្តផងដែរដោយឈរលើគោលការណ៍សញ្ជាតិ។ ក្នុងករណីជនរងគ្រោះជាជនជាតិខ្មែរ ឬបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីកម្ពុជាដោយពលរដ្ឋខ្មែរ ទោះបីជាទទួលបានសញ្ជាតិខ្មែរ ក្រោយការប្រព្រឹត្តល្មើសក៏ដោយ ក៏ក្រមនេះអាចយកមកអនុវត្តគ្រប់បទឧក្រិដ្ឋ និងបទមជ្ឈិមបានដែរ ក្នុងករណីដែលបទល្មើសទាំងនេះត្រូវបានផ្តន្ទាទោសដោយច្បាប់នៃរដ្ឋបរទេសនោះផងដែរ។[9] ទាំងនេះគឺជាគោលការណ៍នៃក្រមព្រហ្មទណ្ឌ ហើយវាមានទំនាក់ទំនងទៅនឹងសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ចំពោះការធ្វើបត្យាប័ន។ ក្នុងស្មារតីនៃសន្ធិសញ្ញានេះ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរដោយការដាក់ពន្ធនាគារ ឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំង សម្រាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬការផ្តន្ទាទោសណាមួយដែលធ្ងន់ជាងនេះ។[10]

---

[8] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩, នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១២

[9] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩, នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៩

[10] សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន, នស/រកម/០៧០០/០៤, ០៩ កុម្ភៈ ១៩៩៩, ប្រការទី២ កថាខណ្ឌទី១

# ជំពូកទី២

# លក្ខណៈនៃបត្យាប័ន

# ជំពូកទី២

# លក្ខខណ្ឌនៃបត្យាប័ន

## ផ្នែកទី១. មូលដ្ឋាននៃការធ្វើបត្យាប័ន

នៅក្នុងស្មារតីនៃសន្ធិសញ្ញានេះ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលមានផ្តន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរ ដោយការដាក់ពន្ធនាគារ ឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំង សម្រាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬការផ្តន្ទាទោសណាមួយដែលធ្ងន់ជាងនេះ។[11] ដូចនេះនៅក្នុងនីតិវិធីបត្យាប័ន គឺត្រូវគោរពលក្ខខណ្ឌគ្រឹះជាមូលដ្ឋានដែលមានចែងដូចជា លក្ខខណ្ឌទាក់ទងនឹងបទល្មើស ឬទ្វិកភាពនៃបទល្មើស លក្ខខណ្ឌទាក់ទងនឹងទោសពន្ធនាគារ លក្ខខណ្ឌទាក់ទងនឹងបុគ្គល និងលក្ខខណ្ឌទាក់ទងនឹងនីតិវិធីធ្វើបត្យាប័ន។

### ១. លក្ខខណ្ឌទាក់ទងនឹងបទល្មើស ឬទ្វិកភាពនៃបទល្មើស

បត្យាប័នអាចធ្វើបាន លុះត្រាតែអំពើដែលត្រូវបានចោទប្រកាន់លើបុគ្គលដែលជាកម្មវត្ថុនៃបត្យាប័ន ជាបទល្មើសតាមច្បាប់របស់ភាគីចិនផង និងតាមច្បាប់កម្ពុជាផង ទោះបីជាគុណវុឌ្ឍិន៍នៃបទល្មើសមិនដូចគ្នាក៏ដោយនៅក្នុងច្បាប់នៃរដ្ឋទាំងពីរ។ រាល់បទល្មើសទាំងអស់ដែលអាចធ្វើបត្យាប័នបាន លុះត្រាតែបទល្មើសនោះមានចែងក្នុងច្បាប់នៃប្រទេសភាគីទាំងពីរ ទោះបីអំពីដែលជាបទល្មើសនោះស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នាក្តី ឬឈ្មោះបទល្មើស ឬការប្រើពាក្យបច្ចេកសព្ទ ឬនិយមន័យមិនដូចគ្នាក្តី ឬធាតុផ្សំបទល្មើសនៃច្បាប់របស់ប្រទេសចិន ខុសគ្នាពីធាតុផ្សំបទល្មើសដែលកំណត់ដោយច្បាប់កម្ពុជាក៏ដោយ ប៉ុន្តែប្រសិនបើរដ្ឋទាំងពីរបានកំណត់ថា អំពើល្មើសនេះជាបទល្មើសដែលមានចែងនៅក្នុងបទប្បញ្ញត្តិជាធរមាន នោះអំពើល្មើសនេះអាចជាកម្មវត្ថុនៃការធ្វើបត្យាប័ន។[12] បុគ្គលដែលជាកម្មវត្ថុនៃការធ្វើបត្យាប័ន អាចជាចារី សហចារី ឬជនផ្សំគំនិត ឬការប៉ុនប៉ង ប្រសិនបើបទល្មើសទាំងនេះមានកំណត់នៅក្នុងរដ្ឋធ្វើសំណើ និងរដ្ឋទទួលសំណើ។

### ២. លក្ខខណ្ឌទាក់ទងនឹងទោសពន្ធនាគារ

បទល្មើសដែលអាចធ្វើបត្យាប័នបាន លុះត្រាតែអំពើដែលត្រូវចោទប្រកាន់ទៅលើបុគ្គលដែលគេទាមទារនោះ មានកម្រិតអតិបរមានៃទោសពន្ធនាគារយ៉ាងតិចស្មើនឹង ២ (ពីរ) ឆ្នាំ តាមច្បាប់នៃរដ្ឋធ្វើសំណើ។

---

[11] សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន, នស/រកម/០៧០០/០៤, ០៩ កុម្ភៈ ១៩៩៩, ប្រការទី២ ចំណុច១

[12] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៦៩

តែករណីជនដែលគេទាមទារនេះ ត្រូវបានរដ្ឋធ្វើសំណើបានកាត់ទោសរួចហើយ ដោយសម្រេចទោសជាប់ពន្ធនាគារចាប់ពី ៦ (ប្រាំមួយ) ខែឡើងទៅក៏អាចជាកម្មវត្ថុនៃការធ្វើបត្យាប័នបានដែរ។[13]

ប៉ុន្តែភាពខុសគ្នារវាងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន គឺខុសគ្នាទៅលើអតិបរមានៃទោស ដោយនៅក្នុងសន្ធិសញ្ញានេះបានចែងថា បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលមានផ្តន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរ ដោយការដាក់ពន្ធនាគារ ឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំង សម្រាប់រយៈពេលលើសពី ០១ (មួយ) ឆ្នាំឡើងទៅ ឬការផ្តន្ទាទោសណាមួយដែលធ្ងន់ធ្ងរជាងនេះ។[14] ករណីនេះយើងត្រូវអនុវត្តទៅតាមនីតិវិធីដែលមានចែងនៅក្នុងសន្ធិសញ្ញាដោយយោងតាមមាត្រា ៥៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ៣. លក្ខខណ្ឌទាក់ទងនឹងបុគ្គល

រាល់អំពើល្មើសដែលបានប្រព្រឹត្តនៅក្នុងដែនដីនៃរដ្ឋធ្វើសំណើ ទោះបីជាបុគ្គលដែលជាកម្មវត្ថុនៃបត្យាប័ននោះមិនមែនជាសញ្ជាតិរបស់រដ្ឋធ្វើសំណើក៏ដោយ ក៏រដ្ឋធ្វើសំណើនោះមានសិទ្ធិធ្វើសំណើបត្យាប័នទៅរដ្ឋដែលជននោះកំពុងតែគេចខ្លួននោះបានដែរ។ តែបើបុគ្គលគេទាមទារនោះ ត្រូវបានប្រព្រឹត្តនៅក្រៅដែនដីរដ្ឋធ្វើសំណើ បត្យាប័នអាចធ្វើទៅបាន លុះត្រាតែបុគ្គលដែលគេទាមទារនោះមានសញ្ជាតិរបស់រដ្ឋធ្វើសំណើ។[15]

ជាគោលការណ៍ប្រទេសនីមួយៗ មិនធ្វើបត្យាប័នជាដាច់ខាតទៅលើពលរដ្ឋរបស់ខ្លួនទៅឱ្យរដ្ឋដទៃ។ ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា "ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ។[16] ឧទាហរណ៍៖ ជនជាតិខ្មែរបានប្រព្រឹត្តបទល្មើសនៅប្រទេសចិនហើយបទល្មើសនោះមានអតិបរមានៃទោសពន្ធនាគារ ២ (ពីរ) ឆ្នាំ ជនជាតិខ្មែរនោះបានរត់គេចខ្លួនមកប្រទេសកម្ពុជាវិញ។ ភាគីចិនបានធ្វើសំណើបត្យាប័នមកកម្ពុជា ដើម្បីស្នើសុំឱ្យបញ្ជូនខ្លួនជនជាតិខ្មែរដែលបានប្រព្រឹត្តបទល្មើសនៅប្រទេសចិននោះទៅឱ្យខ្លួនជំនុំជម្រះនៅប្រទេសចិន។ កម្ពុជាមានសិទ្ធិក្នុងការបដិសេធលើសំណើបត្យាប័ននេះ ដោយមូលហេតុថា កម្ពុជាមិនបញ្ជូនជនជាតិខ្លួនទៅឱ្យរដ្ឋបរទេសជាដាច់ខាត។ បន្ថែមពីនេះកម្ពុជាអាចធ្វើសំណើស្នើសុំឱ្យភាគីចិន បញ្ជូនសំណុំរឿង និងភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តីទាំងអស់មកកម្ពុជា ដើម្បីធ្វើការជំនុំជម្រះ។

---

[13] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧១

[14] សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន, នស/រកម/០៧00/0៤, ០៩ កុម្ភៈ ១៩៩៩, ប្រការទី២ ចំណុច១

[15] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧២

[16] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣, ២៤ កញ្ញា ១៩៩៣, មាត្រា ៣៣

គោលការណ៍មូលដ្ឋានដែលអាចបដិសេធមិនធ្វើបត្យាប័នផ្អែកលើទស្សនៈវិស័យខាងមនុស្សធម៌ គេពិនិត្យមើលទៅលើស្ថានភាពបុគ្គល ដោយរដ្ឋបញ្ជូនបុគ្គលដែលគេទាមទារនោះត្រូវតែទទួលបាននូវការធានាមួយថា ជនដែលត្រូវបញ្ជូនទៅឱ្យរដ្ឋធ្វើសំណើនោះ មិនត្រូវបានទទួលទោសប្រហារជីវិតជាដាច់ខាត ប៉ុន្តែច្បាប់កម្ពុជា មិនបានចែងទៅលើចំណុចនេះឱ្យបានច្បាស់លាស់ទេ។ មាត្រា ៥៧៧ បានចែងថា កម្ពុជាតម្រូវឱ្យរដ្ឋធ្វើសំណើធានាថា មិនធ្វើការចោទប្រកាន់ពីបទល្មើសណាមួយផ្សេងក្រៅពីបទល្មើសដែលបានបញ្ជាក់ក្នុងពាក្យស្នើសុំបត្យាប័ន សំដៅលើបទល្មើសទាំងឡាយណា ដែលបានប្រព្រឹត្តមុនពេលចាប់ខ្លួនបុគ្គលដែលគេទាមទារ។ តែបើរដ្ឋធ្វើសំណើចង់ធ្វើការចោទប្រកាន់នោះ ត្រូវធ្វើពាក្យស្នើសុំបន្ថែមមកកម្ពុជា ហើយកម្ពុជាផ្តល់ការយល់ព្រម។

### ៤. លក្ខខណ្ឌទាក់ទងនឹងពាក្យសុំ

បត្យាប័នអាចធ្វើទៅបាន លុះត្រាតែភាគីចិន ឬកម្ពុជាមិនធ្វើការចោទប្រកាន់ពីបទល្មើសណាមួយផ្សេងក្រៅពីបទល្មើសដែលចែងនៅក្នុងពាក្យស្នើសុំឱ្យធ្វើបត្យាប័ននោះទេ ចំពោះបទល្មើសដែលជននោះបានប្រព្រឹត្តនៅមុនពេលត្រូវបានចាប់ខ្លួន។ ការធ្វើបែបដើម្បីការពារផលប្រយោជន៍ជនដែលត្រូវបានស្នើសុំ ក្នុងរូបភាពបង្ការកុំឱ្យមានការបំភាន់ភ្នែក ដោយប្រើមធ្យោបាយនៃការចោទប្រកាន់បទល្មើសផ្សេងក្រោយពេលទទួលបានបុគ្គលនោះ។ ប៉ុន្តែក្នុងករណីរដ្ឋធ្វើសំណើចង់ធ្វើការចោទប្រកាន់បទល្មើសផ្សេង ក្រៅពីបទល្មើសដែលមាននៅក្នុងសំណើពាក្យសុំធ្វើបត្យាប័ន រដ្ឋធ្វើសំណើត្រូវជូនពាក្យស្នើសុំបន្ថែមបទល្មើសមកអាជ្ញាធរនៃរដ្ឋទទួលសំណើ និងមានការយល់ព្រមពីរដ្ឋទទួលសំណើទើបការចោទប្រកាន់បទល្មើសបន្ថែមនេះអាចប្រព្រឹត្តទៅបាន។[17]

ប្រសិនបើសំណើបត្យាប័នចំពោះតែជនម្នាក់ត្រូវបានធ្វើឡើងដោយភាគីចុះកិច្ចព្រមព្រៀងណាមួយ និងពីរដ្ឋដទៃផ្សេងមួយ ឬច្រើនផ្សេងទៀតផងនោះ ភាគីទទួលសំណើអាចកំណត់អំពីអាទិភាពចំពោះសំណើណាមួយក្នុងចំណោមសំណើបត្យាប័នទាំងនោះ។ កម្ពុជាអាចធ្វើការពិចារណាគ្រប់ស្ថានភាពដូចខាងក្រោម៖[18]

#### ៤.១. ភាពធ្ងន់ធ្ងរនៃបទល្មើស

ត្រូវពិនិត្យមើលលក្ខខណ្ឌមូលហេតុមួយចំនួនដែលជះឥទ្ធិពលដល់ការការពារសិទ្ធិមនុស្ស។ ដូចករណីបញ្ជូនជនដែលគេទាមទារទៅទទួលទោសប្រហារជីវិត ដូច្នេះសន្ធិសញ្ញាអាចទាមទារឱ្យមានការសុំធានាកុំឱ្យអនុវត្តទោសប្រហារជីវិតដោយសារស្ថានភាពមុនសម្លាប់ ឬវិធីសម្លាប់អាចជាអំពើអមនុស្សធម៌ដែលបំពានច្បាប់សិទ្ធិមនុស្ស។ អនុសញ្ញាស្តីពីការប្រឆាំងនឹងអំពើទារុណកម្មមាត្រា ៣ ហាមមិនឱ្យធ្វើបត្យាប័ន ប្រសិនបើជន

[17] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧៧

[18] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧៦

នោះនឹងទទួលរងគ្រោះដោយសារអំពើទារុណកម្មក្រោយពេលបញ្ជូនខ្លួនទៅ។ ទាក់ទងទៅនឹងដំណើរការធ្វើបត្យាប័ន វាក៏ទាមទារនូវការគោរពសិទ្ធិមនុស្ស និងអធិបតេយ្យភាពរបស់រដ្ឋផងដែរ។

**ឧទាហរណ៍៖** តុលាការនៅប្រទេសដាណឺម៉ាកបានបដិសេធមិនឱ្យរដ្ឋាភិបាលធ្វើបត្យាប័នចាប់បញ្ជូនឈ្មួញជួញដូរអាវុធម្នាក់ទៅឱ្យឥណ្ឌា។ ប្រទេសឥណ្ឌាបានទាមទារឱ្យរដ្ឋាភិបាលដាណឺម៉ាកធ្វើបត្យាប័នជនជាតិដាណឺម៉ាក លោក Niels Holck ដែលអាជ្ញាធរឥណ្ឌាចោទប្រកាន់ថា ជាមេខ្លោងជួញដូរអាវុធខុសច្បាប់ទៅឱ្យក្រុមឧទ្ទាម នៅប៉ែកខាងលិចបង់ហ្គាល់កាលពីឆ្នាំ ១៩៩៥។ តុលាការដាណឺម៉ាកនៅស្រុក Hillerod ប៉ែកភាគខាងជើងរដ្ឋធានី Copenhagen បានពន្យល់ថា រដ្ឋាភិបាលមិនអាចធ្វើបត្យាប័ន លោក Niels Holck ក្នុងហេតុផល ខ្លាចថា គាត់អាចត្រូវគេរំលោភសិទ្ធិនៅពេលទៅដល់ប្រទេសឥណ្ឌា។ នៅមុនការសម្រេចរបស់តុលាការនៅថ្ងៃព្រហស្បតិ៍ ព្រះរាជអាជ្ញាដាណឺម៉ាកធ្លាប់បានយល់ព្រមបើកភ្លើងខៀវឱ្យរដ្ឋាភិបាលធ្វើបត្យាប័នលោក Niels Holck ទៅឥណ្ឌា ដែលចង់បើកសវនាការជំនុំជម្រះ លោក Niels Holck ផ្ទាល់នៅក្នុងបទចោទប្រកាន់ ជាមេខ្លោងដឹកនាំអាវុធទៅឱ្យក្រុមឧទ្ទាមនៅភាគខាងកើតបង់ហ្គាល់ក្នុងប្រទេសឥណ្ឌា។ តុលាការដាណឺម៉ាក ក៏ធ្លាប់ទទួលស្គាល់ថា លោក Niels Holck ធ្លាប់បានចូលរួមនៅក្នុងការដឹកនាំអាវុធទៅឱ្យចលនា Ananda Marga ដែលត្រូវការសព្វាវុធ ដើម្បីប្រយុទ្ធតតាំងនឹងទាហានរបស់ថ្នាក់ដឹកនាំកុម្មុយនីស្តនៅបង់ហ្គាល់នៅជំនាន់នោះ។ លោក Niels Holck ត្រូវប៉ូលិសដាណឺម៉ាកចាប់ខ្លួននៅឆ្នាំ ២០១០ បន្ទាប់ពីរដ្ឋាភិបាលចរចាយល់ព្រមធ្វើបត្យាប័នទៅឥណ្ឌាតាមការចង់បានញូវដេលី។ ប៉ុន្តែ មួយឆ្នាំក្រោយ តុលាការក្នុងស្រុកបានចេញសាលក្រមបដិសេធមិនឱ្យគេធ្វើបត្យាប័នបញ្ជូនលោក Niels Holck ទៅឥណ្ឌា។ នៅឆ្នាំ ២០១៦ ឥណ្ឌាបានទាមទារការធ្វើបត្យាប័នជាលើកទី២ និងបានសន្យាធានាថា នៅក្នុងពេលអនុវត្តនីតិវិធីតុលាការនៅឥណ្ឌា លោក Niels Holck នឹងត្រូវបញ្ជូនទៅដាក់ក្នុងផ្ទះពិសេសមួយ ដែលមានតែលោក Niels Holck ម្នាក់ឯងដែលមានប៉ូលិសដាណឺម៉ាកនៅតាមយាមផ្ទាល់។ ប៉ុន្តែយោងតាមតុលាការដាណឺម៉ាកក្នុងទីក្រុង Hillerod បន្ទាប់ពីពិនិត្យស៊ីជម្រៅសំណុំរឿងនេះ ទោះបីជាមានការធានាពីភាគីឥណ្ឌា តុលាការនៅតែយល់ថា ការធ្វើបត្យាប័នលោក Niels Holck ទៅឥណ្ឌា គឺរំលោភមាត្រា ៣ នៃច្បាប់សិទ្ធិមនុស្សរបស់អឺរ៉ុបដែលបានចែងហាមមិនឱ្យធ្វើទារុណកម្មដាក់ពិន័យ ធ្វើបាបអ្នកទោសនៅក្នុងពន្ធនាគារ។[19]

[19] ដកស្រង់ចេញពីគេហទំព័រ RFI, រាយការណ៍៖ ឈាង បុប្ផា ចេញផ្សាយថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤

### ៤.២. ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តិបទល្មើស

ពិនិត្យមើលទៅលើពេលវេលា និងទីកន្លែងដែលបុគ្គលដែលគេទាមទារនោះបានប្រព្រឹត្ត ដើម្បីរដ្ឋទទួលសំណើងាយស្រួលក្នុងការកំណត់អាទិភាពចំពោះសំណើណាមួយ ក្នុងចំណោមសំណើបត្យាប័នដែលមានច្រើនរដ្ឋស្នើសុំលើបុគ្គលតែម្នាក់។

### ៤.៣. កាលបរិច្ឆេទ និងលំដាប់មកដល់នៃសំណើស្នើសុំ

រដ្ឋទទួលសំណើអាចផ្តល់អាទិភាពធ្វើបត្យាប័ននេះទៅរដ្ឋណាដែលបានដាក់បត្យាប័នមកមុន និងមានលក្ខខណ្ឌគ្រប់គ្រាន់ទៅតាមច្បាប់កំណត់។

ឧទាហរណ៍៖ លោក ក ជាជនជាតិថៃបានប្រព្រឹត្តបទល្មើសនៅប្រទេសចិនហើយបានរត់គេចខ្លួនមកកម្ពុជា។ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ ភាគីចិនបានធ្វើសំណើបត្យាប័នមកកម្ពុជា ដើម្បីស្នើសុំឱ្យចាប់ខ្លួនលើបុគ្គលដែលបាន ប្រពឹត្តបទល្មើសលើដែនដីនៃប្រទេសចិន។ ហើយនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ ភាគីថៃក៏បានធ្វើសំណើបត្យាប័នកម្ពុជាដូចគ្នាដែរ។ ចំពោះករណីនេះកម្ពុជាអាចពិចារណាលើកាលបរិច្ឆេទនៃលំដាប់មកដល់នៃសំណើបត្យាប័នដែលបានស្នើសុំ។

### ៤.៤. សញ្ជាតិ លំនៅឋាន ទីសំណាក់នៃបុគ្គលដែលគេទាមទារ និងជនរងគ្រោះ

រដ្ឋទទួលសំណើអាចពិនិត្យមើលទៅលើសញ្ជាតិ លំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលគេទាមទារ ឬជនរងគ្រោះ ដើម្បីយកមកធ្វើការពិចារណាក្នុងការផ្តល់អាទិភាពទៅកាន់រដ្ឋភាគីដែលដាក់សំណើ។

### ៤.៥. លទ្ធភាពប្រគល់មកវិញនូវបុគ្គលដែលគេទាមទាររបស់រដ្ឋធ្វើសំណើ

រដ្ឋទទួលសំណើក៏ត្រូវពិនិត្យមើលផងដែរចំពោះលទ្ធភាពក្នុងការប្រគល់មកវិញ ចំពោះបុគ្គលដែលខ្លួនបាន បញ្ជូនទៅឱ្យរដ្ឋធ្វើសំណើ ប្រសិនបើមានភាពមិនប្រក្រតីណាមួយបានកើតឡើងចំពោះបុគ្គលដែលគេទាមទារនោះ។ ត្រង់ចំណុចនេះនៅមិនទាន់មានមូលដ្ឋានក្នុងការកំណត់ជាក់លាក់ចំពោះរដ្ឋធ្វើសំណើថាមានលទ្ធភាព ឬមិនមានលទ្ធភាពចំពោះបុគ្គលដែលរដ្ឋធ្វើសំណើបានបញ្ជូនទៅហើយ។ម្យ៉ាងវិញទៀត ការអនុវត្តជាក់ស្តែងបច្ចុប្បន្ន ក៏មិនឃើញមានករណីបែបនេះកើតឡើងដែរ។

## ផ្នែកទី២. មូលដ្ឋានបដិសេធនៃការធ្វើបត្យាប័ន

ការធ្វើបត្យាប័នកម្ពុជា និងចិន ត្រូវគោរពតាមសន្ធិសញ្ញាទ្វេភាគីបញ្ជាក់អំពីលក្ខខណ្ឌ និងនីតិវិធីធ្វើបត្យាប័នឧក្រិដ្ឋជនដែលត្រូវបានចោទប្រកាន់នៅក្នុងប្រទេសទាំងពីរ។ ទោះបីជាច្បាប់អន្តរជាតិ មិនបានផ្តល់កាតព្វកិច្ចឱ្យរដ្ឋធ្វើបត្យាប័នក៏ដោយ ក៏សន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការធ្វើបត្យាប័ន (សន្ធិសញ្ញា

របស់ អ.ស.ប) បានចែងអំពីកិច្ចព្រមព្រៀងទ្វេភាគីដែលពាក់ព័ន្ធនឹងការធ្វើបត្យាប័ន ព្រមទាំងមានបំណងចែងអំពីប្រទេសដែលមានមូលដ្ឋានបែបនេះ ដើម្បីធានាថាដំណើរការនៃការធ្វើបត្យាប័ន ឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។ ការធ្វើបត្យាប័នមិនត្រូវបានអនុញ្ញាត ប្រសិនបើបុគ្គលដែលត្រូវបានស្នើសុំឱ្យធ្វើបត្យាប័នអាចពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម ហើយការធ្វើបត្យាប័នអាចនឹងត្រូវបានបដិសេធ ប្រសិនបើរដ្ឋទទួលសំណើចាត់ទុកថាបទល្មើសស្នើសុំឱ្យមានការធ្វើបត្យាប័ន មានពាក់ព័ន្ធនឹងបទល្មើសនឹងនយោបាយ។ រដ្ឋទទួលសំណើត្រូវបដិសេធសំណើសុំធ្វើបត្យាប័ន ប្រសិនបើរដ្ឋដែលធ្វើការស្នើសុំមានការកាត់ទោសប្រហារជីវិតចំពោះបទល្មើស លុះត្រាតែមានការធានាថានឹងមិនមានការអនុវត្តការកាត់ទោសប្រហារជីវិត។

## ១. មូលដ្ឋានជាច់ខាត

### ១.១. បទល្មើសនយោបាយ

តាមក្រមនីតិវិធីព្រហ្មទណ្ឌបត្យាប័នមិនត្រូវបានអនុញ្ញាតចំពោះបទល្មើសមានលក្ខណៈនយោបាយ លើសពីនេះតាមច្បាប់សារធាតុក៏គ្មានចែងអំពីបទល្មើសនយោបាយនោះដែរ ហេតុនេះជាការសមហេតុផលចំពោះអំពើដែលត្រូវចោទប្រកាន់មានលក្ខណៈនយោបាយមិនត្រូវបានអនុញ្ញាតឱ្យធ្វើបត្យាប័ន។ ប៉ុន្តែអំពើហិង្សាដែលធ្វើឱ្យគ្រោះថ្នាក់ដល់អាយុជីវិត បូរណភាពរូបរាងកាយ ឬដល់សេរីភាពបុគ្គលមិនមែនជាបទល្មើសនយោបាយទេ ក្នុងករណីនេះបត្យាប័នត្រូវតែអនុញ្ញាត ប៉ុន្តែតម្រូវឱ្យរដ្ឋធ្វើសំណើផ្តល់ភស្តុតាងផ្ទុយដើម្បីបញ្ជាក់ថា អំពើដែលត្រូវបានចោទប្រកាន់ មិនមែនជាបទល្មើសមានលក្ខណៈនយោបាយនោះទេ តែជាបទល្មើសនៃនីតិរួមដើម្បីឱ្យកម្ពុជាអាចធ្វើបត្យាប័នបាន។

ម្យ៉ាងវិញទៀត តាមសន្ធិសញ្ញាបត្យាប័នកម្ពុជា និងចិន នឹងមិនអនុញ្ញាតឱ្យធ្វើបានឡើយ ក្នុងករណីភាគីទទួលសំណើយល់ឃើញថា បទល្មើសដែលជាកម្មវត្ថុនៃបត្យាប័ន ជាបទល្មើសនយោបាយ លើកលែងតែបទល្មើសការធ្វើឃាត ឬប៉ុនប៉ងធ្វើឃាត ឬការបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល ឬសមាជិកគ្រួសារនៃវីរជនទាំងនោះ។

**ឧទាហរណ៍៖** បន្ទាប់ពីមានសំណើជាផ្លូវការពីភាគីថៃ ប្រទេសកម្ពុជាបានបដិសេធមិនធ្វើបត្យាប័នលោក ថាក់ស៊ីន ស៊ីណាវ៉ាត់ត្រា។ រដ្ឋាភិបាលកម្ពុជាបានច្រានចោលសំណើជាផ្លូវការរបស់រដ្ឋាភិបាលថៃដែលបានស្នើសុំធ្វើបត្យាប័នលោក ថាក់ស៊ីន ស៊ីណាវ៉ាត់ត្រា ទៅកាន់ប្រទេសថៃ ដោយចាត់ទុកលោក ថាក់ស៊ីន ជាជនរងគ្រោះផ្នែកនយោបាយតាមរយៈលោក Chalothorn Phaovibul ភារធារីស្ថានទូតថៃប្រចាំប្រទេសកម្ពុជា បានដាក់លិខិតមួយច្បាប់ស្តីពីការសុំធ្វើបត្យាប័នលោក ថាក់ស៊ីន ស៊ីណាវ៉ាត់ ទៅកាន់ប្រទេសថៃវិញ ក្រោយពីលោកថាក់ស៊ីនបានមកដល់ប្រទេសកម្ពុជា ដើម្បីបំពេញតួនាទីរបស់លោកជាទីប្រឹក្សារដ្ឋាភិបាលទទួលបន្ទុក

សេដ្ឋកិច្ច និងជាទីប្រឹក្សារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងប្រាប់ទូរទស្សន៍ជាតិ និង អន្តរជាតិហើយត្រូវបានទូរទស្សន៍ជាតិកម្ពុជាចាក់ផ្សាយនៅថ្ងៃពុធ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ថា កម្ពុជាមិនធ្វើបត្យាប័នលោកថាក់ស៊ីនទៅកាន់ប្រទេសថៃវិញទេ។ "ឥឡូវហ្នឹងប្រហែលជាបានលិខិតហ្នឹងហើយ គឺថា បញ្ជូនត្រឡប់ទៅវិញនូវលិខិតបដិសេធរបស់យើងអំពីការមិនបញ្ជូន"។ នៅក្នុងលិខិតជាផ្លូវការរបស់ក្រសួងការបរទេសកម្ពុជា ឆ្លើយតបទៅនឹងលិខិតកំណត់ការទូតរបស់ក្រសួងការបរទេសថៃ ដែល VOA សំឡេងសហរដ្ឋអាមេរិកទទួលបាននៅថ្ងៃពុធនេះ បានបញ្ជាក់ថា យោងតាមមាត្រា ៣ នៃសន្ធិសញ្ញាបត្យាប័នរវាងប្រទេសកម្ពុជា និង ប្រទេសថៃ រដ្ឋាភិបាលកម្ពុជាបានចាត់ទុកការកាត់ទោសលោកថាក់ស៊ីន ស៊ីណាវ៉ាត់ និង ដំណើរការច្បាប់ប្រឆាំងនឹងគាត់ គឺ ជាការប្រព្រឹត្តទៅដោយមូលហេតុនយោបាយ។ នៅក្នុងលិខិតដដែលបានបញ្ជាក់ទៀតថា ដោយយោងទៅលើភាពជាក់ស្តែងយ៉ាងច្បាស់លាស់ដូចខាងលើនេះហើយ ទើបរដ្ឋាភិបាលកម្ពុជាមិនអាចចាប់ខ្លួនជាបណ្តោះអាសន្ន ឬក៏ធ្វើបត្យាប័នលោកថាក់ស៊ីនស៊ីណាវ៉ាត់បានទេ។[20]

### ១.២. ការប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង

ប្រសិនបើភាគីទទួលសំណើមានមូលដ្ឋានច្បាស់លាស់ ដើម្បីសន្និដ្ឋានថាសំណើបត្យាប័នធ្វើឡើងដោយភាគីដាក់សំណើ មានគោលបំណងប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង ឬអនុវត្តទណ្ឌកម្មទៅលើបុគ្គល ដែលត្រូវចោទប្តឹងដោយមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ ឬទស្សនៈនយោបាយរបស់បុគ្គលនោះ ឬជំហររបស់ជនដែលត្រូវចោទប្តឹងក្នុងរឿងក្តីនោះ ត្រូវបានគេចាត់ទុកថាបានធ្វើឱ្យប៉ះពាល់ការសំអាងដែលពោលខាងលើ។ ក្នុងផ្នែកនេះអាចមានច្រើនករណីទៅតាមស្ថានភាពនីមួយៗ ដែលកម្ពុជាអាចបដិសេធសំណើសុំធ្វើបត្យាប័នរបស់រដ្ឋបរទេសណាមួយបាន។  ជាឧទាហរណ៍៖ ប្រសិនបើក្រឡេកមើលទៅលើការដាក់ទោសទណ្ឌតាមច្បាប់ប្រទេសមួយចំនួននៅលើសាកលលោកឃើញថា ទណ្ឌកម្មតាមច្បាប់ព្រហ្មទណ្ឌរបស់ពួកគេមានលក្ខណៈកាចសាហាវ យោរយៅ និងព្រៃផ្សៃ ដូចជាទោសប្រហារជីវិត (ចង់ក ដុតសម្លាប់ទាំងរស់ ធ្វើអត្តឃាតដោយខ្លួនឯង) ធ្វើទារុណកម្ម (ការវាយដំយ៉ាងធ្ងន់ធ្ងរ) ជាដើម។ ដោយឡែកតាមច្បាប់នៃប្រទេសកម្ពុជា ទោះបីជានីតិព្រហ្មទណ្ឌមានមុខងារចម្បងគឺ ដើម្បីបង្ក្រាបរាល់បទល្មើស និងបង្ការបទល្មើសក្នុងសង្គម ប៉ុន្តែទណ្ឌកម្មព្រហ្មទណ្ឌពុំមានលក្ខណៈកាចសាហាវដូចប្រទេសមួយចំនួននោះទេ។

ផ្អែកតាមគោលការណ៍មនុស្សធម៌នៃនីតិព្រហ្មទណ្ឌកម្ពុជា ការដាក់ទណ្ឌកម្មទៅលើជនល្មើសគឺ ពុំមានគោលបំណងបង្កឱ្យមានការឈឺចាប់លើរូបរាងកាយ ឬបន្ទាបបន្ថោកកេរ្តិ៍ឈ្មោះ ឬកិត្តិយសរបស់ជនល្មើស

[20] ដកស្រង់ចេញពីគេហទំព័រ VOA រាយការណ៍ដោយ៖ លោក ហេង រស្មី ចេញផ្សាយថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩

ឡើយ។ ផ្ទុយទៅវិញក្នុងគោលបំណងអប់រំជនល្មើសឱ្យប្រែក្លាយជាពលរដ្ឋល្អ ជាសមាជិកបរិសុទ្ធដែលធ្វើឱ្យប្រយោជន៍ដល់សង្គមជាតិ។

ហេតុដូច្នេះ ក្នុងករណីដែលរដ្ឋបរទេសបានស្នើសុំឱ្យកម្ពុជាធ្វើបត្យាប័នបុគ្គលដែលគេទាមទារក្នុងគោលបំណងប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង នោះប្រទេសកម្ពុជាអាចបដិសេធនូវសំណើសុំធ្វើបត្យាប័នរបស់រដ្ឋបរទេសនោះបាន។[21]

### ១.៣. បទល្មើសយោធា

រាល់អំពើទាំងឡាយណាដែលមានសកម្មភាពជាបទល្មើសយោធាដែលប្រព្រឹត្តឡើងដោយយោធិន ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ មិនអាចជាកម្មវត្ថុនៃសំណើបត្យាប័នបានឡើយ។

បទល្មើសយោធា សំដៅទៅលើបទល្មើសដែលប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ព ហើយដែលពាក់ព័ន្ធទៅនឹងវិន័យកងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ។ តុលាការដែលមានសមត្ថកិច្ចជំនុំជម្រះលើបទល្មើសយោធា គឺតុលាការយោធាមានទីតាំងនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ តុលាការយោធា ជាសាលាជម្រះក្តីជាន់ទាប មានថ្នាក់ស្មើនឹងសាលាដំបូងដែលមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលទាក់ទងទៅនឹងបទល្មើសមានលក្ខណៈយោធា ឬបទល្មើសប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធដែលបានប្រព្រឹត្តដោយសមាជិកយោធិន។ តុលាការយោធាមានគោលបំណង គឺគ្រាន់តែបម្រើឱ្យតម្រូវការវិន័យជាក់លាក់ តឹងរ៉ឹងនៃវិស័យយោធា រួមទាំងរឹតបន្តឹងទៅលើបទល្មើសទាក់ទងទាំងស្រុងដល់ផលប្រយោជន៍នៃសណ្តាប់ធ្នាប់យោធាដែលត្រូវការពារតាមផ្លូវច្បាប់ ដូចជាការរត់ចោលជួរទៅខាងខ្មាំង ភាពរឹងរូស ឬការបោះបង់ចោលតួនាទី ឬបញ្ហាជាដើម។ ប៉ុន្តែក្នុងករណីយោធិនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌសាមញ្ញ ត្រូវស្ថិតក្រោមដែនសមត្ថកិច្ចរបស់តុលាការខេត្តក្រុងជំនុំជម្រះ។[22]

- ការបែកចែករវាងបទល្មើសយោធា និងបទល្មើសសាមញ្ញ

ជាគោលការណ៍ បទល្មើសភាគច្រើនត្រូវបានចាត់ទុកជាបទល្មើសសាមញ្ញ ដោយហេតុថា បទល្មើសទាំងនោះត្រូវស្ថិតនៅក្រោមវិធានទូទៅ រួមបញ្ចូលទាំង វិធានជាច្បាប់សារធាតុ និងទាំងវិធានជាច្បាប់នីតិវិធី។

---

[21] អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប, លេខ ៣៩/៤៦, ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤, មាត្រា ៣ កថាខណ្ឌទី១

[22] ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា, ប្រកាសឱ្យប្រើដោយក្រុមប្រឹក្សារដ្ឋលេខ ០៦ ក្រ, ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣, មាត្រា ៩

យ៉ាងណាមិញ បទល្មើសយោធាគឺជាបទល្មើសពិសេស ហើយត្រូវបានច្បាប់ឱ្យនិយមន័យដោយឡែក។ ជាក់ស្តែង ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ត្រង់មាត្រា ៩ បាន កំណត់និយមន័យបទល្មើសយោធាថា ជាបទល្មើសដែលប្រព្រឹត្តដោយយោធិន នៅក្នុងជួរកងទ័ព ហើយដែលពាក់ព័ន្ធនឹងវិន័យកងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិ របស់កងកម្លាំងប្រដាប់អាវុធ ។ ម្យ៉ាងវិញទៀត មាត្រា ១១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ក៏បានឱ្យនិយមន័យប្រហាក់ប្រហែលគ្នានេះដែរ ដោយគ្រាន់តែបាន បញ្ជាក់បន្ថែមពីប្រភេទនៃយោធិន ដែលអាចជាប់ទាក់ទងនឹងបទល្មើសយោធា តែប៉ុណ្ណោះ។ បទប្បញ្ញត្តិខាងលើបានចែងថា  បទល្មើសយោធាជាបទល្មើសដែលទាក់ទិនដល់យោធិន ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ហើយដែលពាក់ព័ន្ធដល់បទវិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា។[23]

ហេតុនេះ រាល់បទល្មើសទាំងឡាយដែលបានប្រព្រឹត្តដោយយោធិន គឺពុំមែនសុទ្ធតែជាបទល្មើសយោធាទេ ពីព្រោះថាតាមខ្លឹមសារនៃមាត្រា ១១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលកំណត់ថា៖ បទល្មើសនឹងច្បាប់សាមញ្ញប្រព្រឹត្តដោយយោធិន ពុំត្រូវចាត់ចូលជាបទល្មើសយោធាឡើយ ។ ជាសរុបមក លក្ខណៈពិសេសរបស់បទល្មើសយោធា បើប្រៀបធៀបទៅនឹងបទល្មើសសាមញ្ញ រួមមានដូចខាងក្រោម៖

- ប្រធាននៃបទល្មើស គឺយោធិន។
- អំពើល្មើស គឺទាក់ទងនឹងវិន័យកងទ័ព ឬទ្រព្យសម្បត្តិរបស់កងទ័ព។

ម្យ៉ាងទៀត មុនពេលដែលច្បាប់ព្រហ្មទណ្ឌអន្តរកាលចូលជាធរមាន គេឃើញមាន ក្រឹត្យច្បាប់លេខ ០៤ ស្តីពីបទល្មើសមានលក្ខណៈយោធា និងទណ្ឌកម្ម ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៨១ ដែលបានធ្វើនិយ័តកម្ម (ដែលបញ្ញត្តិ) លើបទល្មើសយោធា។ ជាក់ស្តែង ក្រឹត្យច្បាប់នេះបានរៀបរាប់យ៉ាងពិស្តារពីប្រភេទនីមួយៗនៃបទល្មើសយោធាមានដូចតទៅ៖

- បទល្មើសប៉ះពាល់ដល់កម្លាំងប្រយុទ្ធ និង បទបញ្ជានៃបរិចារកិច្ចយោធា[24] ត្រូវទទួលទោសយ៉ាងសមរម្យតាមសមធម៌។
- បទល្មើសប្រឆាំងនឹងបញ្ជារបស់ថ្នាក់លើត្រូវទទួលទោសគុកពី ៦ ខែ ទៅ ៣ ឆ្នាំ ឬលើសពីនេះ គឺរហូតដល់ ១០ឆ្នាំ ឬ២០ឆ្នាំ ទៅតាមទម្ងន់ នៃផលអំពើ ក្នុងករណីប្រឆាំងក្នុងពេលប្រយុទ្ធ។

---

[23] ច្បាប់ព្រហ្មទណ្ឌអន្តរកាល ១៩៩២, សម្រេចដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់, ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២, មាត្រា ១១

[24] បរិចារកិច្ចយោធា សំដៅលើការបម្រើយោធា ឬកិច្ចការជាបន្ទុកយោធា

- ការចុះចូលខ្មាំងត្រូវទទួលទោសគុកពី ២ឆ្នាំ ទៅ ៥ឆ្នាំ បើយកអាវុធ និងឯកសារសំខាន់ទៅជាមួយផង ទោសគុកអាចឡើងដល់ ២០ឆ្នាំ ឬ អស់មួយជីវិត។
- ការលួចលក់ ឬជួយក្នុងការលាក់អាវុធ ឬបរិក្ខារយោធាត្រូវទទួល ទោសគុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ក្នុងករណីដែលធ្ងន់ធ្ងររហូតដល់ ១០ឆ្នាំ។ ការគំរាមកំហែងភ្នាក់ងាររដ្ឋបាល (មន្ត្រីទទួលបន្ទុកកិច្ចការរដ្ឋបាល ដូចជាកិច្ចការលេខាធិការដ្ឋាន ឬ ការងារការិយាល័យ ជាដើម) កុំឱ្យ គេបំពេញករណីយកិច្ចរបស់គេបាន ត្រូវទទួលទោសគុកពី ៦ខែ ទៅ ៣ឆ្នាំ។
- ការឃោសនាបំបាក់បំបែកកងទ័ព ត្រូវទទួលទោសគុកពី ៦ ខែ រហូត ដល់ ៣ ឆ្នាំ។
- ការវាយដំ និងធ្វើឱ្យមានរបួសផ្លូវកាយដល់អ្នកនៅក្រោមបង្គាប់ ឬ ថ្នាក់លើត្រូវទទួលទោសគុកពី ៦ ខែ រហូតដល់ ៣ឆ្នាំ។
- ធ្វើឱ្យបែកការសម្ងាត់ ឬ ធ្វើឱ្យបាត់បង់ឯកសារសម្ងាត់ដោយការ ធ្វេសប្រហែស ត្រូវទទួលទោសគុកពី ៦ ខែ រហូតដល់ ៣ឆ្នាំ។
- ការធ្វេសប្រហែសក្នុងករណីយកិច្ចដែលនាំឱ្យមានការខូចខាតធ្ងន់ធ្ងរ ត្រូវទទួលទោសគុកពី ៦ ខែ រហូតដល់ ៣ឆ្នាំ ឬបើខូចខាតធ្ងន់ធ្ងរ ជាពិសេសត្រូវរងទោសគុករហូតដល់ ១០ ឆ្នាំ។
- ការគេចវេសពីបរិចារកិច្ចយោធា[25] (ត្រូវទទួលទោសគុកពី ៦ ខែ ដល់ ៣ ឆ្នាំ ឬ រហូតដល់ ៥ឆ្នាំ បើជំរុញគេឱ្យរត់ចោលជួរ ឬរត់ចោលទ័ពដោយ មានអាវុធទៅជាមួយ។

ដូច្នេះ ឃើញថាយោធិនដែលបានរត់ចោលជួរ គឺជាយោធិនដែលបានប្រព្រឹត្តល្មើសទៅនឹងវិន័យកងទ័ព។ ចំណែកឯយោធិនដែលបានលួចទ្រព្យ ឬ បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិយោធា ក៏ត្រូវចាត់ទុកជាជនដែលបានប្រព្រឹត្តបទល្មើសយោធាផងដែរ។ ផ្ទុយទៅវិញ ប្រសិនបើយោធិនបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ របស់ជនស៊ីវិលវិញ គឺគេមិនចាត់ទុកជាបទល្មើសយោធាទេ តែជាបទល្មើសសាមញ្ញទៅវិញ។

សរុបជារួមមក ការបែងចែករវាងបទល្មើសសាមញ្ញ និងបទល្មើសយោធាមានសារៈប្រយោជន៍ត្រង់ថា៖ បទល្មើសទាំងពីរ គឺមិនត្រូវស្ថិតនៅក្រោមសមត្ថកិច្ចតុលាការដូចគ្នាទេ។ ត្រង់ចំណុចនេះបានន័យថា ចំពោះបទល្មើសយោធា តុលាការយោធាត្រូវមានសមត្ថកិច្ចក្នុងការជំនុំជម្រះ ចំណែកឯបទល្មើសសាមញ្ញវិញ គឺត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងរាជធានីខេត្ត។ ក្រៅពីនេះ គេពុំឃើញមានលក្ខណៈពិសេសអ្វីផ្សេងទៀត

[25] បរិចារកិច្ចយោធា សំដៅលើការគេចវេះពីការបម្រើយោធា ឬកិច្ចការជាបន្ទុកយោធា

ទេ ពីព្រោះថានីតិវិធីជំនុំជម្រះនៅក្នុងតុលាការយោធា គឺដូចគ្នាទាំងស្រុងទៅនឹងនីតិវិធីជំនុំជម្រះនៅសាលាដំបូងរាជធានីខេត្តដែរ។[26]

ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងតុលាការយោធា និងសាលាដំបូង សាលាឧទ្ធរណ៍ភ្នំពេញត្រូវសម្រេចអំពីសមត្ថកិច្ចនេះ តាមបណ្ដឹងសុំរបស់តំណាងអយ្យការ ឬតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។ សាលក្រមរបស់តុលាការយោធាបើកសិទ្ធិប្ដឹងឧទ្ធរណ៍ ទៅសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចដែនដី ដោយអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន។ ការប្ដឹងសាទុក្ខនឹងសាលដីការបស់សាលាឧទ្ធរណ៍ ទៅតុលាការកំពូល ត្រូវអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន។

### ១.៤. អាជ្ញាយុកាល

ការចោទប្រកាន់ ឬការអនុវត្តការដាក់ទណ្ឌកម្មចំពោះបទល្មើសណាមួយ ដែលកម្មវត្ថុរបស់បត្យាប័នត្រូវបានរាំងស្ទះដោយមូលហេតុមានចែងក្នុងច្បាប់នៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ដោយរាប់បញ្ចូលទាំងការពិចារណាលើអាជ្ញាយុកាលនៃបទល្មើសដែលជននោះបានប្រព្រឹត្តផងដែរ។ អាជ្ញាយុកាល គឺជារយៈពេលមួយដែលបានកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ បុគ្គលម្នាក់អាចនឹងបាត់បង់សិទ្ធិណាមួយរបស់ខ្លួន ឬអាចទាមទារសិទ្ធិណាមួយជាប្រយោជន៍របស់ខ្លួន។ យ៉ាងណាមិញ ក្នុងច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាយុកាលត្រូវបានបែងចែកចេញជា ០២ (ពីរ) ប្រភេទគឺ៖ អាជ្ញាយុកាលនៃបទល្មើស (ឬអាចហៅម្យ៉ាងទៀតថាជាអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា) និង អាជ្ញាយុកាលនៃទោស។

#### ១.៤.១. អាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា

ជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់បានទេ ឬ និយាយម្យ៉ាងទៀតថា ព្រះរាជអាជ្ញាពុំអាចធ្វើបណ្ដឹងអាជ្ញាបានឡើយ។ តាមពិតអាជ្ញាយុកាលអាចប្រែប្រួលទៅតាមប្រភេទនីមួយៗនៃបទល្មើស ប៉ុន្តែលើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់៖ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម) នៃក្រមនេះ ចិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាមានដូចតទៅគឺ៖

- ១៥ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ឆ្នាំ ចំពោះបទមជ្ឈិម

[26] ច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្ដីនៃរដ្ឋកម្ពុជា, ប្រកាសឱ្យប្រើដោយក្រុមប្រឹក្សារដ្ឋលេខ ០៦ ក្រ, ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣, មាត្រា ៩

- ១ឆ្នាំ ចំពោះបទលហុ។[27]

ជាគោលការណ៍ អាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាចាប់ផ្តើមរាប់ចាប់ពីពេលប្រព្រឹត្តបទល្មើសតទៅ។ ដូចបានកំណត់នៅក្នុងច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ឃើញថា បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម និងបទល្មើសដែលមានបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្មមិនអាចផុតអាជ្ញាយុកាលបាននោះទេ។[28]

### ១.៤.២.អាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោសជា រយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ទោសមិនអាចយកទៅអនុវត្តបានទៀតឡើយ។ ជាក់ស្តែង ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់រយៈពេលអាជ្ញាយុកាលនៃទោសដូចតទៅ[29]៖

- ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ឆ្នាំ
- ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ឆ្នាំ
- ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ឆ្នាំ។

ហេតុដូច្នេះ ថិរវេលាខាងលើនេះ គឺត្រូវចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសដោយតុលាការបានចូលជាស្ថាពរ។

ទន្ទឹមនឹងការធ្វើបត្យាប័នបាន តាមការចែងពីក្រមនីតិវិធីព្រហ្មទណ្ឌក៏មានករណីមួយចំនួនដែលមិនអាចឱ្យដំណើរការបត្យាប័នផងដែរ។ ការហាមឃាត់មិនឱ្យធ្វើបត្យាប័ននោះមានដូចជា៖

- ករណីដែលជនជាកម្មវត្ថុនៃការធ្វើបត្យាប័ន ត្រូវបានតុលាការនៃប្រទេសស្នើសុំផ្តន្ទាទោសជាស្ថាពររួចហើយ ឬកំពុងស្ថិតនៅក្នុងនីតិវិធីនៃច្បាប់
- បណ្តឹងអាជ្ញាត្រូវផុតរលត់ដោយមូលហេតុដូចខាងក្រោម[30]៖

[27] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០

[28] ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម, នស/រកម/០៧០៧/០១៨, ២០ កក្កដា ២០០៧, មាត្រា ៩

[29] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩, នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៤៤

[30] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៧

### ១.៤.៣. មរណភាពនៃជនល្មើស

កាលណាជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន ឬ ជនល្មើស ដែលកំពុងស្ថិតនៅក្នុងនីតិវិធីនៃបណ្តឹងអាជ្ញា តែជននោះបានទទួលមរណភាព នោះបណ្តឹងអាជ្ញាដែលជាប់ពាក់ព័ន្ធជននោះនឹងត្រូវរលត់ដោយមិនអាចចាប់ផ្តើមចោទប្រកាន់បានទៀតឡើយ ហើយទោះបីមានការចោទប្រកាន់រួចរាល់ហើយក៏ដោយ ក៏ការចោទប្រកាន់នោះត្រូវតែបញ្ឈប់ ឬ បញ្ចប់ដែរ ព្រោះនេះជាការគោរពគោលការណ៍ចំពោះមុខរបស់ភាគីក្នុងរឿងក្តីព្រហ្មទណ្ឌ និងគោរពផលប្រយោជន៍នៃគោលបំណងនៃការដាក់ទោសព្រហ្មទណ្ឌទៅលើជនល្មើស ដែលអប់រំកែប្រែចូលរស់នៅក្នុងសង្គមវិញ លែងមានភាពចាំបាច់ទៀតហើយ។

### ១.៤.៤. ការផុតអាជ្ញាយុកាល

អាជ្ញាយុកាលនៃបទល្មើស ឬ បណ្តឹងអាជ្ញា គឺជាថិរវេលាកំណត់មួយដែលចែងក្នុងច្បាប់ អំពីរយៈពេលដែលអាចធ្វើបណ្តឹងអាជ្ញាចំពោះបទល្មើសណាមួយបាន។ ការផុតអាជ្ញាយុកាលនៃបទល្មើសនាំឱ្យបណ្តឹងត្រូវផុតរលត់។ អាជ្ញាយុកាលនៃបទល្មើស ខុសគ្នាទៅតាមកម្រិតនៃប្រភេទបទល្មើសនីមួយៗដូចខាងក្រោម៖

- បទល្មើសគ្មានអាជ្ញាយុកាលកំណត់ ដូចជា បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម។
- រយៈពេល ១៥ ឆ្នាំ ចំពោះបទឧក្រិដ្ឋ (បទល្មើសមានលក្ខណៈធ្ងន់ធ្ងរ)
- រយៈពេល ០៥ ឆ្នាំ ចំពោះបទមជ្ឈិម (បទល្មើសមានលក្ខណៈកណ្តាល ឬ មធ្យម)
- រយៈពេល ០១ ឆ្នាំ ចំពោះបទលហុ (បទល្មើសមានលក្ខណៈស្រាល ឬ តូចតាច)។

### ១.៤.៥. ការលើកលែងទោសទូទៅ

ការលើកលែងទោសជាទូទៅ គឺជាវិធានការនីតិកម្មដែលមានគោលដៅលុបចោលនូវលក្ខណៈជាបទល្មើសនៃអំពើមួយចំនួន។ តាមពិត ការលើកលែងទោសជាទូទៅ គឺត្រូវស្ថិតក្នុងអំណាចរបស់អង្គការនីតិបញ្ញត្តិ[31] ជាទូទៅត្រូវតែកំណត់ពីដែនអនុវត្តរបស់ខ្លួនឱ្យច្បាស់លាស់។ ជាធម្មតាច្បាប់ស្តីពីលើកលែងទោសជាទូទៅអាចអនុម័តបាន ដោយសារតែមានមូលហេតុច្រើនយ៉ាងដូចជា៖ ដើម្បីកុំឱ្យមានចំនួនទណ្ឌិតក្នុងពន្ធនាគារច្រើនពេក ឬក្នុងឱកាសហេតុការណ៍សំខាន់ណាមួយ ទន្ទឹមនឹងនេះ ច្បាប់ស្តីពីការលើកលែងទោសជាទូទៅរមែងកំណត់យ៉ាងច្បាស់លាស់ពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើស ដែលត្រូវលើកលែង ឬពីប្រភេទនៃបទល្មើសត្រូវលើកលែងទោស ឬ ក៏ពីទោសប្រកាសប្រភេទណាមួយដែលនឹងត្រូវទទួលបាននូវការលើកលែង។ ឧទាហរណ៍៖ ច្បាប់ស្តីពីការលើកលែងទោសជាទូទៅអាចបញ្ញត្តិថា៖ ទណ្ឌិតដែលទទួលរងនូវការផ្តន្ទាទោសដោយតុលាការពី

[31] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣, ២៤ កញ្ញា ១៩៩៣, មាត្រា ៩០ថ្មី (ពីរ)

៣ខែ ដល់ ៣ឆ្នាំ ទទួល បានការលើកលែងទោសជាទូទៅ។ នៅក្នុងករណីដែលមានការលើកលែងទោសជាទូទៅរួចហើយ ទោសមិនអាចយកមកអនុវត្តបានទេ ហើយទោសដែលកំពុងអនុវត្តត្រូវបានបញ្ចប់។ ក៏ប៉ុន្តែចំពោះប្រាក់ពិន័យ និង ប្រាក់ប្រដាប់ក្ដីដែលបានបង់រួចហើយមិនអាចទារសំណងពីរដ្ឋវិញបានទេ។ លើសពីនេះទៅទៀត ការលើកលែងទោសជាទូទៅមិនមែនជាឧបសគ្គដល់ការអនុវត្តសិទ្ធិរបស់ជនរងគ្រោះក្នុងការទាមទារដើម្បីទទួលបានសំណង សម្រាប់ជួសជុលការខូចខាតឡើយ លើកលែងតែករណីដែលច្បាប់ស្ដីពីការលើកលែងទោសជាទូទៅបានចែងផ្ទុយពីនេះទៅវិញ។[32] ជាពិសេសជាងនេះទៅទៀត ដោយសារតែការលើកលែងទោសជាទូទៅ ការផ្ដន្ទាទោសដែលត្រូវបានលុបលាងនឹងត្រូវបានដកចេញពីបញ្ជីថ្កោលទោស។[33]

### ១.៤.៦. និរាករណ៍ច្បាប់ព្រហ្មទណ្ឌ

កាលណាច្បាប់ព្រហ្មទណ្ឌណាមួយត្រូវបាននិរាករណ៍ (លុបចោល) នោះបទល្មើសដែលចែងក្នុងច្បាប់ព្រហ្មទណ្ឌនោះ ក៏ត្រូវលុបចោលដែរ ហើយមិនអាចធ្វើបណ្ដឹងអាជ្ញា ឬ ការចោទប្រកាន់បានឡើយ។ ទោះបីជាមានការចោទប្រកាន់ក៏ដោយក៏បណ្ដឹងអាជ្ញាអាចត្រូវបានរលត់ផងដែរ ប្រសិនបើបទល្មើសនោះត្រូវបាននិរាករណ៍ ពោលគឺអំពើដែលបានប្រព្រឹត្តដោយជនល្មើសនោះ លែងត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌតទៅទៀត។

### ១.៤.៧. អាជ្ញាអស់ជំនុំ

មានន័យថា ជនណាដែលត្រូវបានតុលាការសម្រេចផ្ដន្ទាទោសជាស្ថាពរ ឬ សម្រេចឱ្យរួចខ្លួនជាស្ថាពរ ឬ ត្រូវបានលើកលែងទោសស្របតាមច្បាប់ និង នីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗ ជននោះមិនអាចត្រូវបានចោទប្រកាន់ទៀតទេ ចំពោះបទល្មើសដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។

### ១.៥. អានុភាពសាលក្រមចេញដោយរដ្ឋទទួលសំណើ

ភាគីទទួលសំណើ បានចេញសាលក្រមកាត់ទោសជនដែលត្រូវស្នើសុំ ចំពោះបទល្មើសដដែលនេះរួចហើយ មុនពេលដាក់សំណើសុំធ្វើបត្យាប័ន។ បានន័យថាប្រសិនបើជនដែលជាកម្មវត្ថុស្នើសុំត្រូវបានរដ្ឋទទួលសំណើបាន ដំណើរការនីតិវិធីដល់ដំណាក់កាលចេញសាលក្រមហើយ ហើយស្រាប់តែមានសំណើបត្យាប័ននៅពេលក្រោយនោះ គឺរដ្ឋទទួលសំណើមិនអាចផ្ដល់បត្យាប័នឱ្យបានឡើយ។

---

[32] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩, នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៥១

[33] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៤២

### ១.៦. សាលក្រមកំបាំងមុខរបស់ភាគីដាក់សំណើ

ប្រសិនបើសាលក្រមកំបាំងមុខរបស់ភាគីដាក់សំណើបានត្រូវធ្វើឡើងដោយកំបាំងមុខដោយជនជាប់ទោស[34]ពុំបានទទួលព័ត៌មានគ្រប់គ្រាន់ អំពីសវនាការកាត់ក្តីនេះ ឬគ្មានឱកាសចាត់ចែង ការការពារក្តីរបស់ខ្លួន ឬគ្មានឱកាសដើម្បីឱ្យសំណុំរឿងក្តីរបស់ខ្លួនបានត្រូវជំនុំជម្រះឡើងវិញដោយមានវត្តមានរបស់ខ្លួន។

ច្បាប់កម្ពុជាបានកំណត់សម្គាល់លើសាលក្រមកំបាំងមុខ ក្នុងករណីប្រសិនបើជនជាប់ចោទមិនបានចូលមកបង្ហាញខ្លួននៅពេលសវនាការទេ ប្រសិនបើគ្មានភស្តុតាងបង្ហាញឱ្យឃើញថា សាមីខ្លួនដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះ ឬ បានដឹងអំពីការកោះហៅនោះទេ សាលក្រមនឹងត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទ ហើយសាលក្រមនេះអាចប្តឹងឧទ្ធរណ៍បាន តាមការកំណត់របស់ច្បាប់។

ករណីមួយទៀត បើដើមបណ្តឹងរដ្ឋប្បវេណី ចូលបង្ហាញខ្លួននៅពេលសវនាការ ឬមានអ្នកតំណាងដោយត្រឹមត្រូវនោះសាលក្រមត្រូវតែជាសាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីនេះ។ សាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវជូនដំណឹងដល់សាមីខ្លួនទេ សាលក្រមនេះ អាចប្តឹងឧទ្ធរណ៍បានតាមការកំណត់ដោយច្បាប់។ ស្រដៀងគ្នានេះដែរ ប្រសិនបើបុគ្គលដែលកោះហៅនៅក្នុងឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចូលមកបង្ហាញខ្លួន នៅពេលសវនាការ ឬមានអ្នកតំណាងដោយត្រឹមត្រូវ សាលក្រមនេះ ជាសាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមចំពោះមុខ នេះមិនត្រូវឱ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ តែសាលក្រមនេះអាចប្តឹងឧទ្ធរណ៍បាន។

ផ្ទុយទៅវិញបើបុគ្គលកោះហៅក្នុងឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនចូលបង្ហាញខ្លួនពេលសវនាការ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ សាលក្រមត្រូវសម្រេចដោយកំបាំងមុខ។ សាលក្រមកំបាំងមុខនេះនឹងត្រូវឱ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ហើយក៏អាចមានសិទ្ធិប្តឹងទាស់នឹងសាលក្រមនោះបានដែរ។

### ២. មូលដ្ឋានបដិសេធដោយឆន្ទានុសិទ្ធិ

ពេលខ្លះរដ្ឋទទួលសំណើទទួលបាននូវលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការបញ្ជូនបត្យាប័ន តែគាត់អាចបដិសេធមិនព្រមធ្វើបត្យាប័នបាន ដូចករណីខាងក្រោម៖

[34] សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/0៧00/0៤, ចុះថ្ងៃទី0៩ ខែកុម្ភៈ ឆ្នាំ១៩៩៩, ប្រការទី៣ កថាខណ្ឌទី៦

### ២.១. មូលដ្ឋានច្បាប់របស់ភាគីទទួលសំណើ

យោងតាមច្បាប់របស់ខ្លួន ភាគីទទួលសំណើមានសមត្ថកិច្ចលើបទល្មើសដែលជាកម្មវត្ថុនៃសំណើបត្យាប័ន។ ដូចនេះអាជ្ញាធរដែលមានសមត្ថកិច្ចរបស់រដ្ឋទទួលសំណើនេះ ត្រូវរៀបចំនីតិវិធីជំនុំជម្រះក្តីលើជនដែលត្រូវរដ្ឋមួយទៀតស្នើសុំបត្យាប័ន។ រដ្ឋទទួលសំណើ កំពុងដំណើរការនីតិវិធីជំនុំជម្រះក្តីជនដែលជាកម្មវត្ថុនៃសំណើបត្យាប័នរបស់ភាគីម្ខាងទៀត ចំពោះបទល្មើសដដែល។

ប្រសិនបើបុគ្គលដែលត្រូវស្នើសុំឱ្យធ្វើបត្យាប័ន ត្រូវបានកាត់ទោស ឬក៏នឹងត្រូវចូលសវនាការ ឬកាត់ទោសនៅក្នុងទឹកដីនៃភាគីដាក់សំណើ ដោយតុលាការ ឬសាលាជម្រះក្តីពិសេស ឬបណ្តោះអាសន្នណាមួយ។

### ២.២. គោលការណ៍គាំពារមនុស្សធម៌

ក្នុងដំណើរការធ្វើបត្យាប័ន វាក៏ទាមទារនូវការគោរពសិទ្ធិមនុស្ស និងអធិបតេយ្យភាពរបស់រដ្ឋផងដែរ។ រដ្ឋធ្វើសំណើមិនត្រូវចោទប្រកាន់ជនល្មើស ក្រៅពីបទល្មើសដែលមានចែងក្នុងសំណើបត្យាប័ននោះទេ ប៉ុន្តែប្រសិនបើចង់ធ្វើការចោទប្រកាន់លើបទល្មើសផ្សេងពីក្នុងសំណើបត្យាប័ននេះ ត្រូវធ្វើលិខិតស្នើសុំបន្ថែម និងត្រូវមានការយល់ព្រមពីរដ្ឋបញ្ជូនជាមុន។

ភាគីចុះកិច្ចព្រមព្រៀងម្ខាងៗ មានសិទ្ធិបដិសេធការធ្វើបត្យាប័នពលរដ្ឋផ្ទាល់របស់ខ្លួន។ ទោះបីជារដ្ឋមិនបញ្ជូនជនដែលជាកម្មវត្ថុនៃបត្យាប័នទៅឱ្យរដ្ឋដាក់សំណើក៏ដោយ ក៏ពុំមានន័យថាជននោះត្រូវរួចផុតពីសំណាញ់ច្បាប់ដែរ។ ភាគីទទួលសំណើត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ទៅតាមសំណូមពររបស់ភាគីដាក់សំណើ។ ក្នុងករណីនេះ ភាគីដាក់សំណើត្រូវបញ្ជូនឯកសារ និងភស្តុតាងដែលទាក់ទងនឹងបណ្តឹងក្តីនេះទៅភាគីទទួលសំណើ។ ប៉ុន្តែក្នុងករណីភាគីទទួលសំណើគ្មានយុត្តាធិការលើបទល្មើសនេះទេ ភាគីទទួលសំណើពុំចាំបាច់បញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនដើម្បីចោទប្រកាន់ទេ។[35]

---

[35] សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន, នស/រកម/០៧០០/០៤, ០៩ កុម្ភៈ ១៩៩៩, ប្រការទី៥

# ជំពូកទី៣
# នីតិវិធីបត្យាប័ន

# ជំពូកទី៣

# នីតិវិធីបត្យាប័ន

## ផ្នែកទី១. ព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើ

### ១. ការត្រួតពិនិត្យនីតិវិធីរដ្ឋបាល

ពាក្យស្នើសុំធ្វើបត្យាប័នត្រូវមានការបញ្ជាក់អំពីភាពត្រឹមត្រូវចំពោះពាក្យស្នើសុំ គ្រប់ពាក្យសុំធ្វើបត្យាប័នត្រូវដាក់ជូនរដ្ឋាភិបាលកម្ពុជាតាមផ្លូវទូត ផ្លូវទូតនេះសំដៅទៅក្រសួងការបរទេសរបស់ព្រះរាជាណាចក្រកម្ពុជា។ ពាក្យសុំនេះត្រូវមានលិខិតបញ្ជាក់ភស្តុតាងអមមកជាមួយផងដែរ។[36]

ពាក្យស្នើសុំនេះត្រូវភ្ជាប់ទៅជាមួយនូវឯកសារចាំបាច់ផ្សេងៗដូចជា៖

- លិខិតបញ្ជាក់អង្គហេតុ ដែលរំលោភច្បាប់របស់ភាគីចិនដែលស្នើសុំបត្យាប័ន ឯកសារសេចក្ដីបញ្ជាក់ ឬព័ត៌មានផ្សេងៗដែលពិពណ៌នាអំពីអត្តសញ្ញាណ ប្រសិនបើមានរួមបញ្ចូលទាំងការពិពណ៌នាអំពីប្រវត្តិរូបសង្ខេប រូបថត ឬស្នាមមេដៃ សញ្ជាតិ និងទីកន្លែងស្នាក់នៅប្រហាក់ប្រហែលរបស់ជនដែលត្រូវស្នើសុំធ្វើបត្យាប័ន។
- ការភ្ជាប់អត្ថបទច្បាប់ ដែលជននោះរំលោភបំពានមកជាមួយផង ដោយមានគូសសម្គាល់អត្ថបទដែលពាក់ព័ន្ធ ព្រមទាំងពិពណ៌នាការជាប់ពាក់ព័ន្ធនឹងអង្គហេតុនៃសំណុំរឿង គិតទាំងពេលវេលា និងទីកន្លែងប្រព្រឹត្តបទល្មើស និងប្រវត្តិនីតិវិធីនៃសំណុំរឿង។
- សេចក្ដីបញ្ជាក់អំពីច្បាប់ ដែលពិពណ៌នាអំពីការដាក់ទណ្ឌកម្ម ចំពោះបទល្មើស។
- សេចក្ដីបញ្ជាក់អំពីច្បាប់ ដែលពិពណ៌នាអំពីការកំណត់ពេលនៃការចោទប្រកាន់ ឬអនុវត្តទណ្ឌកម្មចំពោះបទល្មើស។
- សេចក្ដីចម្លងដីកាចាប់ខ្លួន ឬដីកាឃុំខ្លួនចេញដោយចៅក្រម ឬអាជ្ញាធរតុលាការមានសមត្ថកិច្ចរបស់ភាគីចិន។
- លិខិតបញ្ជាក់ថា បុគ្គលដែលស្នើសុំបត្យាប័នមានដីកាចាប់ខ្លួន ឬដីកាឃុំខ្លួន។
- ឯកសារបញ្ជាក់អំពីអំពើ ឬការខកខានដែលត្រូវចោទប្រកាន់ បង្កើតបានជាបទល្មើស និងភស្តុតាងគាំទ្រ ដែលអាចផ្ដល់នូវមូលដ្ឋានត្រឹមត្រូវ ក្នុងការវាយតម្លៃថាបុគ្គលពាក់ព័ន្ធមានសច្ចធារណ៍នៃការប្រព្រឹត្តបទល្មើសនេះ។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧៩

- បើបុគ្គលដែលត្រូវស្នើសុំបត្យាប័ន ត្រូវបានបញ្ជាក់ច្បាស់ថា មានពិរុទ្ធភាព សំណើត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងសាលក្រម ឬសាលដីកាដែលកំណត់ពិរុទ្ធភាពពាក់ព័ន្ធនឹងបុគ្គលនេះ ព្រមទាំងសេចក្តីចម្លងដីកាចាប់ខ្លួន ឬសេចក្តីចម្លងដីកាឃុំខ្លួន។ បើសេចក្តីចម្លងសាលក្រម ឬសាលដីកាដែលកំណត់ពិរុទ្ធភាពសម្រេចឡើងដោយកំបាំងមុខជនដែលត្រូវគេស្នើសុំធ្វើបត្យាប័នត្រូវមានក្នុងសេចក្តីសម្រេចនោះ បញ្ជាក់ថាកំបាំងមុខផងដែរ។

រាល់ឯកសារទាំងអស់ត្រូវចុះហត្ថលេខា បោះត្រាជាផ្លូវការ និងបិទស្រោម ហើយប្រសិនបើមិនមែនជាភាសាខ្មែរ ចិន ឬអង់គ្លេស ត្រូវតែភ្ជាប់មកជាមួយនូវឯកសារបកប្រែជាភាសាណាមួយនៃភាសាទាំងបីនេះ ដោយមានសេចក្តីបញ្ជាក់ផង។

ក្នុងករណីសំណុំឯកសារមានការខ្វះខាត មិនគ្រប់គ្រាន់ ភាគីកម្ពុជាអាចស្នើឱ្យភាគីចិនដែលដាក់សំណើផ្តល់ឯកសារបន្ថែម ដោយមានកំណត់ឱសានវាទនៃការប្រគល់ឯកសារ។ បើភាគីចិនមិនបានគោរពការកំណត់នេះទេ គាត់អាចចរចាជាមួយភាគីកម្ពុជា ដើម្បីពន្យារពេល ឬក៏បោះបង់ការស្នើសុំ តែភាគីចិននៅតែមានសិទ្ធិដាក់ពាក្យស្នើសុំជាថ្មីឡើងវិញផងដែរ។ បើគាត់បោះបង់បុគ្គលពាក់ព័ន្ធនោះក៏ត្រូវដោះលែងឱ្យមានសេរីភាពឡើងវិញដែរ ដោយផ្តល់ព័ត៌មាននេះឱ្យបានឆាប់ទៅភាគីចិន។

## ២. ការដំណើរនីតិវិធីដំណាក់កាលស្ថាប័នមហាអយ្យការអមសាលាឧទ្ធរណ៍

បន្ទាប់ពីក្រសួងការបរទេសកម្ពុជា បានពិនិត្យលើពាក្យស្នើសុំបត្យាប័ននឹងបានបញ្ជាក់ថាត្រឹមត្រូវលើពាក្យស្នើសុំបត្យាប័នរួចហើយអស់ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាត្រូវបញ្ជូនពាក្យសុំឱ្យធ្វើបត្យាប័ន និងលិខិតបញ្ជាក់ភស្តុតាងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវធ្វើការផ្ទៀងផ្ទាត់មើលនិយ័តភាពនៃពាក្យសុំ និងបញ្ជូនពាក្យនោះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍រាជធានីភ្នំពេញ។

ប្រសិនបើមានករណីបន្ទាន់ដោយខ្លាចបុគ្គលដែលជាកម្មវត្ថុនៃការធ្វើបត្យាប័ននោះរត់គេចខ្លួន ខាងភាគីចិនអាចធ្វើពាក្យស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជា ធ្វើការចាប់ឃុំខ្លួនបណ្តោះអាសន្នលើបុគ្គលដែលត្រូវសុំឱ្យធ្វើបត្យាប័នជូនកាលអាចមានការធ្វើមុនពេលសុំបត្យាប័នទៅទៀត។ ពាក្យសុំឱ្យចាប់ខ្លួនបណ្តោះអាសន្នដែលមានគោលដៅរារាំងការគេចខ្លួនបុគ្គលដែលគេទាមទារ មិនតម្រូវឱ្យគោរពទម្រង់បែបបទដោយឡែកឡើយ។[37] ប៉ុន្តែលិខិតនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមផ្លូវការទូត ហើយសំណើនេះត្រូវមានការពិពណ៌នាជនដែលត្រូវស្នើសុំដូចជា៖

[37] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨១

- ព័ត៌មានអំពីសញ្ជាតិនៃបុគ្គលនោះ
- សេចក្តីបញ្ជាក់ទីកន្លែងដែលជននោះស្ថិតនៅ (ប្រសិនបើដឹង)
- សេចក្តីបញ្ជាក់អំពីអង្គហេតុនៃសំណុំរឿង
- សេចក្តីបញ្ជាក់ការពិពណ៌នាអំពីច្បាប់ដែលបានរំលោភ
- សេចក្តីបញ្ជាក់អំពីដីកាចាប់ខ្លួន ឬសាលក្រម ឬសាលដីកានៃការកាត់ទោសលើជននោះ

ហើយសេចក្តីបញ្ជាក់អំពីសំណើបត្យាប័ន លើជនដែលត្រូវស្នើសុំនឹងត្រូវបញ្ជូនតាមក្រោយ។ ក្នុងរយៈពេល ២ខែគិតចាប់ពីថ្ងៃចាប់ខ្លួន ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចនៃភាគីកម្ពុជា មិនបានទទួលសំណើបត្យាប័នជាផ្លូវការ និងឯកសារសំអាងនានាអមមកជាមួយនោះទេ ការចាប់ខ្លួនបណ្តោះអាសន្ននឹងត្រូវបញ្ចប់សុពលភាព ហើយបុគ្គលនោះនឹងត្រូវដោះលែងឱ្យមានសេរីភាពឡើងវិញ។[38] ប៉ុន្តែការដោះលែងនេះក៏អនុញ្ញាតឱ្យមានការចាប់ខ្លួនឡើងវិញដែរឱ្យតែសំណើបត្យាប័នត្រូវបានដាក់ឡើងវិញ ដោយមានឯកសារសម្អាងនានាមានលក្ខណៈគ្រប់គ្រាន់។ ការបញ្ជាឱ្យចាប់ខ្លួន និងឃុំខ្លួនបុគ្គលដែលគេទាមទារ ត្រូវធ្វើឡើងដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍រាជធានីភ្នំពេញ។[39] ក្រោយពីចាប់ខ្លួនបានហើយ បុគ្គលដែលគេទាមទារនោះ ត្រូវនាំទៅបង្ហាញខ្លួននៅមុខព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីមុននឹងត្រូវបញ្ជូនខ្លួនមកអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍រាជធានីភ្នំពេញ ដើម្បីឃុំខ្លួននៅពន្ធនាគារភ្នំពេញ ហើយបុគ្គលនោះអាចមានសិទ្ធិស្នើសុំឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញស្តាប់ចម្លើយរបស់ខ្លួន។[40]

### ២.១. នីតិវិធីចេញដីកាបង្គាប់ឱ្យចាប់ខ្លួន

ក្នុងករណីបន្ទាន់ដោយខ្លាចបុគ្គលដែលជាកម្មវត្ថុនៃការធ្វើបត្យាប័ននោះរត់គេចខ្លួន ភាគីចិនអាចធ្វើពាក្យស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើការចាប់ឃុំខ្លួនបណ្តោះអាសន្នលើបុគ្គលដែលត្រូវសុំឱ្យធ្វើបត្យាប័ន។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នៅភ្នំពេញ អាចចេញបញ្ជាឱ្យចាប់ និងឃុំខ្លួនបុគ្គលដែលជាកម្មវត្ថុនៃបត្យាប័ន។ បញ្ជានេះមានចុះនិទ្ទេសដូចតទៅ៖[41]

- អត្តសញ្ញាណបុគ្គលដែលគេទាមទារ
- ការយោងនៃពាក្យសុំឱ្យចាប់ខ្លួនជាបណ្តោះអាសន្នរបស់រដ្ឋបរទេស

[38] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨១ កថាខណ្ឌទី៣

[39] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨២

[40] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨៣

[41] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨២

- ឈ្មោះ និងឋានៈរបស់អគ្គព្រះរាជអាជ្ញាដែលចេញបញ្ជានេះ។

បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយអគ្គព្រះរាជអាជ្ញា និងមានបោះត្រាផង។

ប៉ុន្តែប្រសិនបើយើងមើលអំពីសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរវិញ ចៅក្រមស៊ើបសួរក៏មានអំណាចក្នុងការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន[42] ដែលមានសមត្ថកិច្ចបញ្ជាដល់កងកម្លាំងប្រដាប់អាវុធឱ្យស្រាវជ្រាវចាប់ និងនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ម្យ៉ាងវិញទៀតក៏ជាការបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួលឃុំខ្លួនបុគ្គលនោះផងដែរ។ ដីកាបង្គាប់ឱ្យចាប់ខ្លួន អាចចេញលើជនត្រូវចោទ ឬ បុគ្គលណាដែលមានតម្រុយពិរុទ្ធភាព។ ករណីនេះលក្ខខណ្ឌដែលចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបានលុះត្រាតែ[43]៖

- បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ
- បុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួន មិនដឹងស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរ ត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញា ហើយចៅក្រមស៊ើបសួរត្រូវចេញដីកានេះ ដោយមានមូលហេតុច្បាស់លាស់។ ក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញាហើយ ចៅក្រមស៊ើបសួរ ត្រូវធានារ៉ាប់រងនូវការផ្សព្វផ្សាយ ដីកាបង្គាប់ឱ្យចាប់ខ្លួននេះ រីឯនិទ្ទេសដែលមានចុះក្នុងដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវចុះនូវព័ត៌មានដូចខាងក្រោម[44]៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ព្រមទាំងមានបោះត្រាផងដែរ។

សរុបជារួមមក អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ ជាអ្នកមានសមត្ថកិច្ចក្នុងការចេញបញ្ជាឱ្យចាប់ និង ឃុំខ្លួនបុគ្គលដែលគេបានទាមទារនោះ។ ចំពោះសមត្ថកិច្ចត្រង់ចំណុចនេះ គឺមិនមានការរំលោភលើ

---

[42] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៩៥

[43] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៩៦

[44] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១៩៨

ដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនោះទេ ព្រោះថានៅក្នុងក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់អំពីស្ថាប័នដែលមានអំណាចអាចចេញបញ្ជាឱ្យចាប់ និងឃុំខ្លួនជនដែលជាកម្មវត្ថុនៃបត្យាប័ន គឺជាសមត្ថកិច្ចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចំពោះតែរឿងដែលពាក់ព័ន្ធនឹងបត្យាប័នតែប៉ុណ្ណោះ។

ចំណែកឯចៅក្រមស៊ើបសួរក៏មានអំណាចក្នុងការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន និង នាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ដីកាបង្គាប់ឱ្យចាប់ខ្លួនដែលចេញដោយចៅក្រមស៊ើបសួរ អាចចេញលើជនត្រូវចោទ ឬបុគ្គលណាដែលមានតម្រុយពិរុទ្ធភាព និងត្រូវបានបំពេញលក្ខខណ្ឌទាំងពីរនេះ គឺបទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងបុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ទាល់តែលក្ខខណ្ឌខាងលើនេះត្រូវបានបំពេញទើបចៅក្រមស៊ើបសួរគាត់អាចធ្វើការចេញដីបង្គាប់ឱ្យចាប់ខ្លួនបាន។

### ២.២. ការឃុំខ្លួនបណ្តោះអាសន្ន

ជាទូទៅដីកាបង្គាប់ឱ្យឃុំខ្លួនជាអំណាចរបស់ចៅក្រមស៊ើបសួរ ដែលមានសិទ្ធិបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួលឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរអាចចេញដីកាឃុំខ្លួននេះ លុះត្រាតែជនត្រូវចោទ ជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន។ ខ្លឹមសារនេះ ហាក់ដូចជាហាមឃាត់មិនឱ្យជនត្រូវចោទមានសេរីភាពក្នុងការដើរហើរ ព្រោះជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាព។ ប៉ុន្តែក្នុងករណីពិសេសជនត្រូវចោទ អាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នបាន នេះជាបញ្ញត្តិដែលចែងអំពី អំណាចរបស់ចៅក្រមស៊ើបសួរ។

ប៉ុន្តែចំពោះនីតិវិធីបត្យាប័នបានផ្តល់សិទ្ធិក្នុងការឃុំខ្លួនបណ្តោះអាសន្នលើជនដែលជាកម្មវត្ថុនៃបត្យាប័នទៅឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។ ករណីចាប់ខ្លួនបុគ្គលដែលគេទាមទារ ត្រូវតែនាំទៅបង្ហាញខ្លួនក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី ដែលត្រូវឱ្យដំណឹងដល់បុគ្គលនោះអំពីបញ្ជាឱ្យចាប់ និងឃុំខ្លួន ហើយនិងទទួលចម្លើយពីបុគ្គលនោះ។ បុគ្គលដែលគេទាមទារត្រូវផ្ទេរមកឃុំខ្លួននៅពន្ធនាគារភ្នំពេញ។ បុគ្គលនោះមានសិទ្ធិស្នើសុំឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញស្តាប់ចម្លើយខ្លួន។[45]

[45] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨៣

ទន្ទឹមនឹងនេះ នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏បានចែងថា មិនមែនគ្រប់ជនត្រូវចោទសុទ្ធតែត្រូវបានឃុំខ្លួនបណ្ដោះអាសន្នបានឡើយ។ មានន័យថា ការឃុំខ្លួនបណ្ដោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ មជ្ឈិម កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើស ១ឆ្នាំប៉ុណ្ណោះ។[46]

### ២.២.១. មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្នអាចបណ្ដាលមកពីមូលហេតុជាច្រើនដូចជា[47]៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី
- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និង អ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស។

### ២.២.២. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន (ច្បាប់កម្ពុជា)

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នកំណត់ដូចខាងក្រោម៖

- **<u>ចំពោះអនីតិជន</u>**

ជាគោលការណ៍ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នមានភាពខុសគ្នារវាងអនីតិជននិងនីតិជន។ ចំពោះអនីតិជនមានអាយុតិចជាង ១៤ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្នទេ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះទៅឳពុកម្ដាយ ឬអាណាព្យាបាល បើគ្មានអាណាព្យាបាលទេ ត្រូវប្រគល់ឱ្យមជ្ឈមណ្ឌលអប់រំបណ្ដោះអាសន្ន រង់ចាំសេចក្ដីសម្រេចរបស់តុលាការ។ ដោយឡែកចំពោះអនីតិជនមានអាយុ ១៤ឆ្នាំដល់ក្រោម ១៨ឆ្នាំ អាចត្រូវឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនអនីតិជនបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម។

- រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋកំណត់ដូចតទៅ[48]៖

---

[46] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៤

[47] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៥

[48] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១៣

- ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជនមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។
- ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ កាលណាអនីតិជនមានអាយុច្រើនជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

- រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈិមកំណត់ដូចតទៅ[49]៖
  - ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ២ (ពីរ) ខែ បានទេ កាលណាអនីតិជនមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។
  - ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជនមានអាយុចាប់ពី ១៦ (ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

ចំពោះបទមជ្ឈិមថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវលើសពីចំនួនពាក់កណ្តាលនៃអប្បបរមាទោសដែលច្បាប់បានកំណត់ចំពោះអនីតិជនឡើយ។

- **<u>ចំពោះនីតិជន</u>**

ចំពោះនីតិជន ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ ខែ បានទេ ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្តោះអាសន្នបាន ៦ ខែ ដោយមានដីកាសំអាងហេតុត្រឹមត្រូវ និង ច្បាស់លាស់ ចៅក្រមស៊ើបសួរ អាចសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្នបានតែ ២ (ពីរ) ដងគត់[50] ។

ចំពោះនីតិជន ដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ ខែ បានទេ ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចធ្វើការពន្យារការឃុំខ្លួនបណ្តោះអាសន្នបាន ២ ខែ ដោយមានដីកាសំអាងហេតុត្រឹមត្រូវ។[51] ចំពោះបទមជ្ឈិមថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវ លើសពីពាក់កណ្តាលនៃអប្បបរមាទោសដែលច្បាប់កំណត់ឡើយ។

បើមានការចោទប្រកាន់ ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ។ តែពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរ អាចនឹងពន្យារការឃុំខ្លួនបណ្តោះអាសន្នបាន ១ ឆ្នាំ ដោយមានដីកាសម្រេច

[49] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១៤
[50] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៨
[51] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៩

សំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះបានតែ ២ ដងគត់[52]។

ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចថា ពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងដល់ជនត្រូវចោទនឹងទទួលនូវការកត់សម្គាល់ពីជននេះ។ កាលណាជនត្រូវចោទមានមេធាវីអមមេធាវី ត្រូវបង្ហាញនូវមធ្យោបាយការពារខ្លួនឱ្យកូនក្តីខ្លួន ។

សរុបជារួមមក ត្រង់មាត្រា ៥៨១ នៃនៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់រយៈពេលឃុំខ្លួនបណ្តោះអាសន្នត្រឹមតែ ២ ខែគិតចាប់ពីថ្ងៃចាប់ខ្លួន ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចនៃភាគីកម្ពុជា មិនបានទទួលសំណើបត្យាប័នជាផ្លូវការ និងឯកសារសំអាងនានាអមមកជាមួយនោះទេ ការចាប់ខ្លួនបណ្តោះអាសន្ននឹងត្រូវបញ្ចប់សុពលភាព ហើយបុគ្គលនោះនឹងត្រូវដោះលែងឱ្យមានសេរីភាពឡើងវិញ។ នៅត្រង់មាត្រាខាងលើនេះមិនបានចែងច្បាស់លាស់អំពីថិរវេលាឃុំខ្លួនទៅលើអនីតិជន ឬនីតិជននោះទេ ដូច្នេះយើងអាចសន្និដ្ឋានជារួមបានថា ឱ្យតែជននោះជាកម្មវត្ថុនៃបត្យាប័ន មិនថាជននោះជានីតិជនក្តី ឬអនីតិជនក្តី គឺរយៈពេលដែលអាចឃុំខ្លួនបណ្តោះអាសន្នត្រឹមតែ ២ ខែតែប៉ុណ្ណោះ ប្រសិនបើអំឡុងពេលនោះមិនទទួលបានសំណើបត្យាប័នផ្លូវការទេ ការឃុំខ្លួនបណ្តោះអាសន្ននឹងត្រូវបញ្ចប់ ហើយត្រូវដោះលែងបុគ្គលនោះឱ្យមានសេរីភាព។

### ៣. នីតិវិធីចំពោះមុខសភាស៊ើបសួរ

ក្នុងសាលាឧទ្ធរណ៍មានសភាស៊ើបសួរដែលមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងឧទ្ធរណ៍។

បន្ទាប់ពីទទួលបានបុគ្គលដែលជាកម្មវត្ថុនៃបត្យាប័នហើយនោះ អគ្គព្រះរាជអាជ្ញាត្រូវរៀបចំសំណុំរឿងដើម្បីប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ។[53] បុគ្គលដែលគេទាមទារ ត្រូវតែបង្ហាញខ្លួននៅចំពោះមុខសភាស៊ើបសួរដោយមានអមមេធាវីរបស់ខ្លួន (អាចគាត់ជ្រើសរើសដោយខ្លួនឯង ឬអាចតាមការចាត់តាំង)។ សភាស៊ើបសួរនឹងសម្រេចក្តី បន្ទាប់ពីមានសវនាការមួយមាន ការចូលរួមពីព្រះរាជអាជ្ញា មេធាវីរបស់ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនត្រូវចោទដែរ កាលណាសភាស៊ើបសួរសម្រេចឱ្យចូលបង្ហាញខ្លួន។ សវនាការនេះ ត្រូវប្រព្រឹត្តទៅក្នុងបន្ទប់សម្ងាត់ បានន័យថាពុំមានវត្តមានសាធារណៈជនទេ លើកលែងតែភាគីពាក់ព័ន្ធដែលត្រូវអនុញ្ញាតឱ្យបានចូលរួមតែប៉ុណ្ណោះ នៅក្នុងករណីចាំបាច់សភាស៊ើបសួរអាចហៅអ្នកបកប្រែបាន។[54]

---

[52] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១០

[53] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨៤

[54] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨៥

ឧទាហរណ៍ៈ ករណីជនត្រូវចោទមិនចេះភាសាខ្មែរ នេះអាចជាករណីចាំបាច់សម្រាប់សភាស៊ើបសួរហៅរកអ្នកបកប្រែដើម្បីជាជំនួយទៅដល់នីតិវិធីក្នុងការជំនុំជម្រះ។

ក្រោយពីបានស្តាប់ចម្លើយរបស់បុគ្គលដែលគេទាមទារ សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានរបស់មេធាវីជនដែលគេទាមទាររួចមក ចៅក្រមស៊ើបសួរអាចចេញសាលដីកាសម្រេចដែលនឹងយល់ព្រម ឬមិនព្រម ចំពោះពាក្យស្នើសុំធ្វើបត្យាប័ន។

ករណីពិនិត្យឃើញថាការធ្វើបត្យាប័ននេះមិនគ្រប់គ្រាន់តាមលក្ខខណ្ឌច្បាប់តម្រូវទេ សភាស៊ើបសួរមានសិទ្ធិបដិសេធក្នុងការធ្វើបត្យាប័ន ប្រសិនបើបានចាប់ជនដែលជាកម្មវត្ថុនៃបត្យាប័នឃុំខ្លួន នោះត្រូវដោះលែងវិញភ្លាម។

ប៉ុន្តែប្រសិនបើសភាស៊ើបសួរសម្រេចឱ្យធ្វើបត្យាប័ន គឺសភាស៊ើបសួរត្រូវជូនដំណឹងភ្លាមនៅពេលដែលសាលដីកាចូលជាស្ថាពរ ទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ បន្ថែមពីនេះក៏ត្រូវមានអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នជាចុងក្រោយមួយទៀតដែលចេញដោយរាជរដ្ឋាភិបាល ពេលមានអនុក្រឹត្យនេះត្រូវជូនដំណឹងទៅកាន់រដ្ឋដែលស្នើសុំនោះឱ្យមកយកជនដែលគេទាមទារនេះ គឺមានរយៈពេលតែ ៣០ ថ្ងៃបន្ទាប់ពីការជូនដំណឹងអនុក្រឹត្យបង្គាប់ធ្វើបត្យាប័ន។ ប្រសិនបើរដ្ឋស្នើសុំមិនបានបំពេញ ឬធ្វើមនីតិវិធីក្នុងការមកទទួលយកជនដែលគេទាមទារនោះទេ គឺត្រូវដោះលែងជននោះវិញ។ រដ្ឋស្នើសុំត្រូវរៀបចំនីតិវិធីក្នុងការមកទទួលយកបុគ្គលដែលគេទាមទារ។ បុគ្គលដែលទាមទារមានសិទ្ធិក្នុងការប្តឹងតវ៉ាលើសេចក្តីសម្រេចសភាស៊ើបសួរ មានរយៈពេល ៥ ថ្ងៃក្នុងការប្តឹងទៅតុលាការកំពូល។

អំឡុងពេលដំណើរការនីតិវិធីនេះបុគ្គលដែលគេទាមទារឱ្យធ្វើបត្យាប័ន ក៏មានសិទ្ធិស្នើសុំឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ដោយពាក្យស្នើសុំឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ននេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ពាក្យស្នើសុំនេះត្រូវដាក់ជូនសភាស៊ើបសួរដែលជាអាជ្ញាធរមានសមត្ថកិច្ចសម្រេចលើពាក្យស្នើសុំនេះ ក្រោយពីបានស្តាប់ហេតុផលបុគ្គលជាប់ពាក់ព័ន្ធ សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជាអាជ្ញា និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី។[55]

[55] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨៧

បើមានការយល់ព្រមពីសាមីខ្លួន កម្ពុជាបញ្ជូនខ្លួនបុគ្គលដែលគេទាមទារតាមរយៈពាក្យស្នើសុំរបស់ភាគីចិនដែលធ្វើសំណើបត្យាប័ន ក្រោយពីទទួលបានព័ត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមចំពោះបត្យាប័ន សភាស៊ើបសួរត្រូវចុះនិទ្ទេសនេះនៅក្នុងសាលដីការបស់ខ្លួន។[56]

### ៤. ការពន្យារពេលនៃការប្រគល់ខ្លួន និងការប្រគល់ខ្លួនជាបណ្ដោះអាសន្ន

កាលណាបុគ្គលដែលគេទាមទារនោះ កំពុងត្រូវស្ថិតក្នុងនីតិវិធីជំនុំជម្រះក្តី ឬ កំពុងទទួលទោសក្នុងប្រទេសនៃភាគីទទួលសំណើ អំពីបទល្មើសណាមួយផ្សេងពីបទល្មើសជាកម្មវត្ថុរបស់បត្យាប័ន ភាគីទទួលសំណើអាប្រគល់ ឬ ពន្យារការប្រគល់ជននោះរហូតដល់ការបញ្ចប់នីតិវិធីជំនុំជម្រះក្តី ឬ ការទទួលទោសទាំងស្រុង ឬ មួយផ្នែកណានៃទោសដែលកំណត់ក្នុងសាលក្រម។ ភាគីទទួលសំណើត្រូវតែផ្តល់ដំណឹងជូនភាគីដាក់សំណើអំពីការពន្យារពេលនេះ និង បញ្ជាក់មូលហេតុច្បាស់លាស់។

ក្នុងករណីភាគីណាមួយយល់ឃើញថា ជនម្នាក់អាចត្រូវធ្វើបត្យាប័នបាន ភាគីទទួលសំណើអាចប្រគល់ជនដែលត្រូវស្នើសុំជាបណ្តោះអាសន្នទៅភាគីដាក់សំណើ ដើម្បីធ្វើការចោទប្រកាន់ស្របទៅតាមលក្ខខណ្ឌដែលបានកំណត់រវាងភាគីទាំងពីរ។ ជនណាម្នាក់ដែលត្រូវបានប្រគល់ទៅភាគីដាក់សំណើបន្ទាប់ពីការប្រគល់ខ្លួនបណ្តោះអាសន្ន អាចត្រូវប្រគល់ជាស្ថាពរទៅភាគីដាក់សំណើ ដើម្បីទទួលទោសតាមសាលក្រមកំណត់ស្របតាមបទបញ្ញត្តិនៃសន្ធិសញ្ញានេះ។

## ផ្នែកទី២. ព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើ

### ១. សំណើបត្យាប័ន

ថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានចែងបញ្ញត្តិច្បាប់អំពីដំណើរការដាក់សំណើសុំបត្យាប័នក៏ដោយ ក៏នីតិវិធីនៃការអនុវត្តប្រាកដជាមិនខុសគ្នានោះទេ។ អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ជាអ្នកធ្វើការចោទប្រកាន់ ហើយសំណុំរឿងត្រូវបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់មកត្រូវបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងការបរទេសដែលគាត់នឹងត្រូវបញ្ជូនទៅឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស ដែលកម្ពុជាស្នើសុំឱ្យធ្វើបត្យាប័នបុគ្គលពាក់ព័ន្ធដែលកំពុងស្នាក់នៅ។ ហើយឯកអគ្គរាជទូតកម្ពុជា ជាអ្នកបញ្ជូនសំណុំរឿងស្នើសុំទៅអាជ្ញាធរនៃរដ្ឋពាក់ព័ន្ធនោះ។

ព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិក្នុងការធ្វើសំណើបត្យាប័នទៅរដ្ឋដែលជនល្មើសមួយ ឬ ច្រើននាក់ស្នាក់នៅបាន ក្នុងករណីដែលជនល្មើសបានប្រព្រឹត្តបទល្មើសក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយ

[56] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨៨

ក្រោយមកជនល្មើសបានទៅស្នាក់នៅប្រទេសដទៃទៀត ដើម្បីគេចខ្លួន និងរួចផុតពីការទទួលខុសត្រូវ ទោះបីជាជនល្មើសនោះមានសញ្ជាតិខ្មែរ ឬបរទេសក៏ដោយ។

ទន្ទឹមនឹងនេះ ក្រសួងយុត្តិធម៌បានបង្កើតឱ្យមានអាជ្ញាធរកណ្តាល ដោយស្ថិតក្រោម យុត្តាធិការអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍលើវិស័យយុត្តិធម៌។ អាជ្ញាធរកណ្តាលនេះបានដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលលើបញ្ហាបត្យាប័ន ជាពិសេសគឺជាអ្នករៀបចំ និងត្រួតពិនិត្យក្នុងការធ្វើសំណើបត្យាប័ន។ ប៉ុន្តែសេចក្តីសម្រេចនេះ ពុំបានបញ្ជាក់អំពី នីតិវិធីនៃការបញ្ជូនជនល្មើស និងស្ថាប័នពាក់ព័ន្ធដែលត្រូវបញ្ជូនសំណើបត្យាប័ននេះឡើយ។

បទប្បញ្ញត្តិសន្ធិសញ្ញាបត្យាប័នគ្រាន់តែបញ្ជាក់ថា ការប្រាស្រ័យទាក់ទងគ្នារវាងរដ្ឋដាក់សំណើ និងរដ្ឋទទួលសំណើ ត្រូវតែធ្វើឡើងតាមរយៈការទូត លើកលែងតែមានបញ្ញត្តិផ្សេងថែងក្នុងកិច្ចព្រមព្រៀងនេះ។ ត្រង់ចំណុចនេះ គេចង់បញ្ជាក់ឱ្យយើងដឹងថា គ្រប់សំណើបត្យាប័នត្រូវបញ្ជូនទៅតាមផ្លូវទូត ប៉ុន្តែពុំបានបញ្ជាក់ថា រដ្ឋដាក់សំណើត្រូវបញ្ជូនសំណើបត្យាប័នទៅទូតរបស់រដ្ឋទទួលសំណើដែលតាំងនៅក្នុងប្រទេសរបស់ខ្លួន ឬតាមរយៈទូតរបស់ខ្លួនដែលតាំងនៅប្រទេសទទួលសំណើនោះទេ។

សំណើបត្យាប័ន ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវភ្ជាប់មកជាមួយនូវ៖

- ឯកសារសេចក្តីបញ្ជាក់ ឬព័ត៌មានផ្សេងទៀត ដែលពិពណ៌នាអំពីអត្តសញ្ញាណ និង ទីកន្លែងស្នាក់នៅប្រហាក់ប្រហែលរបស់ជនល្មើសដែលត្រូវស្នើសុំ
- សេចក្តីបញ្ជាក់លើអង្គហេតុនៃសំណុំរឿង រួមបញ្ចូលទាំងពេលវេលា និងទីកន្លែងប្រព្រឹត្តបទល្មើស និងប្រវត្តិនីតិវិធីនៃសំណុំរឿង
- សេចក្តីបញ្ជាក់អំពីច្បាប់ ដែលពិពណ៌នាអំពីការដាក់ទណ្ឌកម្មចំពោះបទល្មើស
- សេចក្តីបញ្ជាក់អំពី ច្បាប់ដែលទាក់ទងនឹងការកំណត់ពេលនៃការចោទប្រកាន់ ឬការអនុវត្ត ទណ្ឌកម្មចំពោះបទល្មើស
- ឯកសារ សេចក្តីបញ្ជាក់ ឬព័ត៌មានផ្សេងទៀតដែលបញ្ជាក់នៅក្នុងកថាខណ្ឌ
- សេចក្តីចម្លងនៃដីកាចាប់ខ្លួនមួយច្បាប់ ដែលចេញដោយសភាស៊ើបសួរកម្ពុជា
- ពត៌មានដែលបញ្ជាក់ថា បុគ្គលដែលស្នើសុំបត្យាប័ន គឺជាបុគ្គលដែលមានដីកាចាប់ខ្លួន ឬ ដីកាឃុំខ្លួន
- សេចក្តីបញ្ជាក់អំពី ឬការខកខានដែលបានចោទប្រកាន់ បង្កើតបានជាបទល្មើស និង ភស្តុតាងគាំទ្រដែលអាចផ្តល់នូវមូលដ្ឋានត្រឹមត្រូវ គួរឱ្យសង្ស័យថា បុគ្គលដែលត្រូវធ្វើបត្យាប័ន បានប្រព្រឹត្តបទល្មើសដែលបត្យាប័នត្រូវបានស្នើឡើង។

ក្នុងករណីដែលការធ្វើសំណើបត្យាប័ន សំដៅទៅលើជនដែលត្រូវបានរកឃើញនូវពិរុទ្ធភាព សំណើបត្យាប័ន ត្រូវភ្ជាប់មកជាមួយផងដែរនូវះ

- សេចក្តីចម្លងសាលក្រមតុលាការកម្ពុជា
- ព័ត៌មានដែលបញ្ជាក់ថា បុគ្គលដែលស្នើនៅក្នុងបត្យាប័ន គឺជាបុគ្គលដែលមានពិរុទ្ធ
- សេចក្តីបញ្ជាក់ អំពីអំពើរបស់បុគ្គលនោះ ដែលត្រូវបានរកឃើញថាពិតជាមានពិរុទ្ធពិតមែន និង
- ត្រូវបញ្ជាក់ទាក់ទងនឹងមធ្យោបាយតាមផ្លូវច្បាប់ ដើម្បីឲ្យជនល្មើស ដែលត្រូវបានតុលាការ ផ្តន្ទាទោសតាមរយៈសាលក្រមកំបាំងមុខនោះ អាចមានសិទ្ធិក្នុងការការពារខ្លួនរបស់គេបាន ឬការជំនុំជម្រះសារជាថ្មីឡើងវិញ។

គ្រប់ឯកសារនៃសំណើបត្យាប័នទាំងអស់ដែលត្រូវបានចុះហត្ថលេខា ឬបោះត្រាជាផ្លូវការ ត្រូវតែភ្ជាប់មកជាមួយនូវ អត្ថបទបកប្រែជាភាសានៃរដ្ឋទទួលសំណើ ឬជាភាសាអង់គ្លេស។

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា ដាក់សំណើទៅរដ្ឋណាមួយ ដែលកម្ពុជាពុំទាន់បាន ឬពុំបានចុះសន្ធិសញ្ញាបត្យាប័នជាមួយគ្នា នោះកម្ពុជាត្រូវអនុលោមតាមច្បាប់ជាធរមានរបស់កម្ពុជា ប៉ុន្តែនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ពុំបានបញ្ញត្តិអំពីនីតិវិធីនៃការធ្វើសំណើបត្យាប័ននោះទេ។ បើយើងក្រឡេកទៅមើលច្បាប់ស្តីពីការប្រឆាំងអំពើភេរវកម្មវិញ នៅត្រង់មាត្រា ៩៧ ក៏បានបញ្ញត្តិចែង អំពីការធ្វើសំណើបត្យាប័នដែលមានការប្រហាក់ប្រហែលគ្នាទៅនឹងកិច្ចព្រមព្រៀងស្តីពីបត្យាប័នផងដែរ។

### ២. នីតិវិធីចំពោះមុខសភាស៊ើបសួរ

នៅពេលដែលភាគីចិនបានទទួលសំណើសុំបត្យាប័នពីព្រះរាជាណាចក្រកម្ពុជា និងបានបញ្ជូនខ្លួនបុគ្គលដែលជាកម្មវត្ថុនៃបត្យាប័នមកដល់ដែនដីកម្ពុជាហើយនោះ បុគ្គលដែលត្រូវបានធ្វើបត្យាប័នមានរយៈពេល ១៥ ថ្ងៃ ដើម្បីស្នើសុំមោឃភាពនៃបត្យាប័ន។

សភាស៊ើបសួរ ជាស្ថាប័នដែលមានសមត្ថកិច្ចធ្វើការសម្រេចថា បុគ្គលដែលបានស្នើសុំមោឃភាពជាលាយលក្ខណ៍អក្សរត្រូវបានរួចខ្លួន ឬត្រូវចោទប្រកាន់បន្តតាមការពិចារណាមួយដែលមានមូលដ្ឋានលើចម្លើយផ្ទាល់របស់បុគ្គលដែលត្រូវបានធ្វើបត្យាប័ន សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី។

## ៣. អានុភាពនៃមោឃភាពបត្យាប័ន

### ៣.១. អានុភាពមិនផ្អាកនៃបណ្តឹងសុំមោឃភាព

បណ្តឹងសុំមោឃភាពនៃបត្យាប័ននេះ មិនអាចបង្អាក់ដំណើរការនៃបណ្តឹងចោទប្រកាន់ទៅលើបុគ្គលដែលពាក់ព័ន្ធឡើយ។ បើសភាស៊ើបសួរសម្រេចមិនមោឃភាពបត្យាប័នតាមពាក្យសុំទេ នីតិវិធីចោទប្រកាន់ដែលកំពុងធ្វើទៅលើជនដែលជាកម្មវត្ថុនៃបត្យាប័ន គឺនៅតែបន្តដដែល។

### ៣.២. អានុភាពនៃមោឃកម្មចំពោះបត្យាប័ន

ប្រសិនបើសេចក្តីសម្រេចចូលជាស្ថាពររបស់សភាស៊ើបសួរសម្រេចថា បត្យាប័នត្រូវបានចាត់ទុកជាមោឃភាពវិញនោះ នីតិវិធីចោទប្រកាន់ដែលកំពុងតែប្រព្រឹត្តត្រូវតែបញ្ចប់ ហើយបុគ្គលជាប់ចោទត្រូវបានដោះលែងឱ្យមានសេរីភាពឡើងវិញ និងមានលទ្ធភាពចាកចេញដោយសេរីពីដែនដីកម្ពុជា។ ប៉ុន្តែក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីការដោះលែងឱ្យមានសេរីភាពនេះ បុគ្គលដែលត្រូវបានធ្វើបត្យាប័ននេះ អាចត្រូវបានគេចាប់ខ្លួនម្តងទៀតនៅលើដែនដីកម្ពុជា និងត្រូវជាកម្មវត្ថុនៃនីតិវិធីចោទប្រកាន់ជាថ្មីចំពោះអំពើដែលនាំឱ្យមានការធ្វើបត្យាប័នបុគ្គលនេះបាន។

## ៤. នីតិវិធីក្រោយផ្តល់បត្យាប័ន

ក្រោយពីបត្យាប័នត្រូវបានផ្តល់ឱ្យព្រះរាជាណាចក្រកម្ពុជា ភាគីទទួលសំណើត្រូវសម្រេចអំពីការអនុវត្តបត្យាប័ន។ ផ្អែកតាមកិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងកម្ពុជា-ចិន ព្រមទាំងសន្ធិសញ្ញា និងអនុសញ្ញាស្តីពីបត្យាប័នរបស់កម្ពុជា ការអនុវត្តបត្យាប័ន ត្រូវធ្វើតាមវិធីពីរយ៉ាង គឺការប្រគល់ខ្លួនជនដែលត្រូវស្នើសុំ និងការប្រគល់ទ្រព្យសម្បត្តិ។

បន្ថែមពីលើនេះ កិច្ចព្រមព្រៀងស្តីពីបត្យាប័ន បានកំណត់ថាភាគីទទួលសំណើត្រូវចេញសោហ៊ុយនៃដំណើរការនីតិវិធីដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួនដែលកើតឡើងពីសំណើធ្វើបត្យាប័ន។

ចំណែកភាគីទទួលសំណើត្រូវចេញសោហ៊ុយដែលកើតឡើងនៅក្នុងដែនដីរបស់ខ្លួន ទាក់ទងនឹងការចាប់ខ្លួន និងការឃុំខ្លួននៃជនដែលស្នើសុំបត្យាប័ន ឬការដកហូត និងការប្រគល់ទ្រព្យសម្បត្តិ។ ភាគីដាក់សំណើត្រូវចេញសោហ៊ុយដែលកើតឡើងពីការដឹកជញ្ជូនបុគ្គលដែលបត្យាប័នត្រូវផ្តល់ជូនពីទឹកដីនៃភាគីទទួលសំណើ រួមទាំងសោហ៊ុយធ្វើដំណើរឆ្លងកាត់។

កាលណាព្រះរាជាណាចក្រកម្ពុជាបានទទួលបត្យាប័ននៃអាណិកជនបរទេស ហើយក្រោយមកទៀតបានទទួលពាក្យប្តឹងសុំឱ្យធ្វើបត្យាប័នពីរដ្ឋបរទេសណាមួយផ្សេង ព្រះរាជាណាចក្រកម្ពុជានឹងអាចយល់ព្រម

តាមពាក្យប្តឹងសុំនេះបាន ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋដែលបានប្រគល់អាណិកជននេះមករាជរដ្ឋាភិបាលកម្ពុជា ។

ប៉ុន្តែការយល់ព្រមខាងលើនេះមិនជាការចាំបាច់ទេ កាលណាអាណិកជនបរទេសនេះមានលទ្ធភាពចាកចេញដោយសេរីពីដែនដីកម្ពុជារួចទៅហើយ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។

### ៤.១. ការប្រគល់ខ្លួនដែលត្រូវស្នើសុំ

ប្រសិនបើបត្យាប័នត្រូវបានផ្តល់ឱ្យនោះភាគីទទួលសំណើ និង ភាគីដាក់សំណើ ត្រូវសម្រេចអំពីការអនុវត្តបត្យាប័នតាមរយៈការពិគ្រោះយោបល់គ្នា ហើយភាគីទទួលសំណើ នឹងជូនពត៌មានដល់ភាគីដាក់សំណើអំពីរយៈពេលដែលជនដែលត្រូវស្នើសុំនោះ ត្រូវបានចាប់ឃុំឃាំងមុនពេលប្រគល់ខ្លួន។

ល្គឹកណាកថាខណ្ឌ ៣ នៃប្រការនេះ មិនមានចែងអ្វីមួយផ្ទុយពីនេះ ភាគីដាក់សំណើត្រូវ បានចាត់ទុកថាបានបោះបង់សំណើបត្យាប័ន ប្រសិនបើភាគីនេះពុំទទួលយកជនដែលត្រូវបានស្នើសុំ ក្នុងរយៈពេល ១៥ ថ្ងៃក្រោយពីកាលបរិច្ឆេទសម្រាប់ការអនុវត្តធ្វើបត្យាប័ន ដូចដែលបានព្រមព្រៀងគ្នារួចហើយ។ ភាគីទទួលសំណើត្រូវដោះលែងជននោះ ឱ្យមានលើភាពជាបន្ទាន់ហើយអាចបដិសេធការធ្វើបត្យាប័នចំពោះបទល្មើសដដែលនេះ។

ប្រសិនបើភាគីចុះកិច្ចព្រមព្រៀងណាមួយខកខានពុំបានប្រគល់ ឬ ទទួលជនដែល ត្រូវស្នើសុំក្នុងថេរវេលាដែលបានព្រមព្រៀងគ្នា ដោយករណីប្រធានសក្តីភាគីម្ខាងទៀត។[57]

### ៤.២. ការប្រគល់នូវទ្រព្យសម្បត្តិ

យោងតាមក្របខណ្ឌនៃច្បាប់របស់ខ្លួន និងយោងតាមសំណើនៃភាគីដាក់សំណើ ភាគីទទួលសំណើត្រូវរឹបអូសនូវទ្រព្យសម្បត្តិ និងក្រោយពីបានផ្តល់បត្យាប័ន ត្រូវប្រគល់ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃភស្តុតាង ឬទ្រព្យសម្បត្តិដែលកើតចេញពីលទ្ធផលនៃបទល្មើសទៅឱ្យរដ្ឋដាក់សំណើ៖

- ដែលអាចតម្រូវឱ្យធ្វើជាភស្តុតាង ឬ
- ដែលត្រូវបានទទួលស្គាល់ថាជាទ្រព្យសម្បត្តិចេញពីលទ្ធផលនៃបទល្មើស

ទ្រព្យសម្បត្តិដូចមានខាងនេះត្រូវរឹបអូស ឬប្រគល់ជូនស្របតាមកថាខណ្ឌខាងលើទោះបីជាបត្យាប័នដែលត្រូវបានផ្តល់ឱ្យមិនអាចអនុវត្តបានដោយមូលហេតុមកពីមរណៈភាព ការបាត់ខ្លួន ឬការគេចខ្លួននៃជនត្រូវចោទ។

[57] សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន, នស/រកម/០៧០០/០៤, ០៩ កុម្ភៈ ១៩៩៩, ប្រការទី១១

កាលណាទ្រព្យសម្បត្តិដូចមានចែងខាងលើនេះ ជាកម្មសិទ្ធិនៃការដកហូត ឬរឹបអូសនៅលើដែនដីនៃភាគីទទួលសំណើ ភាគីនោះអាចរក្សាទុកជាបណ្ដោះអាសន្នទ្រព្យសម្បត្តិទាំងនេះ ឬបញ្ជូនវាត្រឡប់ទៅវិញក្នុងលក្ខខណ្ឌដែលទ្រព្យសម្បត្តិទាំងនេះស្ថិតក្នុងការរង់ចាំនីតិវិធីព្រហ្មទណ្ឌ។

រាល់សិទ្ធិទាំងឡាយណាដែលភាគីទទួលសំណើ ឬរដ្ឋណាមួយ ឬបុគ្គលណាមួយមានលើទ្រព្យសម្បត្តិដូចពោលខាងលើត្រូវបានរក្សាទុក។ ក្រោយពីមានការជំនុំជម្រះរួច ទោះបីជាសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះនៅទីណាក៏ដោយ ទ្រព្យសម្បត្តិទាំងនេះត្រូវបញ្ជូនទៅភាគីទទួលសំណើភ្លាមតាមសំណូមពរដោយគ្មានបន្ទុកពន្ធអាករបន្ទាប់ពីការជំនុំជម្រះក្ដី។

### ៤.៣. ការឧបត្ថម្ភ និងការចំណាយ

ភាគីទទួលសំណើត្រូវចេញមុខ ក្នុងនាមជាភាគីដាក់សំណើដោយចាត់ចែង និងអនុវត្តរាល់នីតិវិធីដែលចេញពីសំណើបត្យាប័ន។

ចំណាយសម្រាប់បត្យាប័ន ជាបន្ទុករបស់ភាគីដាក់សំណើ។ ចំណាយសម្រាប់ការដឹកនាំតាមផ្លូវអាកាស និងការឆ្លងកាត់ដែលទាក់ទងនឹងការធ្វើបត្យាប័នជននោះ គឺជាបន្ទុករបស់ភាគីដាក់សំណើ។

# សេចក្ដីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

សរុបមកបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន បានចងសម្ព័ន្ធភាពកាន់តែស្អិតរមួត និងពិតជាមានសារៈប្រយោជន៍ដល់គូភាគីក្នុងដំណើការនៃការបង្រ្កាបបទល្មើសឆ្លងដែន និងបង្ការភាពអសន្តិសុខ ដោយធានាបាននូវ អធិបតេយ្យភាព បូរណភាពទឹកដី សមភាព ឯករាជជាតិ និងប្រយោជន៍ទៅវិញទៅមក។ បត្យាប័នកម្ពុជា-ចិន គឺជាចរន្តការមួយធ្វើឡើងដោយរដ្ឋជាភាគីស្នើសុំទៅរដ្ឋភាគីម្ខាងទៀតដើម្បីបញ្ជូនឧក្រិដ្ឋជនដែលបានប្រព្រឹត្តបទល្មើសអនុវត្តទោសដោយច្បាប់នៃប្រទេសណាមួយ។ ដើម្បីលេចចេញនូវបត្យាប័នកម្ពុជា-ចិន ច្បាប់ដែលជាមូលដ្ឋានក្នុងការបង្កើតនេះរួមមាន សន្ធិសញ្ញាអន្តរជាតិ សន្ធិសញ្ញាស្ដីពីបត្យាប័នរបស់អង្គការសហប្រជាជាតិ ច្បាប់រដ្ឋធម្មនុញ្ញ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហទណ្ឌ ជាគោលការណ៍ប្រទេសនីមួយៗមិនធ្វើបត្យាប័នជាដាច់ខាតទៅលើពលរដ្ឋរបស់ខ្លួនទៅឱ្យរដ្ឋដ៏ទៃ។ ក្រឡេកទៅមើលលក្ខខណ្ឌនៃការធ្វើបត្យាវិញដើម្បីធ្វើបត្យាប័នបាន លុះត្រាតែអំពើដែលត្រូវបានចោទប្រកាន់លើបុគ្គលដែលជាកម្មវត្ថុនៃបត្យាប័នជាបទល្មើសតាមច្បាប់របស់ភាគីទាំងពីរ ហើយបទល្មើសនោះត្រូវមានក្នុងប្រទេសទាំងពីរបើទោះបីជាការប្រើពាក្យបច្ចេកសព្ទ និងនិយមន័យមិនដូចគ្នា ឬធាតុផ្សំបទល្មើសខុសគ្នាក៏ដោយឱ្យតែរដ្ឋទាំងពីរកំណត់ថាសកម្មភាពនោះជាបទល្មើសចែងក្នុងបញ្ញត្តិជាធរមាននឹងអាចធ្វើបត្យាប័នបាន។ បទល្មើសអាចធ្វើបត្យាប័នបានលុះត្រាតែការចោទប្រកាន់ជាទោសដាក់ពន្ធនាគារយ៉ាងតិច ឬស្មើ ១ ឆ្នាំ តាមច្បាប់នៃរដ្ឋសំណើមួយវិញទៀតករណីរដ្ឋណាមួយបានកាត់ទោសរួចហើយបានសម្រេចដាក់ទោសពន្ធនាគារចាប់ពី ៦ខែឡើងទៅក៏អាចជាកម្មវត្ថុនៃការធ្វើបត្យាប័នដែរ។ មូលដ្ឋាននៃការមិនអាចធ្វើបត្យាប័នបាន គឺបទល្មើសយោធា បទល្មើសនយោបាយ ទោសប្រហារជីវិត អាជ្ញាយុកាលនៃបទល្មើស និងអាជ្ញាយុកាលនៃទោស។ ការស្នើសុំធ្វើបត្យាប័នគ្រប់ពាក្យសុំត្រូវតែជូនរដ្ឋាភិបាលតាមផ្លូវទូត បន្ទាប់មកក្រសួងការបរទេសពិនិត្យពាក្យសុំបត្យាប័ន និងបញ្ជាក់ថាត្រឹមត្រូវ រដ្ឋមន្ត្រីក្រសួងការបរទេសបញ្ជូនទៅក្រសួងយុត្តិធម៌ដើម្បីពិនិត្យនិយ័តភាពនៃពាក្យសុំ រួចក្រសួងយុត្តិធម៌បញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។ ក្នុងករណីបន្ទាន់ដោយខ្លាចបុគ្គលដែលជាកម្មវត្ថុនៃការធ្វើបត្យាប័ននោះរត់គេចខ្លួនភាគីកម្ពុជា-ចិន អាចធ្វើការចាប់ខ្លួនបណ្ដោះអាសន្នលើបុគ្គលដែលត្រូវធ្វើបត្យាប័ន។ ការធ្វើបត្យាប័នគូភាគីត្រូវធ្វើតាមពីរវិធីការប្រគល់ខ្លួនជនដែលត្រូវស្នើសុំ និងការប្រគល់ទ្រព្យសម្បត្តិ ចំណាយសម្រាប់ធ្វើបត្យាប័នជាបន្ទុកភាគីទទួលសំណើ ចំណាយសម្រាប់ការដឹកជញ្ជូនផ្លូវអាកាស និងឆ្លងដែលទាក់ទងនឹងការធ្វើបត្យាប័ននោះ គឺជាបន្ទុកភាគីដាក់សំណើ។

ក្រោយពីសិក្សាធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទស្ដីពីបត្យាប័នព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន យើងខ្ញុំទាំងពីរនាក់បានទទួលនូវចំណេះដឹងទាក់ទងនឹងមូលដ្ឋានគ្រឹះនៃបត្យាប័ន

និងចំណេះដឹងស្ដីពីសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយណាដែលពាក់ព័ន្ធនឹងបត្យាប័ន ព្រមទាំងចំណេះពាក់ព័ន្ធនឹងលក្ខខណ្ឌ និងនីតិវិធីនៃការធ្វើបត្យាប័ន។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវលើប្រធានបទ "**បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន**" យើងខ្ញុំសង្កេតឃើញថា ប្រធានបទនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ទៅដល់អ្នកសិក្សាស្រាវជ្រាវ។ ទោះបីជាមានសន្ធិសញ្ញារវាងកម្ពុជា-ចិន ក៏សន្ធិសញ្ញានេះមិនបានបកស្រាយលម្អិតលើនីតិវិធីមួយចំនួនដែលមានដូចជា លទ្ធភាពនៃការទាមទារបុគ្គលដែលធ្វើបត្យាប័ននោះមកវិញ ច្បាប់ ឬ សន្ធិសញ្ញាមិនបានបញ្ជាក់អំពីមូលដ្ឋានច្បាស់លាស់ ក្នុងការកំណត់អំពីលទ្ធភាពរបស់រដ្ឋដែលស្នើសុំឱ្យផ្ទេរបុគ្គលដែលជាកម្មវត្ថុបត្យាប័ននោះ ត្រឡប់មករដ្ឋដែលទទួលសំណើវិញក្នុងករណីបើមើលឃើញថា ការអនុវត្តបត្យាប័ននេះមានភាពមិនប្រក្រតី (ករណីរដ្ឋនោះមិនអនុវត្តតាមសន្ធិសញ្ញាបត្យាប័នរវាងកម្ពុជា-ចិន)។

បត្យាប័ននេះមានចំណុចមួយលើកឡើងថា "រាល់ការធ្វើបត្យាប័នត្រូវធានាថាមិនមានការអនុវត្តការកាត់ទោសប្រហារជីវិត"។ ប៉ុន្តែប្រសិនយើងក្រឡេកមើលការអនុវត្តជាក់ស្តែង បើភាគីចិនយកបុគ្គលដែលជាកម្មវត្ថុនៃបត្យាប័ននោះទៅកាត់ទោសប្រហារជីវិតដែលផ្ទុយពីកម្មវត្ថុដែលគេបានស្នើសុំបត្យាប័ន តើនៅពេលនោះមានផលប៉ះពាល់អ្វីខ្លះទៅដល់ភាគីចិន? តើមានច្បាប់ណាបានចែងពីវិធានការអនុវត្តចំពោះរដ្ឋដែលល្មើសនឹងសន្ធិសញ្ញាទ្វេភាគី ឬសន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិ? ត្រង់ចំណុចនេះជាចំណុចឆកល្វែងមួយនៃសន្ធិសញ្ញាបត្យាប័នរវាងកម្ពុជា-ចិន ករណីប្រសិនបើមានរដ្ឋណាមួយល្មើសនឹងការព្រមព្រៀងនេះ។ ម្យ៉ាងវិញទៀតសេដ្ឋកិច្ចប្រទេសកម្ពុជាបច្ចុប្បន្នមួយផ្នែកធំ គឺត្រូវពឹងផ្អែកទៅលើប្រទេសចិន ហើយបើសិនជាប្រទេសចិនមិនអនុវត្តកាតព្វកិច្ច ឬ អនុវត្តផ្ទុយពីសន្ធិសញ្ញាខាងលើនេះ តើប្រទេសកម្ពុជាហ៊ានដាក់ពាក្យប្ដឹងទៅអង្គការសហប្រជាជាតិលើប្រទេសចិនដែរឬទេ? កត្តានេះនាំឱ្យជះឥទ្ធិពលដល់ការគោរពឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី សមភាព និងផលប្រយោជន៍។

ដោយឡែកសន្ធិសញ្ញា និងច្បាប់របស់យើងមិនបានបង្ហាញថា ភាគីចិនត្រូវរៀបចំនីតិវិធី និងសំណុំឯកសារដែលតម្រូវឱ្យមកទទួលយកបុគ្គលដែលខ្លួនបានស្នើសុំនោះ បន្ទាប់ពីប្រទេសកម្ពុជាបានចេញអនុក្រឹត្យបង្គាប់ធ្វើបត្យាប័ន។

សរុបជារួមមក តាមយោបល់របស់យើងខ្ញុំ សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនមិនបានចែងលក្ខខណ្ឌគ្រប់គ្រាន់ពេញលេញលើការអនុវត្តនីតិវិធី ក៏ដូចជាបញ្ហាដែលមានភាគីល្មើសទៅនឹងកិច្ចព្រមព្រៀងនេះ ដូច្នេះរាជរដ្ឋាភិបាល និងក្រសួងយុត្តិធម៌គួរតែពិចារណាបន្ថែមទៅលើការបង្កើតនូវច្បាប់ដាច់ដោយឡែក និងបំពេញបន្ថែមនូវចន្លោះប្រហោងនៃច្បាប់ដើម្បីឱ្យសន្ធិសញ្ញានេះកាន់តែមានប្រសិទ្ធិភាព និងអញ្យាក្រឹត្យ។

# ឯកសារយោង

# ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- Treaty on Extradition* (Adopted by General Assembly resolution 45/116, subsequently amended by General Assembly resolution 52/88), 68th plenary meeting, 14 December 1990.
- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិចិន ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០០/០៤ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០
- អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប បានអនុម័ត និងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងឱ្យចូលជាសមាជិកតាមសេចក្តីសម្រេចលេខ ៣៩/៤៦ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ របស់មហាសន្និបាតអង្គការសហប្រជាជាតិ
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា, ប្រកាសឱ្យប្រើដោយក្រុមប្រឹក្សារដ្ឋលេខ ០៦ ក្រ, ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៨, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧
- STATUTE OF THE INTERNATIONAL COURT OF JUSTICE, San Francisco, United States, Effective, 24 October 1945
- រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ នៅឆ្នាំ២០១៧
- អៀង សំណាង នីតិវិធីព្រហ្មទណ្ឌ នៅឆ្នាំ២០១៨

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី ១. សន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០០/០៤, ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០
- ឧបសម្ព័ន្ធទី ២. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧
- ឧបសម្ព័ន្ធទី ៣. ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៨, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧
- ឧបសម្ព័ន្ធទី ៤. អនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ស្តីពីការបង្គាប់ឱ្យធ្វើបត្យាប័ន
- ឧបសម្ព័ន្ធទី ៥. អនុក្រឹត្យលេខ ១២១៩ អនក្រ.តត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការបង្គាប់ឱ្យធ្វើបត្យាប័ន,
- ឧបសម្ព័ន្ធទី ៦. បត្យាប័ន រៀបរៀងដោយៈ ឯកឧត្តម ផូវ សំភី ខែមករា ឆ្នាំ២០០៨
- ឧបសម្ព័ន្ធទី ៧. បទបង្ហាញស្តីពីបត្យាប័ន រៀបរៀងដោយៈ ក្រសួងយុត្តិធម៌ ឆ្នាំ២០២២
- ឧបសម្ព័ន្ធទី ៨. អត្ថបទស្តីពី បត្យាប័ន បទឧទ្ទេសនាមដោយៈ លោក ជុំគីរី ឆ្នាំសិក្សា ២០២២
- ឧបសម្ព័ន្ធទី ៩. គំនូសតាងនៃនីតិវិធីនៃបត្យាប័នតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលស្នើដោយរដ្ឋបរទេស ចងក្រងដោយៈ ស៊ាង សំភស
- ឧបសម្ព័ន្ធទី ១០. ដីកាបញ្ជូនអោយចាប់ខ្លួន-ឃុំខ្លួន ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤
- ឧបសម្ព័ន្ធទី ១១. គំរូកំណត់បង្ហាញរឿងរបស់ក្រសួងយុត្តិធម៌ស្តីពីសំណើសុំធ្វើបត្យាប័ន
- ឧបសម្ព័ន្ធទី ១២. គំរូដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- ឧបសម្ព័ន្ធទី ១៣. គំរូដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់
- ឧបសម្ព័ន្ធទី ១៤. គំរូកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម
- ឧបសម្ព័ន្ធទី ១៥. គំរូដីកាបង្គាប់ឱ្យចូលខ្លួន
- ឧបសម្ព័ន្ធទី ១៦. គំរូដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទ
- ឧបសម្ព័ន្ធទី ១៧. គំរូដីកាបង្គាប់ឱ្យចាប់ខ្លួន

## ឧបសម្ព័ន្ធទី ១

# សន្ធិសញ្ញា

## ស្ដីពី

## បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា
## និងសាធារណរដ្ឋប្រជាមានិតចិន

# ព្រះរាជក្រម

នស/រកម/០៧០០/០៤

## យើង
## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិ - បត្តិការអន្តរជាតិ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ ហើយដែល ព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ នាសម័យ ប្រជុំពេញអង្គលើកទី ៣ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# សន្ធិសញ្ញា
# ស្តីពី បត្យាប័ន
# រវាង
# ព្រះរាជាណាចក្រកម្ពុជា
# និង
# សាធារណរដ្ឋប្រជាមានិតចិន

*****************

ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតចិន ដែលតទៅនេះកំណត់ហៅថា "ភាគីចុះកិច្ចព្រមព្រៀង"

ដោយមានបំណងជំរុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរ ក្នុងការកំចាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និង ផលប្រយោជន៍ទាំងសងខាង តាមការចុះសន្ធិសញ្ញាបត្យាប័ន
បានព្រមព្រៀងគ្នាដូចតទៅ :

## ប្រការទី ១
## ភារកិច្ចត្រូវធ្វើបត្យាប័ន

យោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងមានភារកិច្ចធ្វើបត្យាប័នទៅភាគីម្ខាងទៀតនូវជនទាំងឡាយណា ដែលត្រូវបានឃើញនៅលើដែនដីនៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ហើយជនទាំងនោះកំពុងត្រូវគេតាមចាប់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ដើម្បីធ្វើការជំនុំជំរះក្តី ឬ ដើម្បីអោយទទួលទោស ឬ អនុវត្តន៍ទណ្ឌកម្ម តាមទោសកំណត់ នៅលើទឹកដីរបស់ភាគីម្ខាងទៀត ចំពោះបទល្មើសដែលអាចធ្វើបត្យាប័នបានណាមួយ ។

## ប្រការទី ២
## បទល្មើសដែលអាចធ្វើបត្យាប័នបាន

១.ក្នុងស្មារតីនៃសន្ធិសញ្ញានេះ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរ ដោយការដាក់ពន្ធនាគារ ឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំង សំរាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬ ការផ្តន្ទាទោសណាមួយដែលធ្ងន់ជាងនេះ ។

២.កាលណាមានសំណើបត្យាប័នពាក់ព័ន្ធដល់បុគ្គលណាម្នាក់ ដែលត្រូវបានកាត់ទោសជាប់ពន្ធនាគារ ឬ ការឃុំឃាំងតាមរូបភាពណាមួយផ្សេងទៀត ធ្វើឡើងដោយតុលាការរបស់ភាគីដាក់សំណើចំពោះបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័នអាចនឹងផ្តល់បាន លុះត្រាតែទោសកំណត់ដែលត្រូវទទួលដូចមានចែងក្នុងសាលក្រម នៅសល់យ៉ាងតិចបំផុត ៦ ខែទៀត ។

៣.ក្នុងស្មារតីប្រការនេះ ការកំណត់ថាបទល្មើសណាមួយ ជាបទល្មើសប្រឆាំងនឹងអង្គច្បាប់នៃភាគីទាំងពីរ គឺមិនសំខាន់ត្រង់ថាអង្គច្បាប់នៃភាគីចុះកិច្ចព្រមព្រៀង ចាត់ទុកអំពើដែលបង្កនូវបទល្មើសនោះ ក្នុងប្រភេទនៃបទល្មើសដូចគ្នា ឬ កំណត់បទល្មើសដោយពាក្យពេចន៍ដូចគ្នានោះទេ ។

៤.កាលណាបត្យាប័នត្រូវបានផ្តល់អោយ ក្នុងស្មារតីនៃបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័ននេះក៏អាចផ្តល់អោយចំពោះបទល្មើសផ្សេងទៀត ដែលចែងក្នុងសំណើបត្យាប័នដដែលនេះ ហើយដែលមានលក្ខណៈគ្រប់គ្រាន់សំរាប់ធ្វើបត្យាប័ន លើកលែងតែរយៈពេលផ្តន្ទាទោស ឬ ឃុំឃាំង ដែលមានចែងក្នុងកថាខ័ណ្ឌទី ១ និង ២ របស់ប្រការនេះ ។

## ប្រការទី ៣
## មូលដ្ឋាននៃការបដិសេធដាច់ខាត

ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ បត្យាប័ននឹងមិនអនុញ្ញាតិអោយធ្វើបានឡើយ ក្នុងករណីណាមួយដូចខាងក្រោមនេះ :

១.ភាគីទទួលសំណើយល់ឃើញថា បទល្មើសជាកម្មវត្ថុនៃបត្យាប័ន ដែលធ្វើឡើងដោយភាគីដាក់សំណើ ជាបទល្មើសនយោបាយ ។ ការយោងទៅលើបទល្មើសនយោបាយ ពុំត្រូវរាប់បញ្ចូលនូវការធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាត ឬ ការបំពារបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ឬ សមាជិកគ្រួសារនៃរូបជនទាំងនោះ ។

២.ភាគីទទួលសំណើមានមូលដ្ឋានច្បាស់លាស់ ដើម្បីសន្និដ្ឋានថាសំណើបត្យាប័នធ្វើឡើងដោយភាគីដាក់សំណើ មានគោលបំណងប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង ឬ អនុវត្តទណ្ឌកម្មទៅលើបុគ្គល ដែលត្រូវចោទប្តឹងដោយមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ ជំហររបស់ជនដែលត្រូវចោទប្តឹងក្នុងរឿងក្តីនោះ ត្រូវបានគេចាត់ទុកថាបានធ្វើអោយប៉ះពាល់ការសំអាងដែលពោលខាងលើ ។

៣.បទល្មើសដែលជាកម្មវត្ថុនៃសំណើបត្យាប័ន តាមច្បាប់របស់ភាគីដាក់សំណើ គឺជាបទល្មើសយោធាសុទ្ធសាធ ។

៤.ការចោទប្រកាន់ ឬ ការអនុវត្តការដាក់ទណ្ឌកម្មចំពោះបទល្មើសណាមួយ ដែលកម្មវត្ថុរបស់បត្យាប័នត្រូវបានរាំងស្ទះដោយមូលហេតុមានចែងក្នុងច្បាប់នៃភាគីចុះកិច្ចព្រមព្រៀងណាមួយដោយរាប់បញ្ចូលទាំងច្បាប់ស្តីពីអាជ្ញាយុកាល ។

៥.ភាគីទទួលសំណើ បានចេញសាលក្រមកាត់ទោសជនដែលត្រូវស្នើសុំ ចំពោះបទល្មើសដដែលនេះរួចហើយ មុនពេលដាក់សំណើសុំធ្វើបត្យាប័ន ។

៦.ប្រសិនបើសាលក្រមរបស់ភាគីដាក់សំណើបានត្រូវធ្វើឡើងដោយកំបាំងមុខដោយជនជាប់ទោសពុំបានទទួលពត៌មានគ្រប់គ្រាន់ អំពីសវនាការកាត់ក្តីនេះ ឬ គ្មានឱកាសចាត់ចែង ការការពារក្តីរបស់ខ្លួន ឬ គ្មានឱកាសដើម្បីអោយសំណុំរឿងក្តីរបស់ខ្លួនបានត្រូវជំនុំជំរះឡើងវិញដោយមានវត្តមានរបស់ខ្លួន ។

## ប្រការទី ៤
## មូលដ្ឋាននៃការបដិសេធដោយឆន្ទានុសិទ្ធិ

ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ បត្យាប័នអាចបដិសេធបានក្នុងករណីណាមួយ ដូចខាងក្រោមនេះ :

១.យោងទៅតាមច្បាប់របស់ខ្លួន ភាគីទទួលសំណើមានយុត្តាធិការលើបទល្មើស ដែលជាកម្មវត្ថុរបស់សំណើបត្យាប័ន ហើយនឹងត្រូវរៀបចំនីតិវិធីជំនុំជំរះជនដែលត្រូវស្នើសុំដោយខ្លួនឯង ។

២.ភាគីទទួលសំណើ កំពុងតែធ្វើនីតិវិធីជំនុំជំរះក្តី លើជនដែលត្រូវស្នើសុំចំពោះបទល្មើសដដែលនេះ ។

៣.ក្នុងករណីពិសេសទាំងឡាយ ដោយគិតពីភាពធ្ងន់ធ្ងរនៃបទល្មើស និង ផលប្រយោជន៍ស្របច្បាប់របស់ភាគីដាក់សំណើ ភាគីទទួលសំណើអាចពិនិត្យឃើញថា បត្យាប័ននេះមានវិសមិតភាព នឹងទស្សនៈវិស័យផ្នែកមនុស្សធម៌ ដោយសារស្ថានភាពផ្ទាល់របស់ជនដែលត្រូវស្នើសុំ ។

៤.ប្រសិនបើបុគ្គលដែលត្រូវស្នើអោយធ្វើបត្យាប័ន ត្រូវបានគេកាត់ទោស ឬក៏ នឹងត្រូវចូលសវនាការ ឬ កាត់ទោសនៅក្នុងទឹកដីនៃភាគីដាក់សំណើ ដោយតុលាការ ឬ សាលាជំរះក្តីពិសេស ឬ បណ្តោះអាសន្នណាមួយ ។

## ប្រការទី ៥
## បត្យាប័នចំពោះពលរដ្ឋសាម៉ី

១.ភាគីចុះកិច្ចព្រមព្រៀងម្ខាងៗ មានសិទ្ធិបដិសេធការធ្វើបត្យាប័នពលរដ្ឋផ្ទាល់របស់ខ្លួន ។

២.ប្រសិនបើបត្យាប័នមិនត្រូវបានផ្តល់អោយ ដោយយោងទៅលើកថាខ័ណ្ឌទី១នៃមាត្រានេះ ភាគីទទួលសំណើត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ទៅតាមសំណូមពររបស់ភាគីដាក់សំណើ ។ ក្នុងករណីនេះ ភាគីដាក់សំណើត្រូវបញ្ជូនឯកសារ និង វត្ថុតាងដែលទាក់ទងនឹងបណ្តឹងក្តីនេះទៅភាគីទទួលសំណើ ។

៣. ទោះបីកថាខ័ណ្ឌទី២នៃមាត្រានេះ បានចែងដូច្នេះក៏ដោយ ភាគីទទួលសំណើពុំចាំបាច់ត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនដើម្បីចោទប្រកាន់ទេ ប្រសិនបើភាគីទទួលសំណើគ្មានយុត្តាធិការលើបទល្មើសនេះ ។

## ប្រការទី ៦
## វិធីផ្តល់ពត៌មាន

ក្នុងស្មារតីនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងត្រូវប្រាស្រ័យទាក់ទងគ្នាតាមរយៈផ្លូវទូតវៀរលែងតែមានបទបញ្ញត្តិផ្សេងចែងក្នុងសន្ធិសញ្ញានេះ ។

## ប្រការទី ៧
## សំណើបត្យាប័ន និង ឯកសារចាំបាច់ ដែលត្រូវភ្ជាប់ជាមួយ

១. សំណើបត្យាប័នត្រូវធ្វើជាលាយលក្ខអក្សរ ហើយត្រូវភ្ជាប់ជាមួយនូវ ៖

ក. ឯកសារ, សេចក្តីបញ្ជាក់ ឬ ភស្តុតាងផ្សេងទៀត មានលក្ខណៈគ្រប់គ្រាន់សំរាប់ពិពណ៌នាអំពីអត្តសញ្ញាណ និង ទីកន្លែងប្រហាក់ប្រហែលដែលជនត្រូវស្នើសុំកំពុងស្នាក់នៅ,

ខ. សេចក្តីបញ្ជាក់ លើកអង្គហេតុនៃបណ្តឹងក្តី,

គ. រាល់បទបញ្ញត្តិនៃច្បាប់ ដែលពិពណ៌នាអំពីធាតុសំខាន់ៗ និងការកំណត់នៃបទល្មើសដែលជាកម្មវត្ថុនៃបត្យាប័ន,

ឃ. រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការផ្តន្ទាទោសទៅលើបទល្មើស និង

ង. រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការកំណត់ពេលនៃការចោទប្រកាន់ ឬ ការអនុវត្តទណ្ឌកម្ម ចំពោះបទល្មើសប្រសិនបើមាន ។

២. សំណើបត្យាប័ន ដែលទាក់ទងនឹងជនដែលត្រូវស្នើសុំដើម្បីចោទប្រកាន់ ត្រូវភ្ជាប់ជាមួយផងដែរនូវ ៖

ក. សេចក្តីចំលងនៃដីកាចាប់ខ្លួន ដែលចេញដោយចៅក្រម ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតរបស់ភាគីដាក់សំណើ ។

ខ. ភស្តុតាងដែលអាចសំអាងបានសំរាប់ការចាប់ខ្លួន និង ការឃុំខ្លួនដើម្បីរង់ចាំការជំនុំជំរះក្តីរបស់ជននោះ ដោយរាប់បញ្ចូលទាំងភស្តុតាងដែលបញ្ជាក់ថា ជនដែលត្រូវស្នើសុំពិតជាជនដែលកំណត់ក្នុងដីកាចាប់ខ្លួនមែន ។

៣. ជាបន្ថែមទៅលើចំណុចទាំងឡាយ ដែលចែងក្នុងកថាខ័ណ្ឌ១នៃប្រការនេះ កាលណាសំណើបញ្ជូនទាក់ទងទៅនឹងជនដែលបានត្រូវកំណត់ទោសរួចហើយ សំណើនេះត្រូវភ្ជាប់មកជាមួយនូវ :

ក. សេចក្តីចំលងនៃសាលក្រមរបស់តុលាការនៃភាគីដាក់សំណើ,

ខ. ភស្តុតាងបញ្ជាក់ថា ជនដែលត្រូវស្នើសុំ ពិតជាជនដែលកំណត់ក្នុងសាលក្រម,

គ. សេចក្តីបញ្ជាក់បង្ហាញអំពីកំរិតដែលសាលក្រមនោះបានត្រូវអនុវត្តហើយ និង

ឃ. សេចក្តីបញ្ជាក់ទាក់ទងនឹងមធ្យោបាយតាមផ្លូវច្បាប់ ដែលមានសំរាប់បុគ្គលដើម្បីរៀបចំការការពារខ្លួនរបស់គេ ឬ ក៏ចាត់អោយមានការកាត់ក្តីសារឡើងវិញ ដោយមានវត្តមានបុគ្គលនោះ ចំពោះករណីដែលជននោះត្រូវបានសំរេចកំបាំងមុខ អោយជាប់ទោស ចំពោះបទល្មើសរបស់គាត់ ។

៤. រាល់ឯកសារទាំងអស់ដែលភាគីដាក់សំណើ ត្រូវបញ្ជូនអោយក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនៃសន្ធិសញ្ញានេះ ត្រូវចុះហត្ថលេខា ឬ បោះត្រាជាផ្លូវការ និង ភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសានៃភាគីទទួលសំណើ ឬ ជាភាសាអង់គ្លេស ។

## ប្រការទី ៨
## ពត៌មានបន្ថែម

ប្រសិនបើភាគីទទួលសំណើយល់ឃើញថា ពត៌មានដែលផ្តល់សំរាប់គាំទ្រសំណើបញ្ជូនពុំមានលក្ខណៈគ្រប់គ្រាន់ ស្របតាមសន្ធិសញ្ញាដែលអនុញ្ញាតអោយធ្វើបញ្ជូនបាន ភាគីនោះអាចស្នើសុំផ្តល់ពត៌មានបន្ថែមពីភាគីដាក់សំណើ ក្នុងរយៈពេលកំណត់ណាមួយសមស្រប ។ ប្រសិនបើភាគីដាក់សំណើខកខានពុំបានបញ្ជូនពត៌មានបន្ថែម តាមរយៈពេលកំណត់នោះ នឹងត្រូវចាត់ទុកថាបានលះបង់នូវសំណើរបស់ខ្លួន ។ ប៉ុន្តែភាគីដាក់សំណើ មិនត្រូវបានហាមឃាត់មិនអោយធ្វើសំណើនេះជាថ្មីទៀតនោះទេ ។

## ប្រការទី ៩
## ការចាប់ខ្លួនបណ្ដោះអាសន្ន

១. ក្នុងករណីបន្ទាន់ ភាគីចុះកិច្ចព្រមព្រៀងម្ខាង អាចស្នើទៅភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀតអោយធ្វើការចាប់ខ្លួនបណ្ដោះអាសន្ននូវជនដែលត្រូវស្នើសុំ ។ សំណើនេះអាចដាក់ជូនជាលាយល័ក្ខអក្សរតាមផ្លូវទូត ឬ តាមរយៈអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ ( អាំងទែរប៉ូល )។

២. សំណើសុំខាងលើត្រូវមាន :
- ការពិពណ៌នាអំពីជនដែលត្រូវស្នើសុំ
- ទីកន្លែងដែលជននោះស្ថិតនៅ ប្រសិនបើដឹង
- សេចក្ដីបញ្ជាក់សង្ខេប អំពីដំណើរហេតុនៃបណ្ដឹងក្ដី
- សេចក្ដីបញ្ជាក់ថា មានដីកាចាប់ខ្លួន ឬ សាលក្រមលើជននោះ ដូចមានចែងក្នុងប្រការទី៧ និង
- សេចក្ដីបញ្ជាក់ថា សំណើបញ្ជាប័នលើជនដែលត្រូវស្នើសុំនឹងត្រូវបញ្ជូនមក តាមក្រោយ ។

៣. ភាគីដាក់សំណើនឹងត្រូវបានទទួលដំណឹងពីលទ្ធផលនៃសំណើរបស់ខ្លួន ដោយគ្មានបង្អែបង្អង់ ។

៤. ការចាប់ខ្លួនបណ្ដោះអាសន្ននឹងត្រូវបញ្ចប់ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួលសំណើ ពុំបានទទួលសំណើបញ្ជាប័នជាផ្លូវការ និង រាល់ឯកសារសំអាងទាំងឡាយដូចដែលកំណត់ក្នុងប្រការទី៧ ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីការចាប់ខ្លួនជនដែលត្រូវសុំ ។ កថាខណ្ឌនេះ មិនត្រូវបានរារាំងដល់លទ្ធភាពក្នុងការដោះលែងដោយមានលក្ខខ័ណ្ឌជនដែលត្រូវស្នើសុំមុនផុតរយៈពេល ៦០ថ្ងៃនេះទេ ក្នុងករណីដែលភាគីទទួលសំណើមានមូលដ្ឋានបដិសេធដាច់ខាត ឬ ក៏មូលដ្ឋានបដិសេធដោយឆន្ទានុសិទ្ធិ ឬក៏ ក្នុងករណីដែលភាគីដាក់សំណើលុបចោលនូវសំណើបញ្ជាប័នរបស់ខ្លួន។

៥. ការបញ្ចប់នូវការចាប់ខ្លួនបណ្ដោះអាសន្នយោងតាមកថាខ័ណ្ឌ៤នៃប្រការនេះ មិនត្រូវមានផលប៉ះពាល់ដល់ការធ្វើបញ្ជាប័ននូវជនដែលត្រូវស្នើសុំនោះទេប្រសិនបើសំណើបញ្ជាប័ន

និង រាល់ឯកសារគាំទ្របត្យាប័នដូចមានចែងក្នុងប្រការទី៧ ត្រូវបានផ្តល់អោយក្នុងកាលបរិច្ឆេទក្រោយទៀត ។

## ប្រការទី ១០
## ការសំរេចចិត្តទៅលើការស្នើ

១. ភាគីទទួលសំណើត្រូវអនុវត្តពិនិត្យលើសំណើសុំបត្យាប័ន ស្របតាមនីតិវិធីចែងដោយច្បាប់របស់ខ្លួន និងត្រូវជូនពត៌មានយ៉ាងឆាប់រហ័សតាមរយៈផ្លូវទូត ទៅភាគីដាក់សំណើអំពីសេចក្តីសំរេចចិត្តរបស់ខ្លួន ។

២. ការបញ្ជាក់ពីមូលហេតុនៃការបដិសេធទាំងស្រុង ឬ ដោយអន្លើណាមួយលើសំណើសុំបត្យាប័ននោះត្រូវតែផ្តល់ជូន ។

## ប្រការទី ១១
## ការប្រគល់ខ្លួនជនដែលត្រូវបានស្នើសុំ

១. ប្រសិនបើបត្យាប័នត្រូវបានផ្តល់ឱ្យ ភាគីទទួលសំណើ និង ភាគីដាក់សំណើត្រូវសំរេច អំពីការអនុវត្តនីបត្យាប័នតាមរយៈការពិគ្រោះយោបល់គ្នា ។ ដើម្បីបំណងនេះភាគីទទួលសំណើ នឹងជូនពត៌មានដល់ភាគីដាក់សំណើពីរយៈពេលដែលជនដែលត្រូវស្នើសុំនោះត្រូវបានចាប់ឃុំឃាំងមុនពេលប្រគល់ខ្លួន ។

២. ល្គឹកណាកថាខ័ណ្ឌ ៣ នៃប្រការនេះ មិនមានចែងអ្វីមួយផ្ទុយពីនេះ ភាគីដាក់សំណើត្រូវ បានចាត់ទុកថាបានបោះបង់សំណើបត្យាប័ន ប្រសិនបើភាគីនេះពុំទទួលយកជនដែលត្រូវបានស្នើសុំ ក្នុងរយៈពេល១៥ថ្ងៃក្រោយពីកាលបរិច្ឆេទសំរាប់ការអនុវត្តធ្វើបត្យាប័ន ដូចដែលបានព្រមព្រៀងគ្នារួចហើយ ។ ភាគីទទួលសំណើត្រូវដោះលែងជននោះអោយមានសេរីភាពជាបន្ទាន់ហើយអាចបដិសេធការធ្វើបត្យាប័នចំពោះបទល្មើសដដែលនេះ ។

៣. ប្រសិនបើភាគីចុះកិច្ចព្រមព្រៀងណាមួយខកខានពុំបានប្រគល់ ឬ ទទួលជនដែលត្រូវស្នើសុំ ក្នុងថេរវេលាដែលបានព្រមព្រៀងគ្នា ដោយករណីប្រធានសក្តិភាគីម្ខាងទៀត

ត្រូវតែបានជូនពត៌មានពីបញ្ហានេះ ។ ភាគីចុះកិច្ចព្រមព្រៀងត្រូវសិរេចជាថ្មីម្តងទៀ តាមការពិគ្រោះគ្នាអំពីការអនុវត្តនីបត្យាប័នម្តងទៀត ហើយបទបញ្ញត្តិនៃកថាខណ្ឌទី ២ នៃប្រការនេះនឹងត្រូវអនុវត្ត ។

## ប្រការទី ១២
## ការពន្យារពេលនៃការប្រគល់ខ្លួន. និង ការប្រគល់ខ្លួនជាបណ្តោះអាសន្ន

១. នៅពេលណាដែលជនត្រូវស្នើសុំ កំពុងត្រូវស្ថិតក្នុងនីតិវិធីជំនុំជំរះក្តី ឬ កំពុងទទួលទោសក្នុងប្រទេសនៃភាគីទទួលសំណើ អំពីបទល្មើសណាមួយផ្សេងពីបទល្មើសជាកម្មវត្ថុរបស់បត្យាបន៍ ភាគីទទួលសំណើអាចប្រគល់ ឬ ពន្យារការប្រគល់ជននោះរហូតដល់ការបញ្ចប់នីតិវិធីជំនុំជំរះក្តី ឬ ការទទួលទោសទាំងស្រុង ឬ មួយផ្នែកណានៃទោសដែលកំណត់ក្នុងសាលក្រម ។ ភាគីទទួលសំណើត្រូវផ្តល់ដំណឹងជូនភាគីដាក់សំណើអំពីការពន្យារពេលនេះ ។

២. យោលទៅតាមធរមាននៃច្បាប់របស់ប្រទេសខ្លួន ក្នុងករណីដែលគេយល់ថា ជនម្នាក់អាចត្រូវធ្វើបត្យាប័នបាន ភាគីទទួលសំណើអាចប្រគល់ជនដែលត្រូវស្នើសុំជាបណ្តោះអាសន្នទៅភាគីដាក់សំណើ ដើម្បីធ្វើការចោទប្រកាន់ស្របទៅតាមលក្ខខណ្ឌ ដែលបានកំណត់រវាងភាគីទាំងពីរ ។ ជនណាម្នាក់ដែលត្រូវបានប្រគល់ទៅភាគីដាក់សំណើបន្ទាប់ពី ការប្រគល់ខ្លួនបណ្តោះអាសន្ន អាចត្រូវប្រគល់ជាស្ថាពរទៅភាគីដាក់សំណើ ដើម្បីទទួលទោសតាមសាលក្រមកំណត់ស្របតាមបទបញ្ញត្តិ នៃសន្ធិសញ្ញានេះ ។

## ប្រការទី ១៣
## សំណើបត្យាបន័ធ្វើឡើងដោយរដ្ឋជាច្រើន

ប្រសិនបើសំណើបត្យាប័នចំពោះតែជនម្នាក់ត្រូវបានធ្វើឡើងដោយភាគីចុះកិច្ចព្រមព្រៀងណាមួយ និងពីរដ្ឋដទៃផ្សេងមួយឬច្រើនទៀតផងនោះ ភាគីទទួលសំណើអាចកំនត់ពីអាទិភាពចំពោះសំណើណាមួយក្នុងចំណោមសំណើបត្យាប័នទាំងនោះ ។

## ប្រការទី ១៤
## វិធានពិសេស

១. ជនដែលត្រូវធ្វើបត្យាប័ន អនុលោមតាមសន្ធិសញ្ញានេះ មិនត្រូវទទួលការឃុំឃាំង ទទួលការកាត់ក្តី ឬ ការដាក់ទណ្ឌកម្ម នៅក្នុងដែនដីភាគីដាក់សំណើសំរាប់បទល្មើសផ្សេង ក្រៅពីបទល្មើសដែលបត្យាប័នបានត្រូវប្រគល់ជូនព្រមទាំងមិនត្រូវធ្វើបត្យាប័នបញ្ជូនទៅរដ្ឋផ្សេង ទៀតដោយភាគីនេះ លើកលែងតែក្នុងករណី :

ក. ជននោះបានចាកចេញពីដែនដីនៃភាគីដាក់សំណើ បន្ទាប់ពីការធ្វើបត្យាប័ន ហើយបានត្រឡប់មកដែនដីនេះវិញដោយស្ម័គ្រចិត្ត

ខ. ជននោះមិនបានចាកចេញពីដែនដីភាគីដាក់សំណើ ក្នុងរយៈពេល ៣០ថ្ងៃ ដែលទុកឱ្យជននោះមានសិទ្ធិចាកចេញ ឬ

គ. ភាគីទទួលសំណើបានយល់ព្រមឱ្យមានការឃុំឃាំង ការកាត់ក្តី ឬ ការដាក់ទណ្ឌកម្មចំពោះជននោះពីបទល្មើសផ្សេងក្រៅពីបទល្មើសដែលបានស្នើសុំឱ្យមានបត្យាប័ន ឬ យល់ព្រមឱ្យមានការធ្វើបត្យាប័នទៅរដ្ឋដទៃផ្សេងទៀត ។ ក្នុងស្ថានភាពនេះ ភាគីទទួលសំណើ អាចទាមទារឱ្យផ្តល់នូវឯកសារ ឬ សេចក្តីបញ្ជាក់ណាមួយ ដូចមានចែងក្នុងប្រការទី៧ រួមទាំងសេចក្តីបញ្ជាក់ដែលធ្វើឡើងដោយជនដែលត្រូវធ្វើបត្យាប័ន ចំពោះបទល្មើសដែលត្រូវពាក់ព័ន្ធ ។

២. បទប្បញ្ញត្តិទាំងនេះមិនត្រូវអនុវត្តចំពោះបទល្មើសទាំងឡាយណា ដែលបានប្រព្រឹត្តិ ក្រោយការធ្វើបត្យាប័នឡើយ ។

## ប្រការទី ១៥
## ការប្រគល់នូវទ្រព្យសម្បត្តិ

១. ក្នុងក្របខណ្ឌនៃច្បាប់របស់ប្រទេសខ្លួន និង យោងតាមសំណើនៃភាគីដាក់សំណើ ភាគីទទួលសំណើត្រូវរឹបអូសទ្រព្យសម្បត្តិ និង ក្រោយពីបានផ្តល់បត្យាប័ន ត្រូវប្រគល់ទ្រព្យសម្បត្តិៈ

ក. ដែលអាចតំរូវឱ្យធ្វើជាភស្តុតាង ឬ
ខ. ដែលត្រូវបានទទួលស្គាល់ថាជាទ្រព្យសម្បត្តិចេញពីលទ្ធផលនៃបទល្មើស ។

២.ទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះត្រូវរឹបអូស ឬ ប្រគល់ជូនស្របតាមកថាខ័ណ្ឌខាងលើទោះបីជាបត្យាបន៍ដែលត្រូវបានផ្តល់ឱ្យ មិនអាចអនុវត្តបានដោយមូលហេតុមកពីមរណៈភាព ការបាត់ខ្លួន ឬ ការគេចខ្លួននៃជនដែលត្រូវជាប់ចោទ ។

៣. កាលណាទ្រព្យសម្បត្តិដូចមានចែងខាងលើនេះ ជាកម្មសិទ្ធិនៃការដកហូត ឬ រឹបអូសនៅលើដែនដីនៃភាគីទទួលសំណើ ភាគីនេះអាចរក្សាទុកជាបណ្តោះអាសន្នទ្រព្យសម្បត្តិទាំងនេះ ឬ បញ្ជូនវាត្រឡប់ទៅវិញ ក្នុងលក្ខខណ្ឌដែលទ្រព្យសម្បត្តិទាំងនេះស្ថិតក្នុងការរង់ចាំនីតិវិធីព្រហ្មទណ្ឌ ។

៤.រាល់សិទ្ធិទាំងឡាយណា ដែលភាគីទទួលសំណើ ឬ រដ្ឋណាមួយ ឬ បុគ្គលណាមួយមានលើទ្រព្យសម្បត្តិដូចពោលខាងលើត្រូវបានរក្សាទុក ។ ក្រោយពីមានការជំនុំជំរះរួចទោះជាសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះនៅទីណាក៏ដោយ ទ្រព្យសម្បត្តិទាំងនេះត្រូវបញ្ជូនទៅភាគីទទួលសំណើតាមសំណូមពរនៃភាគីនេះភ្លាមដោយគ្មានបន្ទុកពន្ធអាករ បន្ទាប់ពីការជំនុំជំរះក្តី ។

## ប្រការទី ១៦
## ដំណើរឆ្លងកាត់

១. នៅពេលដែលជនម្នាក់ត្រូវបានធ្វើបត្យាបន៍បញ្ជូនពីរដ្ឋទីបីមកភាគីចុះកិច្ចព្រមព្រៀងណាមួយ ដោយឆ្លងកាត់ទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ភាគីដំបូងត្រូវស្នើសុំការ

អនុញ្ញាត្តិឆ្លងកាត់ពីភាគីម្ខាងទៀត ។ ការអនុញ្ញាត្តិបែបនេះ មិនត្រូវទាមទារទេ ក្នុងករណីដែលមានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស ហើយគ្មានការសុំសំចតលើទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ។

២. ភាគីទទួលសំណើ ត្រូវផ្តល់ជូនតាមសំណើនៃការសុំឆ្លងកាត់ដែលត្រូវបានស្នើដោយភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត លើកលែងតែការឆ្លងកាត់នេះមិនផ្ទុយពីច្បាប់ក្នុងប្រទេសខ្លួន ។

## ប្រការទី ១៧
## ការផ្តល់ពត៌មានអំពីលទ្ធផល

ភាគីដាក់សំណើត្រូវបញ្ជូនដំណឹងទៅភាគីទទួលសំណើ ឱ្យបានទាន់ពេលវេលានូវដំណឹងដែលពាក់ពន្ធ័ដល់ការចោទប្រកាន់ ការជំនុំជំរះ និង ការអនុវត្តន៏នូវការដាក់ទណ្ឌកម្ម ចំពោះជនដែលស្នើសុំ ឬ ពាក់ពន្ធ័ដល់ការធ្វើបត្យាបន៏បន្ត ចំពោះជនរូបនោះទៅរដ្ឋផ្សេងទៀត ។

## ប្រការទី ១៨
## ការឧបត្ថម្ភ និង ការចំណាយ

១. ភាគីទទួលសំណើត្រូវចេញមុខ ក្នុងនាមជាភាគីដាក់សំណើដោយចាត់ចែង និងអនុវត្តរាល់នីតិវិធីដែលចេញពីសំណើបត្យាបន៏ ។

២.ចំណាយសំរាប់បត្យាបន៏ ជាបន្ទុករបស់ភាគីដែលចំណាយនេះកើតឡើង ។ ចំណាយសំរាប់ការដឹកនាំតាមផ្លូវអាកាស និងការឆ្លងកាត់ដែលទាក់ទងនឹងការធ្វើបត្យាបន៏ជននោះ គឺជាបន្ទុករបស់ភាគីដាក់សំណើ ។

## ប្រការទី ១៩
## ទំនាក់ទំនងជាមួយនឹងអនុសញ្ញាពហុភាគី

សន្ធិសញ្ញានេះគ្មានប៉ះពាល់ផលដល់សិទ្ធិ និង កាតព្វកិច្ចទាំងឡាយដែលគូភាគីចុះកិច្ចព្រមព្រៀងបានទទួល និង គោរពក្នុងក្របខណ្ឌនៃអនុសញ្ញាពហុភាគីណាមួយឡើយ ។

## ប្រការទី ២០
## ដំណោះស្រាយនៃបញ្ហាវិវាទ

រាល់វិវាទដែលកើតចេញពីការអនុវត្តន៍ ឬ ការបកស្រាយនៃសន្ធិសញ្ញានេះ ត្រូវដោះស្រាយតាមការពិគ្រោះយោបល់ ឬ ការចរចា ។

## ប្រការទី ២១
## ការធ្វើវិសោធនកម្ម

សន្ធិសញ្ញានេះអាចធ្វើវិសោធនកម្មបាន តាមការស្នើសុំពីភាគីចុះកិច្ចព្រមព្រៀងណាមួយ ។ រាល់វិសោធនកម្មដែលបានយល់ព្រមដោយភាគីចុះកិច្ចព្រមព្រៀងតាមរយៈការពិគ្រោះផ្លូវទូត ត្រូវចូលជាធរមានចាប់ពីថ្ងៃដែលបានព្រមព្រៀងគ្នាទៅវិញទៅមក និងត្រូវបង្កើតជាផ្នែកមួយ រួមជាមួយនឹងកិច្ចព្រមព្រៀងនេះ ។

## ប្រការទី ២២
## ការផ្តល់សច្ចាបន៍ ការចូលជាធរមាន និង សុពលភាពនៃសន្ធិសញ្ញា

១. សន្ធិសញ្ញានេះត្រូវស្ថិតនៅជាកម្មវត្ថុនៃការសុំសច្ចាបន៍ ។ លិខិតូបករណ៍នៃការធ្វើសច្ចាបន៍ត្រូវប្តូរគ្នានៅភ្នំពេញ ។ សន្ធិសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃក្រោយពេលនៃការប្តូរលិខិតូបករណ៍នៃការធ្វើសច្ចាបន៍ ។

២. ភាគីនៃកិច្ចព្រមព្រៀងនីមួយៗអាចបញ្ចប់សន្ធិសញ្ញានេះបាន ដោយផ្តល់ដំណឹងជាលាយល័ក្ខអក្សរ ទៅភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតតាមរយៈផ្លូវទូត ។ សន្ធិសញ្ញានេះនឹងស្ថិតនៅជាធរមាន រហូតរយៈពេល៦ខែក្រោយពេលដែលភាគីម្ខាងទៀត ទទួលបានការផ្តល់ពត៌មានស្តីពីការបញ្ចប់នេះ ។ ការបញ្ចប់នៃសន្ធិសញ្ញានេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់នីតិវិធីនៃបត្យាបន៍នានា ដែលចាប់ផ្តើមអនុវត្តមុន ការបញ្ចប់សន្ធិសញ្ញានេះឡើយ ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋសាមីរៀងៗខ្លួន បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ។

ធ្វើជាពីរច្បាប់ នៅ ប៉េកាំង ថ្ងៃទី ...០៩... ខែ កុម្ភៈ ឆ្នាំ មួយពាន់ប្រាំបួនរយកៅសិបប្រាំបួន ជាភាសាខ្មែរ ភាសាចិន និង ភាសាអង់គ្លេស ។ អត្ថបទនីមួយៗមានតំលៃស្មើៗគ្នា ។ ក្នុងករណីមាន ការបកស្រាយខុសគ្នាអត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល ។

| | |
|---|---|
| តំណាងព្រះរាជាណាចក្រកម្ពុជា | តំណាងសាធារណរដ្ឋប្រជាមានិតចិន |

# ឧបសម្ព័ន្ធទី ២


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រមនីតិវិធីព្រហ្មទណ្ឌ
នៃ
ព្រះរាជាណាចក្រកម្ពុជា
ឆ្នាំ ២០០៧
ក្រសួងយុត្តិធម៌
Ministère de la Justice

# ព្រះរាជក្រម

នស/រកម/០៨០៧/០២៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ២
# បត្យាប័ន
## ផ្នែកទី ១
## បត្យាប័នដែលស្នើសុំដោយរដ្ឋបរទេស
### កថាភាគទី ១
### បត្យាប័ន

**មាត្រា ៥៦៦.** – បត្យាប័ននៃអាណិកជនបរទេសលើដែនដី

ព្រះរាជាណាចក្រកម្ពុជាអាចយល់ព្រមប្រគល់ដល់រដ្ឋបរទេស នូវអាណិកជនបរទេសដែលស្នាក់នៅលើដែនដីកម្ពុជា ហើយដែល :

-ជាកម្មវត្ថុនៃនីតិវិធីចោទប្រកាន់តាមផ្លូវតុលាការនៅក្នុងរដ្ឋនេះ ឬ

-ត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារដោយតុលាការនៃរដ្ឋនេះ ។

**មាត្រា ៥៦៧.** – សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ

បត្យាប័នអាណិកជនបរទេស ដែលត្រូវចាប់ខ្លួននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិនៃសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណី គ្មានសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជាទេ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកមកអនុវត្ត លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

**មាត្រា ៥៦៨.** – និយមន័យ : រដ្ឋធ្វើសំណើ បុគ្គលដែលគេទាមទារ

នៅក្នុងផ្នែកនេះត្រូវមានឈ្មោះហៅថា :

-រដ្ឋធ្វើសំណើ គឺរដ្ឋបរទេសដែលស្នើសុំឱ្យធ្វើបត្យាប័នអាណិកជនបរទេស

-បុគ្គលដែលគេទាមទារ គឺជាអាណិកជនបរទេស ដែលស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងដែលជាកម្មវត្ថុនៃពាក្យស្នើសុំឱ្យធ្វើបត្យាប័ន ។

### កថាភាគទី ២
### លក្ខខណ្ឌនៃបត្យាប័ន

**មាត្រា ៥៦៩.** – លក្ខខណ្ឌនៃបត្យាប័នទាក់ទងនឹងអំពើ

បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ

ជាបទល្មើសតាមច្បាប់របស់រដ្ឋផ្ញើសំណើផង និងតាមច្បាប់កម្ពុជាផង ទោះបីជា :

-អំពើដែលជាបទល្មើស ស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នាក្តី ឬ

-ឈ្មោះបទល្មើស ការប្រើបច្ចេកស័ព្ទ ឬនិយមន័យ ឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នាក្តី ឬ

-ធាតុផ្សំបទល្មើសនៃច្បាប់របស់រដ្ឋផ្ញើសំណើ ខុសគ្នាពីធាតុផ្សំបទល្មើសដែលកំណត់ដោយច្បាប់កម្ពុជាក៏ដោយ ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋផ្ញើសំណើ គឺជាការប្រព្រឹត្តិបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមាននៅកម្ពុជា ។

**មាត្រា ៥៧០.** – ករណីនៃការប៉ុនប៉ងប្រព្រឹត្តិបទល្មើស និងការសមគំនិត

ប្រសិនបើអំពើដែលត្រូវចោទប្រកាន់តាមច្បាប់នៃរដ្ឋផ្ញើសំណើ ជាការប៉ុនប៉ងប្រព្រឹត្តិបទល្មើស បត្យាប័នអាចធ្វើទៅបាន លុះត្រាតែការប៉ុនប៉ងប្រព្រឹត្តិបទល្មើសនោះត្រូវបានផ្តន្ទាទោសតាមច្បាប់កម្ពុជាដែរ ។

បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកមកអនុវត្តផងដែរលើករណីសមគំនិត ។

**មាត្រា ៥៧១.** – លក្ខខណ្ឌទាក់ទងនឹងទោសពន្ធនាគារ

បត្យាប័នអាចធ្វើបាន លុះត្រាតែអំពើដែលត្រូវចោទប្រកាន់ទៅលើបុគ្គលដែលគេទាមទារនោះមានកម្រិតអតិបរមានៃទោសពន្ធនាគារយ៉ាងតិចស្មើនឹង ២ (ពីរ) ឆ្នាំ តាមច្បាប់នៃរដ្ឋផ្ញើសំណើ ។

ប៉ុន្តែបត្យាប័នក៏អាចធ្វើបានដែរ ប្រសិនបើបុគ្គលដែលគេទាមទារនោះ ត្រូវបានតុលាការនៃរដ្ឋផ្ញើសំណើផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចបំផុតស្មើនឹង ៦ (ប្រាំមួយ) ខែ ហើយសេចក្តីសម្រេចផ្តន្ទាទោសនេះបានចូលជាស្ថាពររួចហើយ ទោះបីជាទោសដែលកំណត់ដោយច្បាប់មានថិរវេលាប៉ុន្មានក៏ដោយ ។

**មាត្រា ៥៧២.** – លក្ខខណ្ឌទាក់ទងនឹងទីកន្លែងប្រព្រឹត្តិបទល្មើស

កាលណាអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ ត្រូវបានប្រព្រឹត្តនៅលើដែនដីនៃរដ្ឋផ្ញើសំណើ បត្យាប័នក៏អាចធ្វើបានដែរ ទោះបីជាបុគ្គលដែលគេទាមទារមិនមានសញ្ជាតិរបស់រដ្ឋផ្ញើសំណើក៏ដោយ ។

កាលណាអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃរដ្ឋផ្ញើសំណើ បត្យាប័នអាចនឹងត្រូវធ្វើបាន លុះត្រាតែបុគ្គលដែលគេទាមទារនោះមានសញ្ជាតិរបស់រដ្ឋផ្ញើសំណើ ។

**មាត្រា ៥៧៣.** – អំពើដែលមានលក្ខណៈនយោបាយ

បត្យាប័នមិនអាចធ្វើបានទេ កាលណាអំពើដែលត្រូវចោទប្រកាន់ មានលក្ខណៈនយោបាយ ។

ប៉ុន្តែមិនត្រូវចាត់ទុកថា ជាបទល្មើសនយោបាយទេ ចំពោះអំពើហិង្សាដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិត ដល់បូរណភាពខាងរូបកាយ ឬដល់សេរីភាពរបស់បុគ្គល ។

**មាត្រា ៥៧៤.** – អំពើដែលត្រូវបានប្រព្រឹត្តលើដែនដី និងដែលត្រូវបានជំនុំជម្រះជាស្ថាពររួចហើយ

បត្យាប័នមិនអាចធ្វើបានទេ កាលណាអំពើដែលត្រូវចោទប្រកាន់បានប្រព្រឹត្តនៅលើដែនដីកម្ពុជា ហើយត្រូវបានជំនុំជម្រះជាស្ថាពររួចហើយនៅកម្ពុជា ។

**មាត្រា ៥៧៥.** – ការរលត់នៃបណ្តឹងអាជ្ញា

បត្យាប័នមិនអាចធ្វើបានទេ នៅក្នុងករណីដែលបណ្តឹងអាជ្ញាបានផុតរលត់តាមច្បាប់របស់រដ្ឋធ្វើសំណើ ។

កាលណាអំពើដែលត្រូវចោទប្រកាន់បានប្រព្រឹត្តនៅលើដែនដីកម្ពុជា បត្យាប័នមិនអាចធ្វើបានទេ នៅក្នុងករណីដែលបណ្តឹងអាជ្ញាត្រូវបានផុតរលត់តាមច្បាប់កម្ពុជា ។

**មាត្រា ៥៧៦.** – ពាក្យសុំធ្វើបត្យាប័នជាច្រើនទាក់ទងនឹងបុគ្គលតែម្នាក់

កាលណាមានរដ្ឋបរទេសច្រើនបានសុំធ្វើបត្យាប័នសំដៅលើបុគ្គលតែម្នាក់ដូចគ្នា ប្រសិនបើធ្វើបត្យាប័ននោះ ត្រូវពិចារណាគ្រប់ស្ថានភាពដូចខាងក្រោម :

-កាតព្វកិច្ចសន្ធិសញ្ញាពាក់ព័ន្ធ

-ភាពធ្ងន់ធ្ងរនៃបទល្មើស

-ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តិបទល្មើស

-កាលបរិច្ឆេទ និងលំដាប់មកដល់នៃសំណើសុំ

-សញ្ជាតិ លំនៅឋាន ទីសំណាក់នៃបុគ្គលដែលគេទាមទារ និងជនរងគ្រោះ

-លទ្ធភាពប្រគល់មកវិញនូវបុគ្គលដែលគេទាមទាររបស់រដ្ឋធ្វើសំណើ ។

**មាត្រា ៥៧៧.** – លក្ខខណ្ឌធ្វើបត្យាប័នទាក់ទងនឹងពាក្យសុំ

បត្យាប័នអាចធ្វើបាន លុះត្រាតែរដ្ឋធ្វើសំណើនោះសន្យាថា មិនធ្វើការចោទប្រកាន់ពីបទល្មើសណាមួយផ្សេងក្រៅពីបទល្មើសដែលចែងនៅក្នុងពាក្យស្នើសុំឱ្យធ្វើបត្យាប័ននោះទេ ហើយកាលណាបទល្មើសនោះបានប្រព្រឹត្តមុនពេលចាប់ខ្លួនបុគ្គលដែលគេទាមទារ ។

ប៉ុន្តែការចោទប្រកាន់អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីនេះ រដ្ឋធ្វើសំណើត្រូវជូនពាក្យស្នើសុំបន្ថែមមកអាជ្ញាធរកម្ពុជា ។

**មាត្រា ៥៧៨.** – ការឃុំខ្លួនបណ្ដោះអាសន្ន

កាលណាបុគ្គលដែលគេទាមទារនោះ ត្រូវបានចោទប្រកាន់តាមផ្លូវតុលាការនៅកម្ពុជា បត្យាប័ន ត្រូវព្យួរក្នុងខណៈដែលការចោទប្រកាន់កំពុងប្រព្រឹត្តទៅ ឬក្នុងករណីមានផ្ដន្ទាទោសនោះ បត្យាប័ន ត្រូវព្យួរដែរក្នុងខណៈដែលទោសមិនទាន់ត្រូវបានអនុវត្ត ។

ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា អាចយល់ព្រមឱ្យផ្ទេរបុគ្គលដែលគេទាមទារនោះ ជាបណ្ដោះអាសន្នទៅឱ្យរដ្ឋធ្វើសំណើ ដើម្បីជំនុំជម្រះនៅទីនោះ ។ រដ្ឋធ្វើសំណើត្រូវសន្យាថា នឹងប្រគល់បុគ្គលពាក់ព័ន្ធមកឱ្យអាជ្ញាធរកម្ពុជាវិញ ក្រោយពេលបញ្ចប់នីតិវិធីជំនុំជម្រះ ។

## កថាភាគទី ៣
## នីតិវិធីនៃបត្យាប័ន

**មាត្រា ៥៧៩.** – ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន

គ្រប់ពាក្យសុំធ្វើបត្យាប័នត្រូវតែជូនរដ្ឋាភិបាលកម្ពុជាតាមផ្លូវទូត ។ ពាក្យសុំនេះត្រូវមានលិខិតបញ្ជាក់ភស្តុតាងអមជាមួយផង ។

លិខិតបញ្ជាក់ភស្តុតាងត្រូវមាន :

-ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ

-របាយការណ៍អំពីអង្គហេតុដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ

-អត្ថបទច្បាប់ដែលអនុវត្តទៅលើអំពើនោះ និងទោសដែលត្រូវទទួលរង

-លិខិតចម្លងនៃសេចក្ដីសម្រេចផ្ដន្ទាទោសប្រសិនបើមាន ។

ឯកសារទាំងអស់ត្រូវចុះហត្ថលេខា បោះត្រាជាផ្លូវការ និងបិទស្រោម ហើយប្រសិនបើមិនមែនជាភាសាខ្មែរ បារាំង ឬអង់គ្លេស ត្រូវតែភ្ជាប់មកជាមួយនូវឯកសារបកប្រែជាភាសាមួយនៃភាសាទាំងបីនេះ ដោយមានសេចក្ដីបញ្ជាក់ផង ។

**មាត្រា ៥៨០.** – ការបញ្ជូនពាក្យសុំធ្វើបត្យាប័ន

រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាបញ្ជូនពាក្យសុំឱ្យធ្វើបត្យាប័ន និងលិខិតបញ្ជាក់ភស្តុតាងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្ទៀងផ្ទាត់មើលនិយតភាពនៃពាក្យសុំ និងបញ្ជូនពាក្យនោះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ ។

**មាត្រា ៥៨១.** – ពាក្យសុំឱ្យចាប់ខ្លួនបណ្ដោះអាសន្ន

រដ្ឋធ្វើសំណើឱ្យធ្វើបត្យាប័ន អាចសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន នូវបុគ្គលដែលគេទាមទារ ។

ក្នុងករណីបន្ទាន់ពាក្យសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន អាចធ្វើមុនពាក្យសុំឱ្យធ្វើបត្យាប័នដែលមានចែងនៅក្នុងមាត្រា ៥៧៩ (ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន) នៃក្រមនេះ ។

ពាក្យសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន ដែលមានគោលដៅរារាំងការគេចខ្លួនបុគ្គលដែលគេទាមទារ មិនតម្រូវឱ្យគោរពទម្រង់បែបបទដោយខ្សែកឡើយ ។

បុគ្គលដែលត្រូវស្ថិតនៅក្រោមនីតិវិធីនៃការចាប់ខ្លួនបណ្តោះអាសន្ន ត្រូវតែបានដោះលែងឱ្យមានសេរីភាពឡើងវិញដោយឯកឯង ប្រសិនបើរាជរដ្ឋាភិបាលពុំបានទទួលឯកសារទាំងឡាយដូចដែលមានចែងនៅក្នុងមាត្រា ៥៧៩ (ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន) នៃក្រមនេះក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចាប់ខ្លួន ទេនោះ ។

**មាត្រា ៥៨២.** – បញ្ជាឱ្យចាប់ខ្លួន និងឃុំខ្លួនចំពោះបុគ្គលដែលគេទាមទារ

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នៅភ្នំពេញអាចចេញបញ្ជាឱ្យចាប់ និងឃុំខ្លួនបុគ្គលដែលគេទាមទារ ។

បញ្ជានេះមានចុះនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណនៃបុគ្គលដែលគេទាមទារ

-ការយោងនៃពាក្យសុំឱ្យចាប់ខ្លួនជាបណ្តោះអាសន្នរបស់រដ្ឋបរទេស

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញបញ្ជានេះ ។

បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយអគ្គព្រះរាជអាជ្ញា និងមានបោះត្រាផង ។

បញ្ជាឱ្យចាប់ និងឃុំខ្លួនមានអានុភាពអនុវត្តនៅលើដែនដីកម្ពុជាទាំងមូល ។

**មាត្រា ៥៨៣.** – ការបង្ហាញបុគ្គលដែលគេទាមទារជូនព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច

ក្នុងករណីចាប់ខ្លួនបុគ្គលដែលគេទាមទារ ត្រូវតែនាំទៅបង្ហាញខ្លួនក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី ដែលត្រូវឱ្យដំណឹងដល់បុគ្គលនោះ អំពីបញ្ជាឱ្យចាប់ និងឃុំខ្លួន ហើយនិងទទួលចម្លើយពីបុគ្គលនេះ ។

បុគ្គលដែលគេទាមទារត្រូវផ្ទេរមកឃុំខ្លួននៅពន្ធនាគារភ្នំពេញ ។ បុគ្គលនោះអាចសុំឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញស្តាប់ចម្លើយខ្លួន ។

**មាត្រា ៥៨៤.** – ការប្តឹងទៅសភាស៊ើបសួរ

អគ្គព្រះរាជអាជ្ញារៀបចំសំណុំរឿង ដើម្បីប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ។

**មាត្រា ៥៨៥.** – នីតិវិធីនៅចំពោះមុខសភាស៊ើបសួរ

បុគ្គលដែលគេទាមទារ ត្រូវតែចូលបង្ហាញខ្លួននៅមុខសភាស៊ើបសួរ ។ បុគ្គលនេះអាចត្រូវអមដោយមេធាវីដែលខ្លួនជ្រើសរើស ឬដែលចាត់តាំងដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅក្នុងបន្ទប់សម្ងាត់ ។ នៅក្នុងករណីចាំបាច់ សភាស៊ើបសួរអាចហៅរកអ្នកបកប្រែ ។

ក្រោយពីបានស្តាប់ចម្លើយរបស់បុគ្គលដែលគេទាមទារ សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីរួចមក សភាស៊ើបសួរផ្តល់យោបល់ជាសាលដីកាដែលមានសំអាងហេតុស្តីពីពាក្យសុំឱ្យធ្វើបត្យាប័ននេះ ។

**មាត្រា ៥៨៦.** – យោបល់របស់សភាស៊ើបសួរ

សភាស៊ើបសួរផ្តល់យោបល់មិនយល់ព្រម ប្រសិនបើយល់ឃើញថាលក្ខខណ្ឌច្បាប់នៃបត្យាប័នមិនត្រូវបានបំពេញទេ ។

**មាត្រា ៥៨៧.** – ពាក្យសុំដោះលែងឱ្យនៅក្រៅឃុំរបស់បុគ្គលដែលគេទាមទារ

បុគ្គលដែលគេទាមទារ អាចសុំឱ្យគេដោះលែងឱ្យនៅក្រៅឃុំបាន ។

ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

ពាក្យសុំត្រូវដាក់ជូនសភាស៊ើបសួរ ដែលសម្រេចក្រោយពីបានស្តាប់ចម្លើយបុគ្គលដែលគេទាមទារ សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី ។

**មាត្រា ៥៨៨.** – ការយល់ព្រមឱ្យគេធ្វើបត្យាប័ន

ប្រសិនបើបុគ្គលដែលគេទាមទារ យល់ព្រមឱ្យគេបញ្ជូនខ្លួនតាមពាក្យសុំរបស់រដ្ឋធ្វើសំណើ ក្រោយពីបានទទួលព័ត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមចំពោះបត្យាប័ន សភាស៊ើបសួរត្រូវចុះនិទ្ទេសនេះនៅក្នុងសាលដីការបស់ខ្លួន ។

**មាត្រា ៥៨៩.** – អានុភាពនៃយោបល់របស់សភាស៊ើបសួរ

កាលណាបានទៅជាស្ថាពររួចហើយ សាលដីកានៃសភាស៊ើបសួរត្រូវបានជូនដំណឹងភ្លាមដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ប្រសិនបើសភាស៊ើបសួរផ្តល់យោបល់មិនយល់ស្របទេ បត្យាប័នមិនអាចធ្វើបានដោយរាជរដ្ឋាភិបាលកម្ពុជាទេ ។ បុគ្គលដែលគេទាមទារត្រូវបានដោះលែងឱ្យមានសេរីភាពវិញភ្លាម លើកលែងតែបុគ្គលនេះ ជាកម្មវត្ថុនៃសេចក្តីសម្រេចឱ្យឃុំខ្លួនពីរឿងផ្សេងទៀត ។

ប្រសិនបើសភាស៊ើបសួរបញ្ចេញយោបល់យល់ព្រម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចបញ្ជូនរឿងនេះទៅរាជរដ្ឋាភិបាល ដើម្បីចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នចំពោះបុគ្គលដែលគេទាមទារនោះ ។

កាលណាបត្យាប័នត្រូវបានបង្គាប់ បុគ្គលដែលគេទាមទារត្រូវបានប្រគល់ឱ្យដល់រដ្ឋធ្វើសំណើ ។ សោហ៊ុយក្នុងការធ្វើបត្យាប័នជាបន្ទុករបស់រដ្ឋធ្វើសំណើ ។ នៅពេលដែលបុគ្គលដែលគេទាមទារនោះ ចាកចេញផុតពីដែនដីកម្ពុជា ក្បួនការពារត្រូវទទួលខុសត្រូវដោយរដ្ឋធ្វើសំណើ ។

ប្រសិនបើរដ្ឋធ្វើសំណើ មិនបានចាប់ផ្ដើមនីតិវិធីធ្វើមាតុភូមិនិវត្តន៍នៅក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នទេ បុគ្គលដែលគេទាមទារត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។

## ផ្នែកទី ២
## បត្យាប័នដែលស្នើសុំដោយព្រះរាជាណាចក្រកម្ពុជាចំពោះរដ្ឋបរទេស

**មាត្រា ៥៩០.** – សមត្ថកិច្ចរបស់សភាស៊ើបសួរ

សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចដើម្បីពិចារណាលើនិយតភាពនៃបត្យាប័នដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួល ។

បុគ្គលដែលត្រូវបានធ្វើបត្យាប័ន មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពីពេលដែលសាមីខ្លួនមកដល់កម្ពុជា ដើម្បីលើកអំពីមោឃភាពនៃបត្យាប័ន ។

ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៥៩១.** – នីតិវិធីនៅចំពោះមុខសភាស៊ើបសួរ

សភាស៊ើបសួរធ្វើការសម្រេច ក្រោយពីបានស្ដាប់ចម្លើយរបស់បុគ្គលដែលត្រូវបានធ្វើបត្យាប័ន សេចក្ដីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្ដីសន្និដ្ឋានការពាររបស់មេធាវី ។

**មាត្រា ៥៩២.** – អានុភាពមិនផ្អាកនៃបណ្ដឹងសុំមោឃភាព

ពាក្យសុំមោឃភាពនៃបត្យាប័ន មិនផ្អាកនីតិវិធីចោទប្រកាន់ដែលកំពុងធ្វើទៅលើជនដែលត្រូវបានធ្វើបត្យាប័នឡើយ ។

**មាត្រា ៥៩៣.** – អានុភាពនៃមោឃកម្មចំពោះបត្យាប័ន

ប្រសិនបើបត្យាប័នត្រូវបានចាត់ទុកជាមោឃៈ ដោយសេចក្ដីសម្រេចជាស្ថាពររបស់សភាស៊ើបសួរ នីតិវិធីចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅត្រូវបញ្ចប់ ។ បុគ្គលដែលត្រូវបានធ្វើបត្យាប័នត្រូវបានដោះលែងឱ្យមានសេរីភាពវិញ និងមានលទ្ធភាពចាកចេញដោយសេរីពីដែនដីកម្ពុជា ។

ប៉ុន្តែ លុះផុតរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដោះលែងឱ្យមានសេរីភាព បុគ្គលដែលត្រូវបានធ្វើបត្យាប័ន អាចត្រូវបានគេចាប់ខ្លួនម្តងទៀតនៅលើដែនដីកម្ពុជា និងត្រូវជាកម្មវត្ថុនៃនីតិវិធីចោទប្រកាន់ជាថ្មីចំពោះអំពើដែលនាំឱ្យមានការធ្វើបត្យាប័នបុគ្គលនេះបាន ។

**មាត្រា ៥៩៤.** – ការយល់ព្រមរបស់រដ្ឋដែលបានប្រគល់អាណិកជនមកព្រះរាជាណាចក្រកម្ពុជា

កាលណាព្រះរាជាណាចក្រកម្ពុជាបានទទួលបត្យាប័ននៃអាណិកជនបរទេស ហើយក្រោយមកទៀតបានទទួលពាក្យប្តឹងសុំឱ្យធ្វើបត្យាប័នពីរដ្ឋបរទេសណាមួយផ្សេង ព្រះរាជាណាចក្រកម្ពុជានឹងអាចយល់ព្រមតាមពាក្យប្តឹងសុំនេះបាន ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋដែលបានប្រគល់អាណិកជននេះ មករាជរដ្ឋាភិបាលកម្ពុជា ។

ប៉ុន្តែការយល់ព្រមខាងលើនេះមិនជាការចាំបាច់ទេ កាលណាអាណិកជនបរទេសនេះមានលទ្ធភាពចាកចេញដោយសេរីពីដែនដីកម្ពុជារួចទៅហើយ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ។

## ជំពូកទី ៣
## ការឆ្លងកាត់

**មាត្រា ៥៩៥.** – ពាក្យសុំឆ្លងកាត់

ការឆ្លងកាត់ដែនដីកម្ពុជា ដោយបុគ្គលណាម្នាក់ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃនីតិវិធីបត្យាប័ន អាចត្រូវបានអនុញ្ញាត កាលណាបត្យាប័ននេះមិនទាក់ទងនឹងបទល្មើសនយោបាយទេ ។ ពាក្យសុំត្រូវធ្វើតាមផ្លូវទូត ។ ពាក្យសុំត្រូវតែមានលិខិតបញ្ជាក់ភស្តុតាងបញ្ជាក់ថាត្រឹមត្រូវអមជាមួយផង។

## ជំពូកទី ៤
## បទប្បញ្ញត្តិដោយឡែកស្តីពីការប្រតិបត្តិទោសមួយចំនួន

**មាត្រា ៥៩៦.** – បទប្បញ្ញត្តិស្តីពីការអនុវត្តទោសមួយចំនួន

ចំពោះវិវាទទាក់ទងនឹងការអនុវត្តទោស ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ តុលាការទទួលបណ្តឹងពីព្រះរាជអាជ្ញាតាមរយៈពាក្យសុំធម្មតា ។ អយ្យការឱ្យដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ ដល់ភាគីពាក់ព័ន្ធ ។

## ជំពូកទី ៥
## នីតិបុគ្គល

**មាត្រា ៥៩៧.** – សមត្ថកិច្ចទាក់ទងនឹងនីតិបុគ្គល

# គន្ថីទី ១១
# អវសានប្បញ្ញត្តិ
## ជំពូកទោល
## អវសានប្បញ្ញត្តិ

**មាត្រា ៦១១.** – និរាករណ៍នៃអត្ថបទច្បាប់ស្ដីពីនីតិវិធីពីមុន

បទប្បញ្ញត្តិដូចតទៅនេះត្រូវទុកជានិរាករណ៍ ៖

- រាល់បទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌ មុនឆ្នាំ ១៩៩២
- បទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌនៃបទប្បញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩២
- ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើដោយក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៣
- ព្រះរាជក្រមលេខ ០៨៩៩/០៩ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន
- ច្បាប់ស្ដីពីវិសោធនកម្មមាត្រា ៣៦ មាត្រា ៣៨ មាត្រា ៩០ និងមាត្រា ៩១ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០២/០០៥ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០២

បទប្បញ្ញត្តិស្ដីពីនីតិវិធីនៃច្បាប់ស្ដីពីការរចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣ ពុំអាចអនុវត្តចំពោះរឿងព្រហ្មទណ្ឌបានឡើយ ។

**មាត្រា ៦១២.-** ការអនុវត្តភ្លាមនូវក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនេះត្រូវអនុវត្តភ្លាម ចំពោះគ្រប់កិច្ចនីតិវិធីក្រោយក្រមនេះចូលជាធរមាន ។

ការអនុវត្តភ្លាមនូវបទប្បញ្ញត្តិនៃក្រមនេះ ពុំមានអានុភាពលើសុពលភាពនៃកិច្ចនីតិវិធីទាំងឡាយដែលត្រូវបានបំពេញរួចរាល់ហើយ ដោយអនុលោមតាមច្បាប់ចាស់ឡើយ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៧០៨.៣៧១

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ:៣៤៩ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

៥៣៨/២៤០

# ឧបសម្ព័ន្ធទី ៣

# ច្បាប់

# ស្តីពី

# ការប្រឆាំងនឹងភេរវកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

នស/រកម/០៧០៧/០១៨

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បទល្មើសមិនដូចគ្នាក្តី និង

គ-ការកំណត់អំពីធាតុផ្សំនៃបទល្មើសនៃច្បាប់របស់រដ្ឋធ្វើសំណើខុសគ្នាអំពីធាតុផ្សំនៃបទល្មើស ដែលកំណត់ដោយច្បាប់នេះ ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើ ឬ ការគេចវេះ ដែលត្រូវបានបង្ហាញដោយរដ្ឋធ្វើសំណើជាបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះត្រូវបានប្រព្រឹត្ត ។

## មាត្រា ៩៣.- បទល្មើសនយោបាយ និងសារពើពន្ធ

បទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ និងបទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស នឹងពុំត្រូវបានចាត់ទុកថាជាបទល្មើសនយោបាយឡើយ ចំពោះបទល្មើសពាក់ព័ន្ធនឹងបទល្មើសនយោបាយ ឬ បទល្មើសដែលកើតឡើងដោយហេតុផលនយោបាយ ឬជាបទល្មើសសារពើពន្ធឡើយ សម្រាប់គោលបំណងធ្វើបត្យាប័ន និងជំនួយទៅវិញទៅមក ។

## ផ្នែកទី ២

## បត្យាប័ន

## មាត្រា ៩៤.- បត្យាប័នទៅកាន់ ឬ មកពីរដ្ឋបរទេសដែលព្រះរាជាណាចក្រកម្ពុជាមានសន្ធិ-សញ្ញាបត្យាប័នជាមួយ

បទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ និងបទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស នឹងត្រូវបានចាត់ទុកជាបទល្មើសបត្យាប័ន ក្រោមសន្ធិសញ្ញាបត្យាប័នណាមួយរវាងព្រះ-រាជាណាចក្រកម្ពុជា និងរដ្ឋបរទេសនោះ ។

## មាត្រា ៩៥.- បត្យាប័នទៅកាន់រដ្ឋបរទេសដែលព្រះរាជាណាចក្រកម្ពុជាមិនមានសន្ធិសញ្ញា-បត្យាប័នជាមួយ ប៉ុន្តែជាភាគីមួយនៃអនុសញ្ញា ឬ ពិធីសារពាក់ព័ន្ធ

អនុសញ្ញា ឬពិធីសារ អាចបង្កើតបានជាមូលដ្ឋានច្បាប់សម្រាប់ការធ្វើបត្យាប័នបុគ្គលណាមួយ ចេញពីព្រះរាជាណាចក្រកម្ពុជាទៅកាន់រដ្ឋបរទេស ឬ សម្រាប់ធ្វើសំណើដោយព្រះរាជាណាចក្រកម្ពុជា ចំពោះរដ្ឋបរទេសនោះ ទាក់ទងនឹងអំពើដែលអនុសញ្ញា ឬពិធីសារនោះចែង ក្នុងករណីដែល :

ក-ព្រះរាជាណាចក្រកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋបរទេស និង

ខ-ទាំងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបរទេសនោះ គឺជាភាគីនៃអនុសញ្ញា ឬ ពិធីសារដែលភ្ជាប់មកជាឧបសម្ព័ន្ធនៃច្បាប់នេះ និង

គ-អនុសញ្ញា ឬ ពិធីសារនោះ ចែងថាវាអាចផ្តល់មូលដ្ឋានច្បាប់សម្រាប់បត្យាប័ន ។

**មាត្រា ៩៦.- បត្យាប័នទៅកាន់រដ្ឋបរទេសដែលប្រទេសកម្ពុជា មិនមានសន្ធិសញ្ញាបត្យាប័នជាមួយ**

ប្រទេសកម្ពុជា អនុលោមតាមច្បាប់ទាក់ទិននឹងបត្យាប័ន អាចធ្វើបត្យាប័នបុគ្គលណាមួយទៅឱ្យរដ្ឋធ្វើសំណើក្នុងករណីដែល :

ក-រាជរដ្ឋាភិបាលកម្ពុជា ទទួលសំណើពីរដ្ឋណាមួយសុំធ្វើបត្យាប័នបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះអំពើដែលបានបង្កជាបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេសនោះ ដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ និង

ខ-ប្រទេសកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋធ្វើសំណើ ហើយ

គ-រដ្ឋធ្វើសំណើផ្តល់ការសន្យាថា ខ្លួននឹងអនុវត្តតាមសំណើដូចគ្នានេះ ពីព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៩៧.- ការបង្ហាញឯកសារសម្រាប់សំណើសុំធ្វើបត្យាប័ន**

១-សំណើសុំធ្វើបត្យាប័នបុគ្គលណាមួយទៅកាន់រដ្ឋបរទេស ត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរដែលភ្ជាប់ជាមួយ :

ក-ក្នុងគ្រប់ករណីទាំងអស់នូវ :

ក.១-ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ ក្នុងការពិពណ៌នាអត្តសញ្ញាណនិងទីកន្លែងប្រហាក់ប្រហែលនៃបុគ្គលដែលត្រូវបានតាមរក និង

ក.២-របាយការណ៍អំពីអង្គហេតុនៃករណីនេះ និង

ក.៣-អត្ថបទនៃមាត្រាពាក់ព័ន្ធនៃច្បាប់ដែលបង្កើតបទល្មើសនោះនិង

ក.៤-អត្ថបទនៃមាត្រាពាក់ព័ន្ធនៃច្បាប់ដែលកំណត់ទោសប្បញ្ញត្តិនិង

ក.៥-អត្ថបទនៃមាត្រាពាក់ព័ន្ធនៃច្បាប់ ដែលបញ្ជាក់ការកំណត់ពេលវេលាដែលពាក់ព័ន្ធ និង

ក.៦-ព័ត៌មានដទៃណាទៀតដែលចាំបាច់ត្រូវផ្តល់ជូន ក្រោមសន្ធិសញ្ញាដែលនៅក្នុងនោះព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបរទេស គឺជាភាគី និង

ខ-ក្នុងករណីដែលបុគ្គលនោះត្រូវបានស្វែងរក ដើម្បីទទួលការអនុវត្តទោសដោយ :

ខ.១-សាលក្រម ឬ សេចក្តីចម្លងសាលក្រមមួយច្បាប់របស់តុលាការ និង

ខ.២-សេចក្តីថ្លែងការណ៍អំពីកម្រិតទោស ដែលការកាត់ទោសបានត្រូវអនុវត្ត ។

២-ឯកសារទាំងអស់ត្រូវតែត្រូវបានចុះហត្ថលេខា បោះត្រាជាផ្លូវការ និងបិទស្រោម ហើយប្រសិនបើមិនមែនជាភាសាខ្មែរ ឬ អង់គ្លេស ត្រូវតែភ្ជាប់មកជាមួយនូវឯកសារបកប្រែជាភាសាមួយនៃភាសាទាំងពីរនេះ ដែលមានសេចក្តីបញ្ជាក់ផង ។

**មាត្រា ៩៨.- មូលហេតុចាំបាច់សម្រាប់បដិសេធសំណើធ្វើបត្យាប័ន**

១-រាជរដ្ឋាភិបាលកម្ពុជាមិនត្រូវយល់ព្រមតាមសំណើសុំធ្វើបត្យាប័នបុគ្គលណាម្នាក់ចំពោះបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេសដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះឡើយ ប្រសិនបើយល់ឃើញថា :

ក-សំណើនោះត្រូវបានធ្វើឡើងដើម្បីកាត់ទោស ឬ ផ្តន្ទាទោសបុគ្គលណាម្នាក់ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ ដើមកំណើត ជាតិពន្ធ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ

ខ-ស្ថានភាពរបស់បុគ្គលនោះ អាចត្រូវរងបុរេនិច្ឆ័យ ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ ដើមកំណើតជាតិពន្ធ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ

គ-បុគ្គលនោះ ត្រូវបានកាត់ទោសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋបរទេសណាមួយ ចំពោះបទល្មើសនោះ ហើយសាលក្រមបានចូលជាស្ថាពរ និងត្រូវបានអនុវត្តចំពោះបុគ្គលនោះហើយ ឬ

ឃ-បុគ្គលនោះត្រូវបានផ្តន្ទាទោសពីបទល្មើសនោះដោយកំបាំងមុខ និង :

ឃ.១-ដោយពុំមានការជូនព័ត៌មានគ្រប់គ្រាន់អំពីការកាត់ទោសនោះ ឬ ដោយបុគ្គលនោះពុំត្រូវបានផ្តល់ឱកាសឱ្យរៀបចំការការពារខ្លួន និង

ឃ.២-ដោយបុគ្គលនោះពុំមាន ឬ នឹងពុំមានឱកាសសុំឱ្យមានការកាត់ទោសករណីនោះឡើងវិញ ដោយមានវត្តមានរបស់ខ្លួន ។

២-រាជរដ្ឋាភិបាលកម្ពុជាមិនត្រូវយល់ព្រមតាមសំណើសុំធ្វើបត្យាប័នបុគ្គលណាម្នាក់ ចំពោះបទល្មើសក្រោមច្បាប់របស់រដ្ឋបរទេស ដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះឡើយ ប្រសិនបើយល់ឃើញថានៅពេលប្រគល់ឱ្យទៅរដ្ឋបរទេសនោះ បុគ្គលនោះនឹងទទួលរងនូវការធ្វើទារុណកម្ម ។

**មាត្រា ៩៩.- បច្ច័យនៃការបដិសេធមិនធ្វើបត្យាប័ន**

ក្នុងករណីដែលរាជរដ្ឋាភិបាលកម្ពុជា ដោយមូលហេតុណាមួយបដិសេធការធ្វើបត្យាប័នបុគ្គលណាមួយ ទៅឱ្យរដ្ឋធ្វើសំណើ ក្រោយការពិចារណាសមស្របលើសំណើបត្យាប័ន :

ក-រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែបញ្ជូនសំណុំរឿងនេះ ទៅឱ្យអាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ដើម្បីគោលបំណងនៃការចោទប្រកាន់ និង

ខ-អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ត្រូវតែធ្វើសេចក្តីសម្រេចចិត្តលើសំណុំរឿង ដូចគ្នានឹងករណីនៃបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១០០.- បត្យាប័នដោយស្ម័គ្រចិត្ត**

១-រាជរដ្ឋាភិបាលកម្ពុជា អាចយល់ព្រមដោយពុំចាំបាច់ធ្វើចំណាត់ការបត្យាប័នផ្លូវការឡើយ ចំពោះការធ្វើបត្យាប័នបុគ្គលណាមួយ ចំពោះបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ប្រសិនបើបុគ្គលនោះយល់ព្រមជាលាយល័ក្ខណ៍អក្សរ នៅចំពោះមុខតំណាងទទួលខុសត្រូវនៃអាជ្ញាធរទទួលបន្ទុកចោទប្រកាន់ថា សុខចិត្តទទួលរងការធ្វើបត្យាប័នទៅកាន់រដ្ឋធ្វើសំណើចំពោះបទល្មើសនោះ ។

២-រាជរដ្ឋាភិបាលកម្ពុជា មិនត្រូវយល់ព្រមចំពោះបត្យាប័នតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើឡើយ លុះត្រាណាតែ :

ក-រដ្ឋធ្វើសំណើបានធ្វើសំណើផ្លូវការ សុំធ្វើបត្យាប័នបុគ្គលនោះ និង

ខ-មុនពេលដែលការយល់ព្រមត្រូវបានផ្តល់ ជននោះត្រូវតែបានទទួលព័ត៌-មានពេញលេញអំពីផលវិបាកនៃការយល់ព្រមលើបត្យាប័ន ។

**មាត្រា ១០១.- ការចាប់ខ្លួន ការឃាត់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្ន**

១-មាត្រានេះត្រូវអនុវត្ត ប្រសិនបើ :

ក-អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ ទទួលសំណើពីរដ្ឋបរទេសណាមួយដោយផ្ទាល់ ឬ តាមរយៈការសម្របសម្រួលនៃអង្គការនគរបាល ព្រហ្មទណ្ឌអន្តរជាតិ សុំឱ្យធ្វើការចាប់ខ្លួនបុគ្គលណាម្នាក់បណ្តោះអាសន្ន ចំពោះបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ហើយមានករណីណាមួយនៃករណីខាងក្រោមនេះ :

ក.១-ព្រះរាជាណាចក្រកម្ពុជា ជាភាគីនៃសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋដែលស្នើសុំជំនួយ ឬ

ក.២-ទាំងព្រះរាជាណាចក្រកម្ពុជា ទាំងរដ្ឋបរទេសនោះ គឺជាភាគីនៃអនុសញ្ញា ឬ ពិធីសារដែលភ្ជាប់មកជាឧបសម្ព័ន្ធ ១ នៃច្បាប់នេះ និងអនុសញ្ញា ឬ ពិធីសារនោះ ចែងថាវាអាចផ្តល់មូលដ្ឋានច្បាប់សម្រាប់បត្យាប័ន ឬ

ក.៣-រដ្ឋធ្វើសំណើផ្តល់ការសន្យាថាខ្លួននឹងអនុវត្តតាមសំណើដូចគ្នានេះពីព្រះរាជាណាចក្រកម្ពុជា និង

ខ-រដ្ឋធ្វើសំណើសន្យានឹងផ្ញើជូនព្រះរាជាណាចក្រកម្ពុជានូវសំណើសុំធ្វើបត្យាប័នបុគ្គលនោះ ។

២-អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ អាចចេញដីកាចាប់ខ្លួនបុគ្គលនោះ ប្រសិនបើពិនិត្យឃើញថា :

ក-បុគ្គលនោះ មានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយ

ខ-ទោះបីជា :

ខ.១-តុលាការ ឬ អាជ្ញាធរនៅក្នុងរដ្ឋធ្វើសំណើបានចេញដីកា ឬបញ្ជាដែលមានលក្ខណៈដូចគ្នា ដើម្បីចាប់ខ្លួនបុគ្គលនោះរួចហើយ ចំពោះបទល្មើសទាក់ទងនឹងដីកាចាប់ខ្លួនបណ្តោះអាសន្ន ដែលត្រូវបានសុំនោះ ឬ

ខ.២-បុគ្គលនោះត្រូវបានសម្រេចឱ្យជាប់ទោសចំពោះបទល្មើសនោះរួចហើយ នៅក្នុងរដ្ឋធ្វើសំណើ ។

៣-ផ្អែកតាមកថាខណ្ឌទី ៤ ខាងក្រោមនេះ បុគ្គលដែលត្រូវចាប់ខ្លួន និងឃុំខ្លួនតាមដីកានឹងត្រូវឃុំខ្លួនតាមច្បាប់រហូតទាល់តែរដ្ឋធ្វើសំណើ ស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើបត្យាប័នបុគ្គលនោះ ។

៤-ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា មិនបានទទួលសំណើសុំធ្វើបត្យាប័នពីរដ្ឋធ្វើសំណើក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃ បន្ទាប់ពីបុគ្គលនោះត្រូវបានឃុំខ្លួនតាមដីកា អាជ្ញាធរទទួលបន្ទុកចោទប្រកាន់ត្រូវតែចេញបញ្ជាឱ្យដោះលែងបុគ្គលនោះ ។

៥-បុគ្គល ដែលត្រូវបានដោះលែង យោងតាមកថាខណ្ឌទី ៤ ខាងលើនេះ អាចត្រូវចាប់ខ្លួនសាជាថ្មី ប្រសិនបើរដ្ឋធ្វើសំណើបញ្ជូនសំណើសុំធ្វើបត្យាប័ន បន្ទាប់ពីបុគ្គលនោះត្រូវបានដោះលែង ។

**មាត្រា ១០២.- បត្យាប័នមកពីរដ្ឋបរទេសដែលព្រះរាជាណាចក្រកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយ**

១-រាជរដ្ឋាភិបាលកម្ពុជា អាចធ្វើសំណើទៅរដ្ឋបរទេសសុំធ្វើបត្យាប័នបុគ្គលណាមួយមកព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែល :

ក-បុគ្គលនោះ បានប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ :

ក.១-នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

ក.២-នៅក្រៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែស្ថិតនៅក្នុងយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា តាមបញ្ញត្តិនៃច្បាប់នេះ ហើយ

ខ-ព្រះរាជាណាចក្រកម្ពុជា មិនមានសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋបរទេសដែលបុគ្គលនោះមានវត្តមាន ។

២-សំណើអាចត្រូវបានធ្វើឡើងផ្អែកលើមូលដ្ឋាននៃការផ្ដល់ ដោយរាជរដ្ឋាភិបាលកម្ពុជា នូវការសន្យាថាខ្លួននឹងអនុវត្តតាមសំណើដូចគ្នានេះពីរដ្ឋបរទេសដែលបុគ្គលនោះមានវត្តមាន ។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

**មាត្រា ១១១.- ការអនុវត្ត**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម/០៧០៧/៣១១ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍនា**

លេខៈ ៣០៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ខែកក្កដា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ឧបសម្ព័ន្ធទី ៤



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..១១..អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្គាប់ឱ្យធ្វើបត្យាប័ន

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញកំណត់ទូតលេខ ១-២/២០១០ ចុះថ្ងៃទី ២៩-៦ និង ០៦-៧-២០១០ របស់ស្ថានទូតស៊ុយអែតនៅទីក្រុងបាងកក

-បានឃើញសាលដីកាលេខ ៨៨ "ស" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្គាប់ឱ្យធ្វើបត្យាប័នចំពោះឈ្មោះ LITMANEN HANNU TAPANI ជនជាតិហ្វាំងឡង់ ភេទប្រុស អាយុ ៣១ឆ្នាំ កើតនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៩ ទីកន្លែងកំណើត ANGERED SWEDEN តាមការស្នើសុំរបស់ស្ថានទូតស៊ុយអែត ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច ✓
- ឯកសារ - កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៥

ឆ្នាំទី១៧ លេខ ៨៣ ត្រីមាសទី ០៤ ឆ្នាំ ២០១៧ រាជកិច្ច ទំព័រ ៩០៥០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១២១៥ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្គាប់ឱ្យធ្វើបត្យាប័ន**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៨០ អនក្រ.បក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញកំណត់ចុតលេខ ១៣៤ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១ របស់ស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា
- បានឃើញសាលដីកាលេខ ៣៦០ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦ របស់តុលាការកំពូល
- បានឃើញសាលដីកាកែតម្រូវលេខ ១០០ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ របស់តុលាការកំពូល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សម្រេច**

**មាត្រា១.-**

ត្រូវបានបង្គាប់ឱ្យធ្វើបត្យាប័នចំពោះឈ្មោះ: **BATALIN VLADIMIR VALERIEVICH** ភេទប្រុស អាយុ ៣៨ ឆ្នាំ ទីកន្លែងកំណើតនៅទីក្រុង ZKYA ប្រទេសរុស្ស៊ី តាមការស្នើសុំរបស់ស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៦

# បត្យាប័ន

ឯកឧត្តម ផូវ សំទី អគ្គនាយកកិច្ចការរដ្ឋបាលតុលាការ

ខែមករា ឆ្នាំ២០១៨

## មាតិកា

- សន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀង
- ទិដ្ឋភាពទូទៅ
- និយមន័យ
- លក្ខខណ្ឌធ្វើបត្យាប័ន
- នីតិវិធីនៃបត្យាប័ន
- បត្យាប័នដែលស្នើសុំដោយកម្ពុជាចំពោះរដ្ឋបរទេស
- ពាក្យសុំឆ្លងកាត់

# សន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិជាអ្វី?

- ការរៀបចំសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងមានការកំណត់នៅមាត្រា៧ នៃអនុសញ្ញា Vienna Convention on the Law of Treaties ឆ្នាំ១៩៦៩ ។
- សន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀង អាចធ្វើជាទ្វេភាគី ឬពហុភាគី ទៅតាមការព្រមព្រៀង និងការឯកភាពគ្នាថាបង្កើតជាទ្វេភាគី ឬពហុភាគី ទៅតាមកម្មវត្ថុនៃការធ្វើសន្ធិសញ្ញា។
- ការរៀបចំសន្ធិសញ្ញា ត្រូវផ្អែកលើច្បាប់រដ្ឋដែលមានរដ្ឋធម្មនុញ្ញាចម្បង អាចភ្ជាប់ទៅនឹងសន្ធិសញ្ញាអន្តរជាតិ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍រដ្ឋ ហើយច្បាប់រដ្ឋក៏មិនអាចជំទាស់នឹងសន្ធិសញ្ញាអន្តរជាតិដែលរដ្ឋនោះបានផ្តល់សច្ចាប័នរួចរាល់ផងដែរ។ ប៉ុន្តែបើសិនមានប៉ះពាល់នឹងផលប្រយោជន៍ជាតិ ឬមិនចំណេះអ្វីណាមួយនោះពីសន្ធិសញ្ញានេះ រដ្ឋនោះអាចស្នើសុំលុបចោល ឬដកខ្លួនចេញពីសន្ធិសញ្ញានោះបាន។

# សន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀង រវាងកម្ពុជា ជាមួយរដ្ឋបរទេស

- សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-ថៃ ឆ្នាំ១៩៩៨
- សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-ចិន ឆ្នាំ១៩៩៩
- សន្ធិសញ្ញា ស្តីពីបត្យាប័ន រវាងកម្ពុជា-ឡាវ ឆ្នាំ១៩៩៩
- កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងកម្ពុជា-កូរ៉េ ឆ្នាំ២០០៩
- អនុសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-បារាំង ឆ្នាំ២០១៥
- សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-រុស្ស៊ី ឆ្នាំ២០១៧
- សន្ធិសញ្ញាអាស៊ាន ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ឆ្នាំ២០០៤

# ចិដ្ឋភាពទូទៅ

## ក្រមនីតិវិធីព្រហ្មទណ្ឌ

- អាចយល់ព្រមដល់រដ្ឋបរទេសនូវអេណិកជនបរទេស ស្នាក់នៅកម្ពុជា ៖
  - កម្មវត្ថុនៃនីតិវិធីចោទប្រកាន់
  - ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ (មាត្រា ៥៦៦)
- សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ៖ បត្យាប័នអេណិកជនបរទេស ដែលត្រូវបានចាប់ខ្លួនលើដែនដីកម្ពុជា ត្រូវបានគ្រប់គ្រងដោយសន្ធិសញ្ញា និងអនុសញ្ញាអន្តជាតិដែលបានផ្តល់សច្ចាប័នដោយកម្ពុជា
- ក្នុងករណីគ្មានសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ដែលត្រូវបានទទួលសច្ចាប័នដោយកម្ពុជា បញ្ញាតិនៃករណីនេះ ត្រូវបានយកមកអនុវត្ត លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេងទៀត (មាត្រា ៥៦៧)

# ចិដ្ឋភាពទូទៅ (ត)

## សន្ធិសញ្ញាអន្តរជាតិ

- លើកកម្ពស់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពក្នុងការបង្ក្រាបបទល្មើសដោយឈរលើមូលដ្ឋានគោរពអធិបតេយ្យភាពគ្នាទៅវិញទៅមកសមភាព និងផលប្រយោជន៍រួមទាំងសងខាងតាមរយៈការចុះសន្ធិសញ្ញាបត្យាប័ន
- ដោយអនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញា ភាគីយល់ព្រមធ្វើបត្យាប័នទៅឲ្យភាគីម្ខាងទៀតនូវជនទាំងឡាយដែលមានវត្តមាននៅលើដែនដីរបស់ខ្លួនដែលភាគីម្ខាងទៀតកំពុងតែស្វែងរក ដើម្បីធ្វើការចោទប្រកាន់ ជំនុំជម្រះ ឬអនុវត្តទោស ចំពោះបទល្មើសដែលអាចធ្វើបត្យាប័នបាន
- សន្ធិសញ្ញានេះមិនមានឥទ្ធិពលដល់សិទ្ធិនិងកាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងសន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា លិខិតុបករណ៍អន្តរជាតិផ្សេងទៀតដែលគូភាគីជាសមាជិកឡើយ

# និយមន័យ

មានអត្ថន័យ ២យ៉ាង គឺ ៖

1. រដ្ឋធ្វើសំណើ គឺរដ្ឋបរទេសដែលស្នើសុំធ្វើបត្យាប័នអាណិកជនរស់នៅបរទេស។
2. បុគ្គលដែលគេទាមទារ គឺជាអាណិកជនបរទេសដែលស្នាក់នៅលើដែនដីរដ្ឋត្រូវស្នើសុំ និងជាកម្មវត្ថុនៃសំណើសុំឱ្យធ្វើបត្យាប័ន។

# លក្ខខណ្ឌធ្វើបត្យាប័ន (ត)

## លក្ខខណ្ឌនៃបត្យាប័ននឹងទាក់ទងអំពើ (មាត្រា ៥៦៩)

- បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ជាបទល្មើសតាមច្បាប់រដ្ឋធ្វើសំណើ និងតាមកម្ពុជាផងដែរ ទោះបីជា ៖
  - អំពើដែលកើតជាបទល្មើស ស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នាក្តី ឬ
  - ឈ្មោះបទល្មើស ការប្រើបច្ចេកស័ព្ទ ឬនិយមន័យ ឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នាក្តី ឬ
  - ជាតុផ្សំនៃបទល្មើសនៃច្បាប់របស់រដ្ឋធ្វើសំណើ ខុសគ្នាពីជាតុផ្សំនៃបទល្មើស ដែលកំណត់ដោយកម្ពុជាក៏ដោយ ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋធ្វើសំណើដែលប្រព្រឹត្តតាមបញ្ញានៃច្បាប់ជាធរមានកម្ពុជា

# លក្ខខណ្ឌធ្វើបត្យាប័ន (ត)

- មាត្រា ៥៧០ ករណីនៃការប៉ុនប៉ងប្រព្រឹត្តបទល្មើស និងការសមគំនិត
- មាត្រា ៥៧១ លក្ខខណ្ឌទាក់ទងនឹងទោសពន្ធនាគារ
- មាត្រា ៥៧២ លក្ខខណ្ឌទាក់ទងនឹងទៅកន្លែងប្រព្រឹត្តបទល្មើស
- មាត្រា ៥៧៣ អំពើដែលមានលក្ខណៈនយោបាយ
- មាត្រា ៥៧៤ អំពើដែលត្រូវបានប្រព្រឹត្តលើដែនដី និងត្រូវបានជំនុំជម្រះជាស្ថាពរួចរាល់ហើយ
- មាត្រា ៥៧៥ ការរលត់នៃបណ្តឹងអាជ្ញា
- មាត្រា ៥៧៦ ពាក្យសុំធ្វើបត្យាប័នជាច្រើនទាក់ទងនឹងបុគ្គលតែម្នាក់
- មាត្រា ៥៧៧ លក្ខខណ្ឌធ្វើបត្យាប័នទាក់ទងពាក្យសុំ
- មាត្រា ៥៧៨ ការព្យួរបត្យាប័ន

# នីតិវិធីនៃធ្វើបត្យាប័ន

- គ្រប់ពាក្យសុំធ្វើបត្យាប័នត្រូវជូនរដ្ឋាភិបាលកម្ពុជាតាមផ្លូវទូត។ ពាក្យសុំនេះត្រូវមានលិខិតបញ្ជាក់ភស្តុតាងអមជាមួយផង។

- ការបញ្ជូនពាក្យសុំធ្វើបត្យាប័ន ៖ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាបញ្ជូនពាក្យសុំធ្វើបត្យាប័ន និងលិខិតបញ្ជាក់ភស្តុតាងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្ទៀងផ្ទាត់មើលនិយតភាពនៃពាក្យសុំ និងបញ្ជូនពាក្យនោះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ (មាត្រា ៥៨០)។

- អគ្គព្រះរាជអាជ្ញារៀបចំសំណុំរឿង ដើម្បីប្តឹងទៅសភាស៊ើបសួរនៃ សាលាឧទ្ធរណ៍ភ្នំពេញ (មាត្រា ៥៨៤)។

# នីតិវិធីនៃធ្វើបត្យាប័ន (ត)

- យោបល់របស់សភាស៊ើបសួរ (មាត្រា ៥៨៦) សភាស៊ើបសួរផ្តល់យោបល់មិនយល់ព្រម ប្រសិនបើយល់ឃើញថាលក្ខខណ្ឌច្បាប់នៃបត្យាប័នមិនត្រូវបានបំពេញទេការយល់ព្រមធ្វើបត្យាប័ន (មាត្រា ៥៨៨) ប្រសិនបើបុគ្គលដែលគេទាមទារ យល់ព្រមឱ្យគេបញ្ជូនតាមពាក្យសុំរបស់រដ្ឋធ្វើសំណើក្រោយពីបានទទួលព័ត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមចំពោះបត្យាប័ន សភាស៊ើបសួរត្រូវចុះនិទ្ទេសនេះនៅក្នុងសាលដីការបស់ខ្លួន។
- សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ជាអង្គភាពតែមួយគត់ដែលមានសមត្ថកិច្ច ដើម្បីពិចារណាលើនិយតភាពនៃបត្យាប័នដែលរដ្ឋាភិបាលកម្ពុជាបានទទួល។

# នីតិវិធីនៃធ្វើបត្យាប័ន (ត)

## សន្ធិសញ្ញាអន្តរជាតិ

- លើកលែងតែមានបញ្ញត្តិផ្ទុយពីសន្ធិសញ្ញា ច្បាប់ជាតិរបស់ភាគីទទួលសំណើប៉ុណ្ណោះ ដែលអាចអនុវត្តចំពោះនីតិវិធីនៃការចាប់ខ្លួនជាបណ្តោះអាសន្ន ការធ្វើបត្យាប័ន និងការឆ្លងកាត់
- គូភាគីត្រូវធ្វើការទំនាក់ទំនងគ្នាដោយផ្ទាល់តាមរយៈអាជ្ញាធរកណ្តាល ឬ តាមរយៈបណ្តាញការទូត
- ប្រសិនបើភាគីទទួលសំណើយល់ឃើញថា ព័ត៌មានដែលភ្ជាប់មកជាមួយសំណើសុំបត្យាប័នមិនគ្រប់គ្រាន់សម្រាប់អនុវត្តនីតិវិធីធ្វើបត្យាប័ន តាមសន្ធិសញ្ញា ភាគីអាចស្នើសុំផ្តល់ព័ត៌មានបន្ថែមនៅក្នុងអំឡុងពេលសមស្របដែលបានកំណត់ដោយភាគីទទួលសំណើ

# បត្យាប័នស្នើសុំដោយកម្ពុជាចំពោះរដ្ឋបរទេស

- បុគ្គលដែលត្រូវបានធ្វើបត្យាប័ន មានរយៈពេល១៥ថ្ងៃ គិតពីពេលដែលសាមីខ្លួនមកដល់កម្ពុជា ដើម្បីលើកអំពីមោឃភាពនៃបត្យាប័ន។
- សភាស៊ើបសួរធ្វើការសម្រេច ក្រោយពីបានស្តាប់ចម្លើយរបស់បុគ្គលដែលត្រូវបានទទួលពាក្យប្តឹងសុំឱ្យធ្វើបត្យាប័នពីរដ្ឋបរទេសណាមួយផ្សេង កម្ពុជានឹងអាចយល់ព្រមតាមពាក្យប្តឹងនេះបាន ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋដែលបានប្រគល់អាណិកជននេះ មករាជរដ្ឋាភិបាលកម្ពុជា។
- ប៉ុន្តែការយល់ព្រមនេះ មិនជាការចាំបាច់ទេ កាលណាអាណិកជនបរទេសនេះមានលទ្ធភាពចាកចេញដោយសេរីពីដែនដីកម្ពុជារួចទៅហើយ រយៈពេល៣០ថ្ងៃ។

# ពាក្យសុំឆ្លងកាត់

## ក្រមនីតិវិធីព្រហ្មទណ្ឌ

ការឆ្លងកាត់ដែនដីកម្ពុជា ដោយបុគ្គលណាម្នាក់ដែលស្ថិតក្នុងក្របខណ្ឌនៃនីតិវិធីបត្យាប័ន អាចត្រូវបានអនុញ្ញាត កាលណាបត្យាប័ននេះមិនទាន់ទងនឹងបទល្មើសនយោបាយទេ។ ពាក្យសុំត្រូវសុំត្រូវធ្វើតាមផ្លូវទូត។ ពាក្យសុំតែមានលិខិតបញ្ជាក់ភស្តុតាងបញ្ជាក់ថាត្រឹមត្រូវអមជាមួយផង។

# ពាក្យសុំឆ្លងកាត់ (ត)

## សន្ធិសញ្ញាអន្តរជាតិ

1. អនុលោមតាមច្បាប់របស់ភាគី ការឆ្លងកាត់របស់បុគ្គលដែលត្រូវធ្វើបត្យាប័នដោយភាគីទីបីទៅភាគីមួយតាមដែនដីនៃភាគីមួយទៀត ត្រូវអនុញ្ញាតតាមសំណើជាលាយលក្ខណ៍អក្សរតាមរយៈបណ្តាញការទូត ឬដោយផ្ទាល់រវាងអាជ្ញាធរកណ្តាលនៃគូភាគី ហើយការឆ្លងកាត់នេះត្រូវបានធ្វើឡើងបន្ទាប់ពីមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីភាគីនោះ។
2. ការអនុញ្ញាតសុំការឆ្លងកាត់នេះមិនតម្រូវឲ្យមានការស្នើសុំទេ ក្នុងករណីដែលមានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស ហើយគ្មានការសុំចុះចតលើដែនដីនៃភាគីដែលត្រូវឆ្លងកាត់។ប្រសិនបើមានការចុះចតដោយមិនបានកំណត់ពេលនៅលើដែនដីនៃភាគីដែលត្រូវឆ្លងកាត់ ភាគីទីបីត្រូវផ្តល់ជូននូវសំណើសម្រាប់ការឆ្លងកាត់ដែលបានចែងនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ។

7/27/2023


# ពាក្យសុំឆ្លងកាត់ (ត)


3. នៅពេលដែលទទួលបានសំណើសុំការអនុញ្ញាតឆ្លងកាត់ ភាគីឆ្លងកាត់ត្រូវផ្តល់ជូនការអនុញ្ញាតឲ្យឆ្លងកាត់ លើកលែងតែមានហេតុផលដែលមានមូលដ្ឋាននៃការបដិសេធសមស្រប។
4. ការអនុញ្ញាត្តិក្នុងការឆ្លងកាត់នេះ ត្រូវស្របតាមច្បាប់នៃភាគីទទួលសំណើដោយរាប់បញ្ចូលទាំងការអនុញ្ញាត្តិចំពោះបុគ្គលដែលជាប់ឃុំឃាំងក្នុងការឆ្លងកាត់។
5. នៅពេលបុគ្គលដែលជាប់ឃុំឃាំង ដូចដែលមានចែងនៅក្នុងចំណុច៤ ខាងលើ ដែនដីនៃភាគីដែលបុគ្គលស្នើសុំកំពុងស្ថិតនៅ អាចនឹងធ្វើការដោះលែងប្រសិនបើការដឹកជញ្ជូនមិនបានបន្តក្នុងកំឡុងពេលសមស្របមួយ។
6. ភាគីដែលបុគ្គលស្នើសុំបាននឹងកំពុងបញ្ជូនត្រូវផ្តល់សំណងដល់ភាគីម្ខាងទៀត សម្រាប់ការចំណាយដែលពាក់ព័ន្ធនឹងការឆ្លងកាត់។ បុគ្គលនោះបានចាកចេញពីដែនដីនៃភាគីធ្វើសំណើ បន្ទាប់ពីការធ្វើបត្យាប័នហើយបានត្រលប់មកដែនដីវិញដោយស្ម័គ្រចិត្ត។

# ឧបសម្ព័ន្ធទី ៧


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

**បទបង្ហាញ**
**ស្តីពី**
**បត្យាប័ន**

**ក្រសួងយុត្តិធម៌** ឆ្នាំ ២០២២

**មាតិកា**

១. និយមន័យ និងគោលបំណង
២. ក្របខណ្ឌក្នុងការធ្វើបត្យាប័ន
៣. បត្យាប័នតាមសន្ធិសញ្ញា
៤.បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា
៥.លក្ខខណ្ឌ និងនីតិវិធីនៃបត្យាប័ន

## ពាក្យគន្លឹះ

- ➢រដ្ឋដាក់សំណើ ឬរដ្ឋធ្វើសំណើ៖ រដ្ឋដែលជាអ្នកស្នើសុំធ្វើបត្យាប័ន
- ➢រដ្ឋទទួលសំណើ៖ រដ្ឋដែលទទួលបានសំណើសុំធ្វើបត្យាប័ន
- ➢សន្ធិសញ្ញា៖ កិច្ចព្រមព្រៀងអន្តរជាតិដែលធ្វើឡើងរវាងរដ្ឋនិងរដ្ឋ នៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ



## និយមន័យ

- ➢ បត្យាប័ន គឺជានីតិវិធីនៃការប្រគល់ខ្លួនបុគ្គលម្នាក់ដោយរដ្ឋ (រដ្ឋទទួលសំណើ) ទៅឱ្យអាជ្ញាធររបស់រដ្ឋមួយផ្សេងទៀត (រដ្ឋដាក់សំណុំ)ក្នុងគោលបំណងដើម្បី យកជននោះមកធ្វើការចោទប្រកាន់ចំពោះមុខយុត្តាធិការរបស់ខ្លួន ឬយកជននោះ មកអនុវត្តទោសនៅក្នុងប្រទេសរបស់ខ្លួន។
- ➢ បត្យាប័នកើតមានឡើងនៅពេលដែលរដ្ឋមួយដែលជាអ្នកស្នើសុំ ហៅថារដ្ឋដាក់សំណើ ឬរដ្ឋធ្វើសំណើ បានធ្វើការស្នើសុំទៅរដ្ឋមួយផ្សេងទៀត ដើម្បីធ្វើបត្យាប័ន ដែលរដ្ឋនោះហៅថារដ្ឋទទួលសំណើ។

## ក្របខ័ណ្ឌច្បាប់នៃការធ្វើបត្យាប័នមានបីយ៉ាងគឺ ៖

- ក្របខ័ណ្ឌនៃបត្យាប័នពិសេស៖  ត្រូវអនុលោមទៅតាមសន្ធិសញ្ញាស្តីពីបត្យាប័នដែលកម្ពុជាបានផ្តល់សច្ចាប័ន។ ប្រសិនបើមានសន្ធិសញ្ញាគឺសន្ធិសញ្ញានេះបានចែងនីតិវិធីលម្អិតអំពីការធ្វើបត្យាប័នហើយបត្យាប័ននេះត្រូវអនុវត្តតាមសន្ធិសញ្ញានោះ។
- ក្របខ័ណ្ឌនៃបត្យាប័នតាមក្រមនីតិវិធីព្រហ្មទណ្ឌ៖  នៅពេលដែលមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយរដ្ឋធ្វើសំណើបត្យាប័នទេជាគោលការណ៍ត្រូវអនុវត្តតាមនីតិវិធីរួមស្តីពីបត្យាប័នដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។   ដូចនេះប្រទេសមួយចំនួនដែលមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយកម្ពុជាបើមានការស្នើសុំធ្វើបត្យាប័នត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។
- ក្របខ័ណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិពិសេស៖ ក្នុងករណីដែលមានច្បាប់ពិសេសស្តីពីបត្យាប័នគឺត្រូវអនុវត្តតាមនីតិវិធីនៃបត្យាប័នទៅតាមច្បាប់ពិសេសនោះ (មាត្រា ៥៦៧ ក្រមនីតិវិធីព្រហ្មទណ្ឌ)។



## ក្របខ័ណ្ឌច្បាប់ផ្សេងទៀត

មាត្រា៣នៃសន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិស្តីពីការធ្វើបត្យាប័ន បានចែងថា ការធ្វើបត្យាប័នមិនត្រូវបានអនុញ្ញាត ប្រសិនបើបុគ្គលដែលត្រូវបានស្នើសុំឲ្យធ្វើបត្យាប័ន អាចពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម ហើយការធ្វើបត្យាប័នអាចនឹងត្រូវបានបដិសេធ ប្រសិនបើរដ្ឋដែលត្រូវបានស្នើសុំ ចាត់ទុកថា បទល្មើសដែលត្រូវស្នើឱ្យមានការធ្វើបត្យាប័នមានពាក់ព័ន្ធនឹងនយោបាយ ឬយោធា ។ រដ្ឋដែលត្រូវបានស្នើឲ្យធ្វើបត្យាប័ន ត្រូវបដិសេធសំណើសុំធ្វើបត្យាប័ន ប្រសិនបើរដ្ឋដែលធ្វើការស្នើសុំ មានការកាត់ទោសប្រហារជីវិតចំពោះបទល្មើស លុះត្រាតែមានការធានាថា នឹងមិនមានការអនុវត្តការកាត់ទោសប្រហារជីវិត។ ក្នុងករណីបែបនេះ សេចក្តីសម្រេចថា មិនធ្វើបត្យាប័នមានលក្ខណៈស្របច្បាប់។

ទោះបីជាច្បាប់អន្តរជាតិ មិនបានផ្តល់កាតព្វកិច្ចឱ្យរដ្ឋធ្វើបត្យាប័នក៏ដោយ ក៏សន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិ ស្តីពីការធ្វើបត្យាប័ន (សន្ធិសញ្ញាគំរូរបស់ អ.ស.ប) បានចែងអំពីគំរូសម្រាប់ច្បាប់ជាតិ និងកិច្ចព្រមព្រៀងទ្វេភាគីដែលពាក់ព័ន្ធនឹងការធ្វើបត្យាប័ន ព្រមទាំង មានបំណងចែងអំពីប្រទេសដែលមានមូលដ្ឋានបែបនេះ ដើម្បីធានាថា ដំណើរដំណើរការនៃការធ្វើបត្យាប័នឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។

**បត្យាប័នតាមសន្ធិសញ្ញា**

- បត្យាប័នកើតមានឡើងបានលុះត្រាតែមានការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ។ ទន្ទឹមនឹងនេះ ការព្រមព្រៀងនេះ គឺពឹងផ្អែកទៅលើឆន្ទៈរបស់រដ្ឋទទួលសំណើ ក្នុងការផ្ទេរបុគ្គលម្នាក់ឱ្យទៅរដ្ឋដាក់សំណើ។
- សន្ធិសញ្ញាស្តីពីបត្យាប័នត្រូវធ្វើឡើងតាមរយៈការចរចាគ្នាដើម្បីកំណត់នូវនីតិវិធីសមស្រប និងកំណត់នូវបទល្មើសទាំងឡាយណាដែលអនុញ្ញាតិឱ្យធ្វើបត្យាប័នបានឬមិនបាន។
- សន្ធិសញ្ញាទាក់ទងនឹងការធ្វើបត្យាប័ននេះ បានផ្តល់នូវភាពងាយស្រួលជាច្រើនដល់រដ្ឋជាភាគីតាមរយៈការឱ្យរដ្ឋជាភាគីបានដឹងជាមុន នូវនីតិវិធីក្នុងការធ្វើបត្យាប័ន ព្រមទាំងដែនអនុវត្តខ្លះដែលរដ្ឋ ជាភាគីបានធ្វើការព្រមព្រៀងគ្នានៅក្នុងសន្ធិសញ្ញា។



ព្រះរាជាណាចក្រកម្ពុជាមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយរដ្ឋបរទេសៈ

- សាធារណរដ្ឋវៀតណាម
- ព្រះរាជាណាចក្រថៃ
- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
- សាធារណរដ្ឋកូរ៉េ
- សាធារណរដ្ឋប្រជាមានិតចិន
- សាធារណរដ្ឋបារាំង
- សហព័ន្ធរុស្សី

## បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា

មិនមានច្បាប់ ឬគោលការណ៍ណាមួយហាមឃាត់មិនឱ្យធ្វើបត្យាប័ន ដោយគ្មានសន្ធិសញ្ញាបត្យាប័ននោះទេ បានន័យថា ការធ្វើបត្យាប័នមិនចាំបាច់ទាមទារឱ្យធ្វើឡើងតាមរយៈសន្ធិសញ្ញាបត្យាប័ននោះទេ។ ការធ្វើបត្យាប័ន ជាពិសេស គឺ ត្រូវតែពឹងផ្អែកលើឆន្ទៈជួយគ្នាទៅវិញទៅមក... និងមនោសញ្ចេតនារបស់ប្រទេសជាដៃគូ... ដើម្បីបង្រ្កាបបទល្មើសដែលកើតមានលើទឹកដីរបស់ខ្លួន ព្រមទាំងធានាបាននូវគុណភាពនៃការធ្វើ បត្យាប័នប្រកបដោយភាតរភាព និងនិរន្តរភាព។ប្រទេសមួយចំនួនដែលមិនមានសន្ធិសញ្ញាបត្យាប័ន ក៏បានចែងពីឆន្ទៈរបស់ខ្លួន ក្នុងការធ្វើបត្យាប័នតាមរយៈ ច្បាប់ជាតិរបស់ខ្លួន គោលការណ៍បដិការ ក្នុងគោលបំណងដើម្បីជាប្រយោជន៍ដល់សហគមន៍អន្តរជាតិ ដូចជាប្រទេសដទៃទៀតដែលជាប្រទេសដាក់សំណើ។

ព្រះរាជាណាចក្រកម្ពុជាពុំមានច្បាប់ស្តីពីបត្យាប័នទេ ប៉ុន្តែមានបញ្ញត្តមួយចំនួនដែលទាក់ទងនឹងបត្យាប័នដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។



## បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា (ត)

- ព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិក្នុងការធ្វើសំណើបត្យាប័នទៅរដ្ឋដែលបុគ្គលម្នាក់ ឬ ច្រើននាក់ស្នាក់នៅបាន ក្នុងករណីដែលបុគ្គលនោះបានប្រព្រឹត្តិបទល្មើសក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយក្រោយមកជនល្មើសបានទៅស្នាក់នៅប្រទេសដទៃទៀត ដើម្បីគេចខ្លួន និងរួច ផុតពីការទទួលខុសត្រូវ ទោះជាបុគ្គលនោះមានសញ្ញាតិខ្មែរ ឬបរទេសក៏ដោយ។
- អាជ្ញាធរកណ្តាល គឺក្រសួងយុត្តិធម៌។ អាជ្ញាធរកណ្តាលនេះបានដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលលើបញ្ហាបត្យាប័ន ជាពិសេសគឺជាអ្នករៀបចំ និងត្រួតពិនិត្យក្នុងការធ្វើសំណើបត្យាប័ន។

## លក្ខខណ្ឌក្នុងការធ្វើបត្យាប័ន

- លក្ខខណ្ឌទាក់ទងនឹងបទល្មើស៖ ការធ្វើបត្យាប័នបានលុះត្រាតែបទល្មើសនោះមានចែងក្នុងច្បាប់នៃរដ្ឋធ្វើសំណើផង និងរដ្ឋទទួលសំណើផង ទោះបីជាឈ្មោះនៃបទល្មើស ឬធាតុផ្សំ ឬពាក្យបច្ចេកទេសនៃបទល្មើសនោះខុសគ្នាក៏ដោយ។
- លក្ខខណ្ឌទាក់ទងនឹងបុគ្គលដែលត្រូវធ្វើបត្យាប័ន៖ ជាចារីផ្ទាល់ ឬអ្នកសមគំនិតក្នុងបទល្មើស
- លក្ខខណ្ឌដែលទាក់ទងនឹងទោសដាក់ពន្ធនាគារ៖ លុះត្រាតែបទល្មើសនោះមានចែងទោសដាក់ពន្ធនាគារអតិបរមាលើសពី ២ ឆ្នាំ ឬជននេះត្រូវបានតុលាការនៃរដ្ឋស្នើសុំផ្តន្ទាទោសរួចហើយដែលមានទោសលើសពី ៦ ខែក៏អាចធ្វើបត្យាប័នបានដែរ។

11

## លក្ខខណ្ឌក្នុងការធ្វើបត្យាប័ន (ត)

- លក្ខខណ្ឌទាក់ទងនឹងទីកន្លែងនៃការប្រព្រឹត្តបទល្មើស៖ បទល្មើសត្រូវបានប្រព្រឹត្តនៅលើទឹកដីនៃរដ្ឋដាក់សំណើ ទោះបីជនល្មើសមិនមានសញ្ជាតិនៃរដ្ឋដាក់សំណើក៏ដោយ ឬជនល្មើសមានសញ្ជាតិរបស់រដ្ឋដាក់សំណើទោះបីបទល្មើសនោះត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃរដ្ឋដាក់សំណើក៏ដោយ។
- លក្ខខណ្ឌទាក់ទងនឹងបទល្មើសដែលអាចជាកម្មវត្ថុនៃការធ្វើបត្យាប័ន៖ លុះត្រាតែបទល្មើសនេះជាបទល្មើសនៃនីតិព្រហ្មទណ្ឌពោលគឺមិនមែនជាអំពើមានលក្ខណៈជានយោបាយ ឬការរើសអើងពូជសាសន៍ ឬសាសនា។
- លក្ខខណ្ឌទាក់ទងនឹងពាក្យសុំ៖ កម្ពុជាធ្វើបត្យាប័នផ្តល់ជូនជនដែលត្រូវបានគេស្នើសុំបានលុះត្រាតែរដ្ឋបរទេសនោះសន្យាថាមិនចោទប្រកាន់បទល្មើសផ្សេងទៀតទៅលើបុគ្គលនេះទេ។

12

## នីតិវិធីក្នុងការធ្វើបត្យាប័ន (ត)

➢ ពាក្យសុំធ្វើបត្យាប័ន៖ រដ្ឋធ្វើសំណើត្រូវដាក់ពាក្យសុំធ្វើបត្យាប័នជូនរដ្ឋាភិបាលកម្ពុជាតាមផ្លូវទូតដោយភ្ជាប់មកជាមួយភ័ស្តុតាងរួមមាន៖ ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារធ្វើបត្យាប័ន,របាយការណ៍អំពីអង្គហេតុដែលត្រូវចោទប្រកាន់,លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន និងឯកសារទាំងអស់ត្រូវចុះហត្ថលេខាបោះត្រាផ្លូវការ និងបិទស្រោម។

➢ ការទទួលពាក្យសុំធ្វើបត្យាប័ន៖ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាត្រូវបញ្ជូនពាក្យសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីផ្ទៀងផ្ទាត់មើលនិយតភាពនៃពាក្យសុំធ្វើបត្យាប័នបន្ទាប់មករដ្ឋមន្ត្រីក្រសួងយុត្តិធម៌បញ្ជូនពាក្យសុំនោះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

➢ រដ្ឋធ្វើសំណើអាចសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ននូវបុគ្គលដែលទាមទារហើយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចេញបញ្ជាឲ្យចាប់ និងឃុំខ្លួនជនដែលជាកម្មវត្ថុនៃការធ្វើបត្យាប័នបាន។



## នីតិវិធីក្នុងការធ្វើបត្យាប័ន

- អគ្គព្រះរាជអាជ្ញារៀបចំសំណុំរឿងដើម្បីប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍

- នីតិវិធីនៅចំពោះមុខសភាស៊ើបសួរ៖ បុគ្គលដែលគេទាមទារត្រូវបង្ហាញខ្លួននៅចំពោះមុខសភាស៊ើបសួរដែលមានចៅក្រម ៣ រូប។ ការពិភាក្សាដេញដោលនៅសាលសវនាការអសាធារណៈ។ បន្ទាប់ពីស្តាប់ចម្លើយបុគ្គលដែលគេទាមទារសេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញាសេចក្តីសន្និដ្ឋានការពាររបស់មេធាវីរួចមកសភាស៊ើបសួរផ្តល់យោបល់ជាសាលដីកាលើពាក្យសុំធ្វើបត្យាប័ននោះ។

**យោបល់របស់សភាស៊ើបសួរ**

ក- មិនយល់ព្រមប្រសិនបើយល់ឃើញថាលក្ខខណ្ឌច្បាប់នៃបត្យាប័នមិនត្រូវបានបំពេញត្រូវដោះលែងបុគ្គលដែលគេទាមទារ

ខ- បើយល់ព្រមឱ្យធ្វើបត្យាប័នសភាស៊ើបសួរត្រូវជូនដំណឹងភ្លាមទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីបញ្ជូនរឿងនេះទៅរាជរដ្ឋាភិបាលដើម្បីចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នប្រគល់បុគ្គលដែលគេទាមទារទៅរដ្ឋស្នើសុំ។

# ឧបសម្ព័ន្ធទី ៨

## ចំណេះដឹងផ្នែកច្បាប់

# អត្ថបទ ស្តីពី បត្យាប័ន

បទខ្ទេសនាមដោយ: លោក ជុំ គិរី

ឆ្នាំសិក្សា ២០២២

## មាតិកា

១- និយមន័យបត្យាប័ន
២- ការកកើតនៃបត្យាប័ន
៣- ក្របខណ្ឌនៃបត្យាប័ន
៤- លក្ខខណ្ឌក្នុងការធ្វើបត្យាប័ន
៥- តម្លៃរវាងបត្យាប័ន និងដីកាចាប់ខ្លួន
៦- ការហាមឃាត់ក្នុងការធ្វើបត្យាប័ន
៧- នីតិវិធីធ្វើបត្យាប័ន

# សេចក្តីផ្តើម

- នៅក្នុងប្រទេសមួយ ឬ រដ្ឋមួយចាំបាច់ណាស់ត្រូវតែមានច្បាប់សម្រាប់គ្រប់គ្រងប្រទេស ឬ រដ្ឋនោះ បើពុំដូច្នោះទេ ភាពចលាចល អសន្តិសុខ គ្មានសណ្តាប់ធ្នាប់ក្នុងសង្គម ពិតជាកើតឡើងឥតឈប់ឈរ។ ហេតុនេះហើយប្រទេស ឬ រដ្ឋនោះ ត្រូវតែមានច្បាប់សម្រាប់បង្ការ ទប់ស្កាត់ និងអនុវត្តច្បាប់ចំពោះជនដែលប្រព្រឹត្តបទល្មើស។
- ក្នុងន័យបត្យាប័ន គឺជាការស្នើសុំជនល្មើសរបស់រដ្ឋបរទេស ឬ ជារដ្ឋធ្វើសំណើដើម្បីស្នើសុំជនល្មើសយកទៅធ្វើការចោទប្រកាន់ និងផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់របស់ប្រទេសខ្លួន។



# ១- និយមន័យបត្យាប័ន

- បត្យាប័ន ជានីតិវិធីនៃការបញ្ជូនខ្លួនជនល្មើសពីរដ្ឋមួយទៅរដ្ឋមួយ ឬ ជានីតិវិធីមួយ ដែលរដ្ឋធ្វើសំណើបានធ្វើសំណើសុំជនណាម្នាក់ទៅរដ្ឋមួយទៀត ដើម្បីយកជននោះមកធ្វើការចោទប្រកាន់ចំពោះមុខយុត្តាធិការរបស់ខ្លួន ឬ យកជននោះមកអនុវត្តទោសនៅក្នុងប្រទេសរបស់ខ្លួន។
- បុគ្គលដែលទាមទារ គឺជាអាណិកជនបរទេស ដែលស្នាក់នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការចោទប្រកាន់ ឬ ផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់របស់ប្រទេសដែលបានស្នើសុំ ឬ ជាកម្មវត្ថុនៃពាក្យស្នើសុំធ្វើបត្យាប័ន *(ម.៥៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)*។

# ២- ការកកើតនៃបត្យាប័ន

- ការកកើតនៃបត្យាប័ន នៅពេលរដ្ឋបរទេសដាក់សំណើស្នើសុំឲ្យព្រះរាជាណាចក្រកម្ពុជា ប្រគល់អាណិកជនបរទេសណាមួយកំពុងស្នាក់នៅក្នុងប្រទេសកម្ពុជា ដើម្បីយកបុគ្គលដែលទាមទារនោះមកធ្វើការចោទប្រកាន់តាមផ្លូវតុលាការ ឬ ផ្តន្ទាទោសដាក់ពន្ធនាគារដោយតុលាការនៃរដ្ឋស្នើសុំ។
- បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជា ពិនិត្យមើលនិយតភាពនៃការស្នើសុំធ្វើបត្យាប័ន រួចសម្រេចប្រគល់អាណិកជនបរទេសនោះឲ្យរដ្ឋស្នើសុំ ពេលនោះកកើតមាននូវការធ្វើបត្យាប័ន ហើយបុគ្គលដែលរដ្ឋបរទេសទាមទារ គឺជាកម្មវត្ថុនៃការធ្វើបត្យាប័ន។



# ៣- ក្របខណ្ឌនៃបត្យាប័ន

- *ក្របខណ្ឌនៃបត្យាប័នពិសេសៈ* ចំពោះបត្យាប័នពិសេសនេះ ត្រូវអនុលោមតាមសន្ធិសញ្ញាដែលប្រទេសនោះបានផ្តល់សច្ចាប័ន។ ប្រសិនបើសន្ធិសញ្ញានោះ មានចែងលម្អិតអំពីនីតិវិធីបត្យាប័ន។ ឧទាហរណ៍ៈ ប្រទេសកម្ពុជាបានចុះសន្ធិសញ្ញាជាមួយប្រទេសដូចជាៈ ប្រទេសចិន ថៃ វៀតណាម ឡាវ រុស្ស៊ី ជាដើម។
- *ក្របខណ្ឌនៃបត្យាប័នតាមក្រមនីតិវិធីព្រហ្មទណ្ឌៈ* នៅពេលដែលមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយរដ្ឋស្នើសុំធ្វើបត្យាប័នទេ ជាគោលការណ៍ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។
- *ក្របខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិពិសេសៈ* ក្នុងករណីដែលមានច្បាប់ពិសេសស្តីពីបត្យាប័ន គឺត្រូវអនុវត្តតាមនីតិវិធីនៃបត្យាប័នទៅតាមច្បាប់ពិសេស *(ម.៥៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)*។

# ៤- លក្ខខណ្ឌក្នុងការធ្វើបត្យាប័ន

បត្យាប័នត្រូវធ្វើឡើងតាមលក្ខខណ្ឌមួយចំនួន ដូចខាងក្រោម៖

- *លក្ខខណ្ឌទាក់ទងនឹងបទល្មើស៖* ការធ្វើបត្យាប័នបានលុះត្រាតែបទល្មើសនោះមានចែងក្នុងច្បាប់នៃរដ្ឋធ្វើសំណើផង និងរដ្ឋទទួលសំណើផង ទោះបីជាឈ្មោះនៃបទល្មើស ឬ ធាតុផ្សំ ឬ ពាក្យបច្ចេកទេសនៃបទល្មើសនោះខុសគ្នាក៏ដោយ *(ម.៥៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)*។
- *លក្ខខណ្ឌដែលទាក់ទងនឹងទោសដាក់ពន្ធនាគារ៖* លុះត្រាតែបទល្មើសនោះមានចែងទោសដាក់ពន្ធនាគារអតិបរមាយ៉ាងតិចស្មើ ២ឆ្នាំ ឬ ជននេះត្រូវបានតុលាការនៃរដ្ឋស្នើសុំសម្រេចផ្តន្ទាទោសរួចហើយ ដែលមានទោសយ៉ាងតិចបំផុតស្មើនឹង ៦ ខែក៏អាចធ្វើបត្យាប័នបានដែរ *(ម.៥៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)*។



# ៤- លក្ខខណ្ឌក្នុងការធ្វើបត្យាប័ន

- *លក្ខខណ្ឌទាក់ទងនឹងទីកន្លែងនៃការប្រព្រឹត្តបទល្មើស៖* បទល្មើសត្រូវបានប្រព្រឹត្តនៅលើទឹកដីនៃរដ្ឋធ្វើសំណើ ទោះបីជនល្មើសមិនមានសញ្ជាតិនៃរដ្ឋដាក់សំណើក៏ដោយ ឬ ជនល្មើសមានសញ្ជាតិរបស់រដ្ឋធ្វើសំណើ ទោះបីបទល្មើសនោះត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃរដ្ឋធ្វើសំណើក៏ដោយ *(ម.៥៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)*។
- *លក្ខខណ្ឌទាក់ទងនឹងពាក្យសុំ៖* កម្ពុជាធ្វើបត្យាប័នផ្តល់ជូនជនដែលត្រូវបានគេស្នើសុំបាន លុះត្រាតែរដ្ឋបរទេសនោះសន្យាថាមិនចោទប្រកាន់បទល្មើសផ្សេងទៀតទៅលើបុគ្គលនេះទេ លើកលែងតែមានការយល់ព្រមពីរដ្ឋកម្ពុជា *(ម.៥៧៧ នីតិវិធីព្រហ្មទណ្ឌ)*។
- *លក្ខខណ្ឌទាក់ទងនឹងបទល្មើសដែលជាកម្មវត្ថុនៃការធ្វើបត្យាប័ន៖* លុះត្រាតែបទល្មើសនេះ ជាបទល្មើសដែលផ្ទុយអំពីច្បាប់ជាធរមាន ពោលគឺមិនមែនជាអំពើមានលក្ខណៈជាននយោបាយ ឬ ការរើសអើងពូជសាសន៍ ឬ សាសនា។

# ៥- តម្លៃរវាងបត្យាប័ន និងដីកាចាប់ខ្លួន

- ប្រសិនបើផ្តល់អត្ថន័យចំពោះ ដីកាចាប់ខ្លួន គឺជាវិធានការបង្ខំមួយដែលចេញដោយ អាជ្ញាធរតុលាការ ដើម្បីបង្គាប់ឲ្យមន្ត្រីមានសមត្ថកិច្ចស្វែងរក និងចាប់ខ្លួនជនត្រូវចោទមកអនុវត្តតាមច្បាប់។
- ចំណែកពាក្យថា បត្យាប័ន គឺជានីតិវិធីនៃការស្នើសុំ និងការប្រគល់ជនដែលប្រព្រឹត្តបទល្មើសពីរដ្ឋ ដែលជននោះកំពុងស្នាក់នៅទៅរដ្ឋដែលធ្វើសំណើ។
- សរុបសេចក្តីមកតម្លៃនៃបត្យាប័ន មិនមានតម្លៃដូចដីកាចាប់ខ្លួនទេ។



# ៦- ការហាមឃាត់ក្នុងការធ្វើបត្យាប័ន

- ករណីមួយចំនួនត្រូវបានច្បាប់ហាមឃាត់មិនឲ្យធ្វើបត្យាប័ន ទោះបីជាគ្រប់លក្ខខណ្ឌក៏ដោយ៖

-ជនដែលជាកម្មវត្ថុនៃការធ្វើបត្យាប័ន ត្រូវបានតុលាការកម្ពុជាផ្តន្ទាទោសជាស្ថាពររួចហើយ ឬ កំពុងស្ថិតនៅក្នុងនីតិវិធីនៃច្បាប់កម្ពុជា។

-បណ្តឹងអាជ្ញាបានរលត់ (តាមច្បាប់កម្ពុជា)

-ការបញ្ជូនជននោះទៅត្រូវបានតុលាការនៃប្រទេសស្នើសុំផ្តន្ទាទោសប្រហារជីវិត។

-ការបញ្ជូនជននោះទៅត្រូវបានជំនុំជម្រះដោយតុលាការពិសេសនៃប្រទេសដាក់សំណើ។

# ៧- នីតិវិធីធ្វើបត្យាប័ន






# សេចក្តីសន្និដ្ឋាន

- សរុបសេចក្តីមក ការធ្វើបត្យាប័ន គឺជានីតិវិធីមួយនៃការបញ្ជូនខ្លួនជនល្មើសពីរដ្ឋមួយទៅរដ្ឋមួយ ដើម្បីយកជនដែលប្រព្រឹត្តបទល្មើសនោះ មកធ្វើការចោទប្រកាន់ ឬ អនុវត្តទោសដាក់ពន្ធនាគារតាមច្បាប់ប្រទេសរបស់ខ្លួន។
- ការធ្វើបត្យាប័ន តែងតែមានកម្មវត្ថុនៃការធ្វើបត្យាប័ន ព្រមទាំងលក្ខខណ្ឌដែលត្រូវគោរព ព្រោះថាពេលដែលរដ្ឋធ្វើសំណើដាក់សំណើមករដ្ឋទទួលសំណើ នោះរដ្ឋទទួលសំណើធ្វើការពិនិត្យនិយតភាពនៃការស្នើសុំធ្វើបត្យាប័ន និងស្របតាមលក្ខខណ្ឌសន្ធិសញ្ញា ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិពិសេសស្តីពីបត្យាប័ន។

# ឧបសម្ព័ន្ធទី ៩


នីតិវិធីនៃបត្យាប័នតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលស្នើដោយរដ្ឋបរទេស
(ចងក្រងដោយ៖ ស៊ាង សំភស់)
ពាក្យសុំធ្វើបត្យាប័ន
លិខិតបញ្ជាក់កស្តុតាង
- ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ
- របាយការណ៍អំពីអង្គហេតុ ដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ
- អត្ថបទច្បាប់ដែលអនុវត្តទៅលើអំពើនោះ និង ទោសដែលត្រូវទទួលរង
- លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន
រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ
សភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ភ្នំពេញ
សាលដីកាដែលចូលជាស្ថាពរ រួចហើយត្រូវជូនដំណឹងភ្លាម ដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
យោបល់សភាស៊ើបសួរក្រោយពីពិភាក្សាដេញដោល
(ចេញជាសាលដីកា)
-ក្រោយពីស្តាប់ចម្លើយបុគ្គលដែលគេទាមទារ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី
ករណីយល់ព្រម
ករណីមិនយល់ព្រមៈបត្យាប័នមិនអាចធ្វើបានដោយរាជរដ្ឋាភិបាលកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចបញ្ជូនរឿងនេះទៅរាជរដ្ឋាភិបាល
រាជរដ្ឋាភិបាលចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័ន
ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័ន ប្រសិនបើរដ្ឋផ្ញើសំណើមិនបានចាប់ផ្តើមនីតិវិធីធ្វើមាតុភូមិនិវត្តន៍ នោះបុគ្គលដែលគេទាមទារត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។

# ឧបសម្ព័ន្ធទី ១០



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការអមសាលាឧទ្ធរណ៍

លេខ [illegible] អ.ឧ.ភ.ក/១៤

[illegible] ថ្ងៃទី [illegible]

## ដីកាបញ្ជាឲ្យចាប់-ឃុំខ្លួន

យើងអគ្គព្រះរាជអាជ្ញានៃអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញមាត្រា ៥៧៥ និង ៥៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញលិខិតលេខ ២០៨៧ កយ ព្រទ/ប១១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ទីស្តីការក្រសួងយុត្តិធម៌ ស្តីអំពីសំណើសុំចាប់ខ្លួន និងធ្វើបត្យាប័នជនជាតិ រុស្ស៊ី ឈ្មោះ Balatin Vladimir Vitalievitch ភេទប្រុស អាយុ ៣៦ឆ្នាំ (កើតនៅទីក្រុង Zeya) មកពីតុលាការ រុស្ស៊ី ដោយហេតុថា បុគ្គលនេះបានប្រព្រឹត្តបទល្មើសនៅប្រទេស រុស្ស៊ី ហើយរត់គេចខ្លួនមកប្រទេសកម្ពុជា បច្ចុប្បន្នស្នាក់នៅខេត្តព្រះសីហនុ ។

បានឃើញដីកាចាប់ខ្លួនចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ចេញដោយប្រធានចៅក្រមឈ្មោះ Petrov M.G the secretary of the court Kalashnikava E.S ស្នើសុំឱ្យចាប់ខ្លួនបុគ្គលឈ្មោះ Balatin Vladimir Vitalievitch ពីបទៈ បោកលុយក្រុមហ៊ុន ។

### បង្គាប់មក

ភ្នាក់ងារមានសមត្ថកិច្ចស្វែងរកចាប់ខ្លួនលើបុគ្គលឈ្មោះ Balatin Vladimir Vitalievitch ជនជាតិរុស្ស៊ី កើតនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៧៨ ជាប់ចោទពីបទៈ បោកលុយក្រុមហ៊ុន ប្រព្រឹត្តនៅចន្លោះឆ្នាំ ២០០៧-២០០៨ ហើយត្រូវនាំខ្លួនបុគ្គលនេះ ក្នុងរយៈពេលឆាប់បំផុតជូនព្រះរាជអាជ្ញាដែនដី ដើម្បីធ្វើការឃុំខ្លួនបុគ្គលនេះ ដោយអនុវត្តតាមមាត្រា ៥៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ជ.អគ្គព្រះរាជអាជ្ញា

# ឧបសម្ព័ន្ធទី ១១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**
**អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី និងព្រហ្មទណ្ឌ**
**នាយកដ្ឋានជំនួយទៅវិញទៅមកក្នុងវិស័យ**
**ព្រហ្មទណ្ឌ និងបត្យាប័ន**
លេខ៖ . . . . . . . . . . . . . . . .

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ** ៖ អំពីសំណើសុំធ្វើបត្យាប័នឈ្មោះ ពីប្រទេសឡាវ ដើម្បីនាំខ្លួនមកផ្តន្ទាទោសនៅប្រទេសកម្ពុជា។

**យោង** ៖ លិខិតលេខ ២០៨៥ លស ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ។

**កំណត់បង្ហាញរឿង**

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន ឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបថា ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់ក្រសួងមហាផ្ទៃដែលមានកម្មវត្ថុស្នើសុំធ្វើបត្យាប័ន ឈ្មោះ ភេទប្រុស កាន់អត្តសញ្ញាណប័ណ្ណ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ជានីតិជន ដោយសារបុគ្គលរូបនេះ ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញចេញដីកាបង្គាប់ឱ្យចាប់ខ្លួន លេខ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ពីបទ **ឆបោក** តាមមាត្រា ៣៧៧ និង៣៧៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៣។ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ ការិយាល័យនគរបាលអន្តរជាតិទីក្រុងវៀងច័ន្ទ ប្រទេសឡាវ បានជូនដំណឹងអំពីការចាប់ខ្លួនឈ្មោះ កាន់លិខិតឆ្លងដែនលេខ ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ពីបទឆបោកប្រជាជនឡាវ តាមបញ្ញត្តមាត្រា ១២០ នៃក្រមព្រហ្មទណ្ឌឡាវ និងបានឃុំខ្លួនចាប់ពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ ដល់បច្ចុប្បន្ននៅពន្ធនាគារ PHONTONG ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ ដោយហេតុថា ជនត្រូវចោទ បានប្រព្រឹត្តបទល្មើសនៅកម្ពុជា ដោយក្រុមហ៊ុន EBC និងមានដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់សាលាដំបូងរាជធានីភ្នំពេញ ដូចនេះ ក្រសួងមហាផ្ទៃស្នើសុំធ្វើបត្យាប័នជនត្រូវចោទរូបនេះពីប្រទេសឡាវ យកមកផ្តន្ទាទោសតាមច្បាប់ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

តាមសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពី បត្យាប័ន៖

- ប្រការទី១៖ ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងមានភារកិច្ចធ្វើបត្យាប័នទៅភាគីម្ខាងទៀតនូវជនទាំងឡាយណា ដែលត្រូវបានឃើញនៅលើដែនដីនៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ហើយជនទាំងនោះកំពុងត្រូវគេតាមចាប់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ដើម្បីធ្វើការជំនុំជម្រះក្តី ឬដើម្បីឱ្យទទួលទោស ឬអនុវត្តទណ្ឌកម្មតាមទោសកំណត់ នៅលើទឹកដីរបស់ភាគីម្ខាងទៀត ចំពោះបទល្មើសដែលអាចធ្វើបត្យាប័នបានណាមួយ។

- ប្រការទី២ កថាខណ្ឌទី១ ៖ ក្នុងស្មារតីនៃសន្ធិសញ្ញានេះ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរ ដោយការដាក់ពន្ធនាគារ ឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំងសម្រាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬការផ្តន្ទាទោសណាមួយដែលធ្ងន់ជាងនេះ។

- ប្រការទី៧ ចែងថា៖

១-សំណើបត្យាប័នត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវភ្ជាប់ជាមួយនូវ៖

ក-ឯកសារសេចក្តីបញ្ជាក់ ឬភស្តុតាងដទៃទៀត មានលក្ខណៈគ្រប់គ្រាន់សម្រាប់ពិពណ៌នាអំពីអត្តសញ្ញាណ និងទីកន្លែងប្រហាក់ប្រហែលដែលជនត្រូវស្នើសុំកំពុងស្នាក់នៅ

ខ-សេចក្តីបញ្ជាក់លើអង្គហេតុនៃបណ្តឹងក្តី

គ-រាល់បទបញ្ញត្តិនៃច្បាប់ ដែលពិពណ៌នាអំពីធាតុសំខាន់ៗ និងការកំណត់នៃបទល្មើសដែលជាកម្មវត្ថុនៃបត្យាប័ន

ឃ-រាល់បទប្បញ្ញត្តិនៃច្បាប់ដែលចែងពីការផ្តន្ទាទោសទៅលើបទល្មើស និង

ង-រាល់បទប្បញ្ញត្តិនៃច្បាប់ ដែលចែងពីការកំណត់ពេលនៃការចោទប្រកាន់ ឬការអនុវត្តទណ្ឌកម្មចំពោះបទល្មើសប្រសិនបើមាន។

២-សំណើបត្យាប័ន ដែលទាក់ទងនឹងជនដែលត្រូវបានស្នើសុំ ដើម្បីចោទប្រកាន់ ត្រូវជាមួយផងដែរនូវ៖

ក-សេចក្តីចម្លងនៃដីកាចាប់ខ្លួន ដែលចេញដោយចៅក្រម ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតរបស់ ភាគីដាក់សំណើ។

ខ-ភស្តុតាងដែលអាចសំអាងបានសម្រាប់ការចាប់ខ្លួន និងការឃុំខ្លួនដើម្បីរង់ចាំការជំនុំជម្រះក្តីរបស់ជននោះ ដោយរាប់បញ្ចូលទាំងភស្តុតាងដែលបញ្ជាក់ថា ជនដែលត្រូវស្នើសុំពិតជាជនដែលកំណត់ក្នុងដីកាចាប់ខ្លួន ។

៤-រាល់ឯកសារទាំងអស់ដែលភាគីដាក់សំណើ ត្រូវបញ្ជូនឲ្យក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ ត្រូវចុះហត្ថលេខា ឬបោះត្រាជាផ្លូវការ និងភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសានៃភាគីទទួលសំណើ ឬជាភាសាអង់គ្លេស។

តាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា៖

- មាត្រា ៣៧៧ និយមន័យនៃការឆបោក៖ អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឲ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវ (១) ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ (២) ការផ្តត់ផ្គង់សេវា (៣) ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឲ្យរួចពីកាតព្វកិច្ច។

- មាត្រា ៣៧៨ ទោសដែលត្រូវអនុវត្ត៖ អំពើឆបោកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

**<u>ពាក់ព័ន្ធនឹងករណីនេះ ពិនិត្យឃើញថា៖</u>**

- ព្រះរាជាណាចក្រកម្ពុជា និងប្រទេសឡាវ មានសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីបត្យាប័ន

- ជនត្រូវចោទ ឈ្មោះ មានសញ្ជាតិខ្មែរ ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ចេញដីកាបង្គាប់ឲ្យចាប់ខ្លួន លេខ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ពីបទ **ឆបោក** តាមមាត្រា ៣៧៧ និង ៣៧៨ នៃក្រមព្រហ្ម-ទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៣ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ ហើយបទល្មើសនេះ ក៏ជាបទឆបោក តាមបញ្ញត្តមាត្រា ១២០ នៃក្រមព្រហ្មទណ្ឌឡាវផងដែរ និងបានឃុំខ្លួនចាប់ពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ ដល់បច្ចុប្បន្ននៅពន្ធនាគារ PHONTONG ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដោយអនុលោមតាមប្រការទី១ និងទី២ កថាខណ្ឌទី១ នៃសន្ធិសញ្ញា។

- ឯកសារដែលក្រសួងមហាផ្ទៃបានភ្ជាប់មកបញ្ជាក់ថាជនត្រូវចោទ ឈ្មោះ មានសញ្ជាតិខ្មែរ កំពុងជាប់ឃុំនៅពន្ធនាគារ PHONTONG ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ ជាមួយគ្នានេះ ជននេះបានប្រព្រឹត្តបទល្មើសឆបោកនៅកម្ពុជា ដោយក្រុមហ៊ុន EBC តាមមាត្រា ៣៧៧ និង៣៧៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងមានភ្ជាប់នូវដីកាបង្គាប់ឲ្យចាប់ខ្លួន លេខ៤២៧ ដ.ច.ន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ប៉ុន្តែមិនបានភ្ជាប់នូវភស្តុតាងសំអាងផ្សេងទៀត ពាក់ព័ន្ធនឹងសំណុំរឿងរបស់ជនត្រូវចោទរូបនេះនោះទេ ដែលភស្តុតាងសំអាងពាក់ព័ន្ធនឹងការចាប់ខ្លួននេះ ជាតម្រូវការនៃការធ្វើបត្យាប័នផ្អែកតាមសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជា-ធិបតេយ្យប្រជាមានិតឡាវ ស្តីពីបត្យាប័ន។

- កថាខណ្ឌទី៤ នៃសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីបត្យាប័ន ទាមទារនូវឯកសារចុះហត្ថលេខា ឬបោះត្រាផ្លូវការ តែដីកាបង្គាប់ឲ្យចាប់ខ្លួន លេខ៤២៧ ដ.ច.ន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ដែលបានទទួលពីក្រសួងមហាផ្ទៃ មិនមែនជាច្បាប់ដើមនោះទេ។ ម្យ៉ាងវិញទៀត កថាខណ្ឌនេះ ក៏តម្រូវឲ្យធ្វើការបកប្រែឯកសារភ្ជាប់នឹងសំណើបត្យាប័នជាភាសានៃភាគីទទួលសំណើ ឬជាភាសាអង់គ្លេសផងដែរ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ក្រសួងគប្បី៖

- ធ្វើលិខិតទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការពិនិត្យ និងរាយការណ៍អំពីព័ត៌មានលម្អិតដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធនឹងជនត្រូវចោទរូបនេះ ដើម្បីក្រសួងមានមូលដ្ឋានរៀបចំសំណើធ្វើបត្យាប័ន។
- ធ្វើការបកប្រែឯកសារភ្ជាប់នឹងសំណើបត្យាប័នជាភាសាអង់គ្លេស
- រៀបចំសំណើធ្វើបត្យាប័នជនត្រូវចោទ ឈ្មោះ ពីប្រទេសឡាវ មកផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជា។

<table>
<tr><th>មតិយោបល់ មន្ត្រីជំនាញ</th><th>មតិយោបល់ លោកស្រីប្រធាននាយកដ្ឋាន</th></tr>
<tr><td>សំណើសុំធ្វើបត្យាប័នជនត្រូវចោទ ពីប្រទេសឡាវ មកផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជាក្រសួងគប្បីធ្វើលិខិតទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការពិនិត្យ និងរាយការណ៍ អំពីព័ត៌មានលម្អិតដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធនឹងជនត្រូវចោទរូបនេះ ដើម្បីក្រសួងមានមូលដ្ឋានរៀបចំសំណើធ្វើបត្យាប័ន និងធ្វើការបកប្រែឯកសារភ្ជាប់នឹងសំណើបត្យាប័នជាភាសាអង់គ្លេស។ ម៉្យាងទៀត ក្រសួងគួររៀបចំសំណើធ្វើបត្យាប័នជនត្រូវចោទ ឈ្មោះ ហួត សុវណ្ណ ពីប្រទេសឡាវ មកផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជា។<br>សូមគោរពជូនលោកស្រីប្រធាននាយកដ្ឋានមេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។</td><td></td></tr>
<tr><th colspan="2">មតិយោបល់ ឯកឧត្តមអគ្គនាយក</th></tr>
<tr><td colspan="2"></td></tr>
<tr><th>មតិយោបល់ ឯកឧត្តមរដ្ឋលេខាធិការ</th><th>មតិយោបល់ ឯកឧត្តមរដ្ឋមន្ត្រី</th></tr>
<tr><td></td><td></td></tr>
</table>

# ឧបសម្ព័ន្ធទី ១២

**<u>គំរូឯកសារដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (ទី ១)</u>**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអមសាលាដំបូង**

**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ...................

ចុះថ្ងៃទី..........ខែ..........ឆ្នាំ...........

លេខ................................អ.យ.ខ[១]

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

**យើង សុខ រឿន តំណាងអយ្យការអមសាលាដំបូងក្រុងភ្នំពេញ ។**

បានឃើញសំណុំរឿងលេខ.................................ចុះថ្ងៃទី............ខែ................ឆ្នាំ....................

របស់[២] ............. ...................................................................................... ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា មានពត្រុយសន្មតបានថា:**

**នាមត្រកូល**..................**នាមខ្លួន**.................ហៅ.........ភេទ........អាយុ.........ឆ្នាំ ជាតិ................របររកស៊ី............

**ទីកន្លែងកំណើត**......................ឃុំ-សង្កាត់...................ស្រុក-ខណ្ឌ............................ខេត្ត-ក្រុង.........................

**ទីលំនៅបច្ចុប្បន្ន**......................ឃុំ-សង្កាត់......................ស្រុក-ខណ្ឌ..........................ខេត្ត-ក្រុង...................

ទោសពីមុន.................ឪពុកឈ្មោះ..............................រ.ស ម្ដាយឈ្មោះ...................................រ.ស

ប្ដីឬប្រពន្ធឈ្មោះ........................................រ.ស មានកូន....................ឬនៅលីវ☐ **អនីតិជន☐ឬនីតិជន☐** ។

**បានប្រព្រឹត្តអំពើដូចតទៅ**[៣] :..........................................................................................................

.........................................................................................................................................................

.........................................................................................................................................................

.........................................................................................................................................................

.........................................................................................................................................................

.......................................................................... ។

អំពើខាងលើជាបទល្មើស.........................................................ប្រព្រឹត្តនៅ..................................................................

..................កាលពីថ្ងៃទី.............ខែ....................ឆ្នាំ......................តាមមាត្រា...........................................នៃច្បាប់............

........................................................................................................................................................ ។

បានឃើញមាត្រា **៤៤** និងមាត្រា **១២៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**សម្រេច**

---

[១] **លេខដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

[២] **លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌**

[៣] **សេចក្ដីសង្ខេបអង្គហេតុ**

[illegible]៖

- ☐ ដាក់ឱ្យស្ថិតនៅក្រោម[illegible][៤]៖..........................................................................................................................
..........................................................................................................................................................
...........................................................................................................................................................។
- ☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៥]៖..........................................................................................
..........................................................................................................................................................
...........................................................................................................................................................។
- ☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន[៦]៖..............................................................................................
..........................................................................................................................................................
...........................................................................................................................................................។

ធ្វើនៅភ្នំពេញ, ថ្ងៃទី........ខែ..............ឆ្នាំ២០០....

**តំណាងអយ្យការ**

---

[៤] [illegible]

[៥] [illegible] ២២៣

[៦] [illegible] ២០៥

# ឧបសម្ព័ន្ធទី ១៣

<u>គំរូដីកាកោះហៅឲ្យបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ (ទី ២)</u>

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**

**ក្រុងភ្នំពេញ**

## ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

សំណុំរឿងព្រហ្មទណ្ឌលេខ.......

ចុះថ្ងៃទី.....ខែ.......ឆ្នាំ២០០:::.............................**យើង** តំណាងអយ្យការអមសាលាដំបូងក្រុងភ្នំពេញ។

**បញ្ជាឱ្យចូលទៅបង្ហាញខ្លួននៅសវនាការ :**

**នាមត្រកូល**......................**នាមខ្លួន**.................................ហៅ...............

ភេទ........អាយុ.......ឆ្នាំ ជាតិ.................របររកស៊ី...................................

**ទីកន្លែងកំណើត**.................................ឃុំ-សង្កាត់.................................

ស្រុក-ខណ្ឌ....................................ខេត្ត-ក្រុង....................................

**ទីលំនៅបច្ចុប្បន្ន**.............................. ឃុំ-សង្កាត់....................................

ស្រុក-ខណ្ឌ....................................ខេត្ត-ក្រុង....................................

ទោសពីមុន........ឪពុកឈ្មោះ...................“រ.ស”ម្តាយឈ្មោះ...................“រ.ស”

ប្តី ឬប្រពន្ធឈ្មោះ..................“រ.ស”មានកូន.........ឬនៅលីវ **អនីតិជន☐ ឬនីតិជន☐** ។

**អ្នកត្រូវបានចោទប្រកាន់ពី(អង្គហេតុ[៩]):**.....................................................

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

---

[៩] សេចក្តីសង្ខេបអង្គហេតុដែលរៀបរាប់អំពីធាតុសម្បាននុម័ត និងអង្គនោះមិត

.............................................................................................................

.............................................................................................................

.............................................................................................................

...........................................................។

ជាបទល្មើស.........................................................................................

.............ប្រព្រឹត្តនៅ.................................................................................

.................................កាលពីថ្ងៃទី........ខែ........ឆ្នាំ២០០....ដែលចែងក្នុងមាត្រា.............

នៃច្បាប់...................................................................................................។

**សវនាការនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី.......ខែ.......ឆ្នាំ.........វេលាម៉ោង............នៅ.........**

**................................................។**

សាមីខ្លួនអាចពឹងមេធាវីឱ្យអមខ្លួនបាន ។

សាមីខ្លួនត្រូវចូលបង្ហាញខ្លួនឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងជីវភាពសាមីខ្លួន ឬដំណើររឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅអយ្យការ, ថ្ងៃទី........ខែ.........ឆ្នាំ២០០....

**តំណាងអយ្យការ**

# ឧបសម្ព័ន្ធទី ១៤

<u>គំរូកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម</u>

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**

**ក្រុងភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ.......

ចុះថ្ងៃទី.....ខែ.......ឆ្នាំ២០០..

## កំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ឆ្នាំពីរពាន់...............ខែ............ថ្ងៃទី................វេលាម៉ោង..............។

**យើង**.....................................តំណាងអយ្យការអមសាលាដំបូងក្រុងភ្នំពេញ

បានឃើញសំណុំរឿងលេខ[៨] ......................ចុះថ្ងៃទី.........ខែ.........ឆ្នាំ.......

របស់.......................................................................។

**បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម :**

**នាមត្រកូល**.......................**នាមខ្លួន**..................................ហៅ...........

ភេទ........អាយុ.......ឆ្នាំជាតិ.................របររកស៊ី...............................

**ទីកន្លែងកំណើត**...........................ឃុំ-សង្កាត់...................................

ស្រុក-ខណ្ឌ................................ខេត្ត-ក្រុង................................

**ទីលំនៅបច្ចុប្បន្ន**........................... ឃុំ-សង្កាត់...................................

ស្រុក-ខណ្ឌ.....................................ខេត្ត-ក្រុង............................

ទោសពីមុន........ឪពុកឈ្មោះ....................“រ.ស”ម្តាយឈ្មោះ....................“រ.ស” ប្តី ឬប្រពន្ធឈ្មោះ...................“រ.ស”មានកូន.........ឬនៅលីវ

**អនីតិជន**☐ ឬ**នីតិជន**☐ ។

---

[៨] **លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌**

**យើងប្រាប់ដល់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ**

**:**..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

.................................................................................................... ។

**អង្គហេតុនេះជាបទល្មើស**..........................................................................

......ប្រព្រឹត្តនៅ..................................................................................................

កាលពីថ្ងៃទី..........ខែ...........ឆ្នាំ២០០.....ដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា..................

......នៃច្បាប់.................................................................................................... ។

**យើងបានទទួលចម្លើយពីជននេះដូចតទៅៈ**...........................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................។

**យើងបានប្រាប់ដល់ជននេះថា** : ខ្លួនមានសិទ្ធិសុំពឹងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬស្នើសុំឱ្យ មានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

**ជននេះបានឆ្លើយថា** :

- ☐ ខ្ញុំជ្រើស លោក/លោកស្រីមេធាវី .............................. ។
- ☐ ខ្ញុំសូមស្នើសុំឱ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។
- ☐ ខ្ញុំមិនត្រូវការមេធាវីនៅក្នុងពេលនេះ ។

**យើងបានបញ្ជាក់ថា** :

- ☐ លោក/លោកស្រីមេធាវី...............................អាចពិនិត្យសំណុំរឿងនិងទាក់ទង ជាមួយ ជនជាប់ចោទ ។
- ☐ យោងលើសំណើសុំឱ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ស្តីពីលក្ខន្តិកៈមេធាវីតំណាង គណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។
- ☐ លោក/លោកស្រីមេធាវី...............................អវត្តមាន ។

បានឃើញមាត្រា **៩៧** មាត្រា **៩៨** និងមាត្រា **៣០៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## សម្រេច

**បញ្ជូនជនជាប់ចោទឈ្មោះ**...................................................................... ......ទៅតុលាការដើម្បីធ្វើការជំនុំជម្រះ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះអង្គហេតុ និងបទល្មើសដូច ខាងលើ ។

ក្រោយពីបានអាន ជនជាប់ចោទបានចុះហត្ថលេខាជាមួយយើង ។

**ជនជាប់ចោទ** **តំណាងអយ្យការ**

# ឧបសម្ព័ន្ធទី ១៥

**<u>គំរូដីកាបង្គាប់ឲ្យចូលខ្លួន៖</u>**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>សាលាដំបូងខេត្ត.............</u>**

លេខអយ្យការៈ .........................

លេខស៊ើបសួរៈ .........................

លេខៈ.........................

## <u>ដីកាបង្គាប់ឲ្យចូលខ្លួន</u>

**យើង .................... ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត............ ។**

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរនោះ ទាក់ទងនឹងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ .................... ចុះថ្ងៃទី .......... ខែ..........ឆ្នាំ ............ របស់តំណាងអយ្យការអមសាលាដំបូងខេត្ត .................... ដែលបើកការប្រឆាំងនឹងជនត្រូវចោទឈ្មោះ ...................... ពីបទៈ ...................... ប្រព្រឹត្តនៅភូមិ ........ ឃុំ ........ ស្រុក .......... ខេត្ត .......... កាលពីថ្ងៃទី........ ខែ........ ឆ្នាំ........ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា......... នៃច្បាប់............................ ។

## <u>បង្គាប់មក</u>

ឈ្មោះ **..................** ភេទ...... អាយុ....... រស់នៅភូមិ ....... ឃុំ........ស្រុក........ខេត្ត.................

**<u>ឲ្យចូលមកកាន់សាលាដំបូងខេត្ត....................................</u>** ។

- **នៅថ្ងៃទី** .................. **ខែ** ............ **ឆ្នាំ** ............ **វេលាម៉ោង** ......................... ជាកំណត់ ។
- **ដើម្បី ឆ្លើយបំភ្លឺពីដំណើររឿងពាក់ព័ន្ធ និងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។**

សាមីខ្លួនត្រូវចូលមកបង្ហាញខ្លួនឲ្យទាន់ពេលវេលា តាមការកំណត់ខាងលើ និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងសំណុំរឿងខាងលើមកជាមួយផងប្រសិនបើមាន។

**ក្នុងករណីមិនចូលខ្លួនតាមការកំណត់ខាងលើទេ <u>យើងនឹងចេញបញ្ជាឱ្យកម្លាំងសាធារណៈបង្ខំសាមីខ្លួនឱ្យចូលមកបង្ហាញខ្លួនពី យើងចេញដីកាបង្គាប់ឱ្យនាំខ្លួន ។</u>**

ធ្វើនៅ........... ថ្ងៃទី ......... ខែ ......... ឆ្នាំ.........

**ចៅក្រមស៊ើបសួរ**

**ហត្ថលេខា និង ត្រា**

# ឧបសម្ព័ន្ធទី ១៦

**<u>គំរូដីកាបង្គាប់ឲ្យនាំខ្លួនៈ</u>**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>សាលាដំបូងខេត្ត.............</u>**

លេខអយ្យការៈ ...........................

លេខស៊ើបសួរៈ ...........................

លេខៈ...........................

**<u>ដីកាបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទ</u>**

យើង ...................... ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត......................ៗ

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ៦០០ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៧ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរនោះ ទាក់ទងនឹងការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ...................... ចុះថ្ងៃទី ........ ខែ ......... ឆ្នាំ .......... របស់តំណាងអយ្យការអមសាលាដំបូងខេត្ត ............. ដែលបើកការប្រឆាំងនឹងជនត្រូវចោទ .............................. ពីបទៈ .................. ប្រព្រឹត្តនៅភូមិ ............ សង្កាត់ ......... ក្រុង .......... ខេត្ត ............. កាលពីថ្ងៃទី .......... ខែ ...... ឆ្នាំ .......... តាមបញ្ញត្តិមាត្រា ............ នៃច្បាប់.......................................................... ។

យល់ឃើញថា ............................................................................................................................ ។

យល់ឃើញថា ............................................................................................................................ ។

យល់ឃើញថា ............................................................................................................................ ។

**<u>ហេតុដូច្នេះសម្រេច</u>**

- បង្គាប់ឲ្យនាំខ្លួនឈ្មោះ ...................... ភេទ......... អាយុ........ឆ្នាំ កើតនៅថ្ងៃទី .... ខែ .... ឆ្នាំ ........ មានទីកន្លែងកំណើតនៅភូមិ................ឃុំ..............ស្រុក................ខេត្ត............... និងរស់នៅបច្ចុប្បន្ននៅភូមិ................ឃុំ.............ស្រុក................ខេត្ត............... ឪពុកឈ្មោះ .................... ម្ដាយឈ្មោះ .................. មកកាន់សាលាដំបូងខេត្ត...................... ដើម្បីសាកសួរយកព័ត៌មានផ្សេងៗ ទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

- បង្គាប់មក **ភ្នាក់ងារមានសមត្ថកិច្ចគ្រប់ថ្នាក់** អនុវត្តដីកានេះឲ្យបានសម្រេច ។

...................., ថ្ងៃទី.............ខែ .......... ឆ្នាំ ...............

**ចៅក្រមស៊ើបសួរ**

**ហត្ថលេខា និង ត្រា**

# ឧបសម្ព័ន្ធទី ១៧

**គំរូដីកាបង្គាប់ឲ្យចាប់ខ្លួន**

## ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត..............**

លេខអយ្យការ: ..............................

លេខស៊ើបសួរ: ..............................

លេខ:..............................

## ដីកាបង្គាប់ឱ្យចាប់ខ្លួន

យើង ................ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត......................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ..................... ចុះថ្ងៃទី ............. ខែ ........... ឆ្នាំ ...............។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ .............. ចុះថ្ងៃទី .............. ខែ .......... ឆ្នាំ .......... របស់តំណាងអយ្យការអមសាលាដំបូងខេត្ត............................ ។

បានឃើញដីកាបញ្ជូនឲ្យឆ្លើយលេខៈ ...................... ចុះថ្ងៃទី ........... ខែ .......... ឆ្នាំ ............. របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្ត........................................ ។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់**

**យល់ឃើញថា**

- .......................................................................................................................................

-......................................................................................................................................

-.........................................................................................................................................

## <u>ហេតុដូច្នេះសម្រេច</u>

១- បង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ឲ្យចាប់ និងនាំខ្លួនជនឈ្មោះ..............ភេទ.........ជាតិ........អាយុ ..............ឆ្នាំ កើតនៅភូមិ....................ឃុំ.............ស្រុក....................ខេត្ត...................... រស់នៅភូមិ...............ឃុំ................. ស្រុក....................ខេត្ត................ឪពុកឈ្មោះ .............. ម្តាយឈ្មោះ ................. នៅលីវមានប្រពន្ធឈ្មោះ........................ ទោសពីមុន.............................................. ។

២- បង្គាប់ឲ្យប្រធានពន្ធនាគាខេត្តកំពង់ធំ ទទួលយកជននេះ រហូតដល់មានបទបញ្ជាកថ្មីសម្រេចផ្សេងពីនេះ ។

៣- បង្គាប់ឲ្យភ្នាក់ងារមានសមត្ថកិច្ច នៃកម្លាំងសាធារណៈទាំងអស់នៅពេលត្រូវបានបង្ហាញដីកានេះ ត្រូវអនុវត្តឲ្យបានល្អនៅក្នុងករណីចាំបាច់ ។

............., ថ្ងៃទី........... ខែ.......... ឆ្នាំ.............

**ចៅក្រមស៊ើបសួរ**